# មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយ សៅ សារ៉ុន ភេទប្រុស អាយុ៨៥ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ គណៈតំបន់១០៥**

**ស្រុកកំណើតៈ ភូមិកោះម៉ាយើល, ឃុំដីនៀត, ស្រុកកោះញែក, ខេត្តមណ្ឌលគីរី**

**សព្វថ្ងៃរស់នៅភូមិថ្នល់កែង(១០៥) ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២**

**សម្ភាសន៍ដោយៈ ឡុង ដានី**

**០២:២៥:៣៦**

**៧៥ទំព័រ**

ដានី : ខ្ញុំចង់ណែនាំខ្លួនខ្ញុំម្ដងទៀត ប្រាប់អ៊ំឲ្យកាន់តែយល់ច្បាស់ពី ខ្ញុំឈ្មោះ ដានី។ ហើយម្នាក់ដែលគាត់ទៅមិញនេះ គាត់ឈ្មោះ វណ្ណៈ។

សារ៉ុន : ដានី, វណ្ណៈ។

ដានី : ហើយពួកខ្ញុំពីរនាក់នេះ មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា នៅទីក្រុងភ្នំពេញ។ ហើយខ្ញុំធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជាៗនឹង គឺជាសមាជិកមួយនៃគណៈកម្មការអន្តរក្រសួងដែលរាជរដ្ឋាភិបាលបង្កើតគណៈកម្មការអន្តរក្រសួងឡើង គឺដើម្បីគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រនៅអន្លង់វែង។ ហើយខាងគណៈកម្មការអន្តរក្រសួង គេប្រជុំគេសម្រេចទៅ គឺខាងខ្ញុំខាងមជ្ឈមណ្ឌលឯកសារកម្ពុជានឹង ជាអ្នកមានភារកិច្ចជាអ្នកចងក្រង ជាអ្នករៀបចំសរសេរសៀវភៅពីប្រវត្តិសាស្ត្រទេសចរណ៍នៅស្រុកអន្លង់វែង។ ហើយយើងសរសេរប្រវត្តិសាស្ត្រទេសចរណ៍នឹងហើយ យើងអាចថាសរសេរជាសៀវភៅមគ្គុទេសទេសចរណ៍ថែមទៀត។ ការដែលយើងសរសេរសៀវភៅនឹងបានគឺអាស្រ័យទៅលើអ៊ំពូមីង ដែលគាត់ជាអ្នកតស៊ូ ហើយគាត់រស់នៅទីនេះ បទពិសោធន៍ជីវិតរបស់គាត់ៗបានឆ្លងកាត់នឹង ហើយគាត់ចែករំលែកមកដល់ពួកខ្ញុំ។ ហើយព័ត៌មានទាំងអស់នឹងវាមានសារៈសំខាន់ក្នុងការ ដែលពួកខ្ញុំចងក្រងសរសេរសៀវភៅនឹង។ ចឹងខ្ញុំមកជួបអ៊ំនេះក៏ក្នុងគោលបំណងមួយ ដើម្បីសុំឲ្យអ៊ំជួយចែករំលែកបទពិសោធន៍ជីវិតជីវិតរបស់អ៊ំកន្លែងណាដែលអ៊ំនៅចាំ អ៊ំជាអាជួយជម្រាបប្រាប់ខ្ញុំបាន សុំអ៊ំជួយជម្រាបប្រាប់ខ្ញុំកន្លែងណាដែលអ៊ំអត់ចាំ កន្លែងណាដែលអ៊ំអត់ដឹង កន្លែងណាដែលអ៊ំអត់ចង់និយាយ ក៏

អត់អីដែរ អត់មានបញ្ហាអីទេ ។ ចឹងអ៊ំអនុញ្ញាតិឲ្យខ្ញុំសួរនាំ ទាក់ទងពីបទពិសោធន៍ជីវិតរបស់អ៊ំទេ?

សារ៉ុន ៖ បាទ!

ដានី ៖ ចឹងអ៊ំជំរាបខ្ញុំចង់ស្គាល់ឈ្មោះពេញអ៊ំៗឈ្មោះអីដែរ?

សារ៉ុន ៖ សៅ សារ៉ុន ។

ដានី ៖ សៅ សារ៉ុន?

សារ៉ុន ៖ បាទ!

ដានី ៖ អ៊ំអាយុប៉ុន្មានហើយ សព្វថ្ងៃ?

សារ៉ុន ៖ ៨៥ ។

ដានី ៖ អាយុ៨៥?

សារ៉ុន ៖ បាទ! ដូចអស់ដល់ខែ១២នេះ ៨៦ហើយ ។

ដានី ៖ ចុះអ៊ំ ស្រុកកំណើតរបស់អ៊ំនៅភូមិឃុំស្រុកអីដែរ?

សារ៉ុន ៖ ស្រុកកំណើតនៅភូមិកោះម៉ាយើល ឃុំដីទៀត ។

ដានី ៖ ឃុំពាមជីទៀត?

សារ៉ុន ៖ បាទ! ស្រុកកោះញែក ខេត្តមណ្ឌលគិរី ។

ដានី ៖ អ៊ំសព្វថ្ងៃរស់នៅភូមិឃុំអីដែរសព្វថ្ងៃនេះ?

សារ៉ុន ៖ ឥឡូវនេះគេហៅថាភូមិថ្នល់កែង គេខ្វាចថ្នល់កែងច្រើន គេដាក់ចុង១០៥ ។

ដានី ៖ ភូមិថ្នល់កែង ១០៥?

សារ៉ុន ៖ បាទ! វាស្រុកច្រើនថ្នល់កែង ។

ដានី ៖ ឃុំអីដែរនៅនេះ?

សារ៉ុន ៖ ឃុំផ្អាវ ។

ដានី ៖ ស្រុក?

សារ៉ុន ៖ ស្រុកត្រពាំងប្រាសាទ ។

ដានី ៖ អូ! ស្រុកត្រពាំងប្រាសាទ នេះមិនមែន?

សារ៉ុន ៖ បាទ! មិនមែនអន្លង់វែង ។

ដានី ៖ ខេត្ត?

សារ៉ុន ៖ ខេត្តឧត្តរមានជ័យ ។

ដានី ៖ អ៊ំស្រីគាត់ឈ្មោះអីដែរ ប្រពន្ធអ៊ំ?

សារ៉ុន ៖ ផក់ យ៉ន់។

ដានី ៖ ផ-ក-់?

សារ៉ុន ៖ បាទ!

ដានី ៖ យ៉-ន-់ ហើយ?

សារ៉ុន ៖ បន្តក់ អត់ បន្តក់ក៏បានដែរ។

ដានី ៖ គាត់អាយុប៉ុន្មានហើយ ឥឡូវ?

សារ៉ុន ៖ អឺ! នេះស្មានៗ អាច៦៥អីចឹង ៦៨ ៦៩ បែប៧០ហើយ តាមមើល។

ដានី ៖ កើតឆ្នាំអីឆ្នាំខ្មែរ?

សារ៉ុន ៖ អត់ដឹងទេ។

ដានី ៖ ប្រហែលជា៦៩ ៧០អីនឹង?

សារ៉ុន ៖ បាទ! ប៉ុននឹងឯង។

ដានី ៖ ប៉ុន្តែបើអ៊ំៗចាំអាយុអ៊ំច្បាស់?

សារ៉ុន ៖ អឺ! អត់ចាំដែរនឹង ខ្ញុំអត់ចាំមែន។

ដានី ៖ ចុះអ៊ំជនជាតិអី?

សារ៉ុន ៖ ជនជាតិព្នង។

ដានី ៖ ចុះអ៊ំស្រីជនជាតិអី?

សារ៉ុន ៖ ជនជាតិចារាយ។

ដានី ៖ ចឹងអ៊ំប្រុសជនជាតិព្នង អ៊ំស្រីជនជាតិចារាយ?

សារ៉ុន ៖ បាទ!

ដានី ៖ ចឹងអាចនិយាយភាសាជនជាតិដូចគ្នា ហើយខុសគ្នា?

សារ៉ុន ៖ ខុសគ្នា និយាយភាសាចារាយផ្សេងទៅ និយាយភាសាព្នងផ្សេង ស្តាប់គ្នាអត់បានទេ។ ប៉ុនដល់មកនៅភូមិចំរុះ នៅកោះម៉ាយើលនឹង មានចារាយផង មានព្នងផង មានទំពួនផង គេមកធម្មតាដូចយើងឥឡូវនឹង ខ្មែរមកយកជនជាតិៗទៅយកខ្មែរទៅនៅចំរុះចឹងក៏ចេះភាសាព្នងដូចគ្នា អ្នកព្នងក៏ចេះចារាយដូចគ្នាទៅ វាចឹង។

ដានី ៖ ចុះនៅក្នុងក្រុមគ្រួសារអ៊ំនិយាយភាសាអីទៅ នៅផ្ទះដូចថា?

សារ៉ុន ៖ បើនៅនឹងនិយាយភាសាព្នងនឹងឯង។

ដានី : និយាយភាសាព្នង?

សារ៉ុន : បាទ! បើក្មេងឥឡូវប៉ុនៗអស់នេះអត់ចេះទេ ចេះតែប៉ុននេះ មានកូននេះទេ ។

ដានី : ចេះតែអ៊ំហើយនិងកូនទេ ដល់ពេលចៅអត់ចេះ?

សារ៉ុន : អត់ចេះ ។

ដានី : ប៉ុន្តែអ៊ំស្រីចេះនិយាយភាសាព្នងបានដែរ?

សារ៉ុន : និយាយភាសាព្នងដូចគ្នា គាត់ភាសាចារាយនោះភ្លេចអស់ហើយ ពីព្រោះគាត់នៅនឹងវា មិនបាននិយាយយូរ គាត់គ្រាន់តែយល់ ទៅភាសាព្នងនឹងគេចេះស្ទាត់ ។

ដានី : ចឹងអ៊ំឪពុកអ៊ំគាត់ឈ្មោះអីដែរ?

សារ៉ុន : ឈ្មោះ នូ ។

ដានី : ឪពុកឈ្មោះ នូ?

សារ៉ុន : បាទ! ស្លាប់ហើយ ស្លាប់តាំងពី ។

ដានី : ស្លាប់ឆ្នាំណាទៅ?

សារ៉ុន : ៧៣ អាយុគាត់ស្លាប់នឹង ១១៥ឆ្នាំ គាត់ស្លាប់ ។

ដានី : ចុះម្តាយ ឈ្មោះអីដែរ?

សារ៉ុន : ម្តាយ ប្រ៉ង ។

ដានី : សរសេរម៉េចទៅ?

សារ៉ុន : ប្រ-ប៉-ង ។

ដានី : ប្រ៉ង ។ គាត់ស្លាប់ពីអន្កាល់ណា?

សារ៉ុន : ស្លាប់មើល៩៨ អាយុគាត់១២០ឆ្នាំ គាត់ស្លាប់ ។ ១២០ឆ្នាំនឹងអត់វង្វេងអីទេណា នៅចាំកូនចាំចៅ ។

ដានី : អ៊ំបងប្អូនបង្កើតប៉ុន្មាននាក់ទៅ?

សារ៉ុន : ទាំងអស់១០នាក់ ។

ដានី : បងប្អូន១០នាក់?

សារ៉ុន : បាទ!

ដានី : ស្រីប៉ុន្មាន ប្រុសប៉ុន្មានទៅ?

សារ៉ុន : ស្រីមើលបងទី១ប្រុសស្រី១ ។

ដានី : ទី១ឈ្មោះអីទៅ?

សារ៉ុន ៖ ឡូ ។

ដានី ៖ ឈ្មោះ ឡូ ។ ឡូ-ូ ?

សារ៉ុន ៖ បាទ! គាត់ស្លាប់ ។

ដានី ៖ ស្លាប់ស្រី ហើយ ប្រុស?

សារ៉ុន ៖ ប្រុស បងទី១ ស្លាប់ហើយ គាត់អាយុ៩០ជាង ។

ដានី ៖ ៩០ជាង?

សារ៉ុន ៖ បាទ! គាត់បងទី១ ខ្ញុំនេះទី៣ទេ ខ្ញុំ ។

ដានី ៖ ទី២?

សារ៉ុន ៖ ទីបងប្រុស ។

ដានី ៖ ឈ្មោះអីដែរ?

សារ៉ុន ៖ ឈ្មោះ អូច អ-ូ-ច ។

ដានី ៖ គាត់នៅរស់ ហើយក៏?

សារ៉ុន ៖ នៅរស់ ។

ដានី ៖ គាត់នៅណាទៅ?

សារ៉ុន ៖ នៅរតនគិរី គាត់យកប្រពន្ធនៅរតនគិរី ។

ដានី ៖ អាយុប៉ុន្មានហើយឥឡូវ?

សារ៉ុន ៖ មើលគាត់បងខ្ញុំ ៨៥ហើយ គាត់នឹង៩០ហើយ ។

ដានី ៖ ទី៣អ៊ំ?

សារ៉ុន ៖ បាទ! ទី៣ខ្ញុំ ។

ដានី ៖ ទី៤?

សារ៉ុន ៖ អានឹងទី៤ ស្រី ។

ដានី ៖ ទី៤ ស្រី ឈ្មោះអីទៅ?

សារ៉ុន ៖ ខៃ ។

ដានី ៖ សព្វថ្ងៃគាត់នៅណា?

សារ៉ុន ៖ ស្លាប់ហើយ ស្លាប់នៅនេះដែរ ។

ដានី ៖ ទី៥?

សារ៉ុន ៖ អឺ! ស្រីដែរ ។

ដានី ៖ គាត់ឈ្មោះអីដែរ?

សារ៉ុន ៖ ឈ្មោះ សូរិយា ស្លាប់ហើយ ។ ស្លាប់ក្របីវ៉ៃតៗត្រង់នេះ គាត់ផ្លាស់ក្របីចងវាយូរទៅ វាអត់បានផឹកទឹក គាត់ទៅផ្លាស់ទៅក្របីវៃតស្លាប់ទៅ ។

ដានី ៖ ចុះឈ្មោះ ខៃ គាត់ស្លាប់ដោយសារអីដែរ?

សារ៉ុន ៖ ស្លាប់ដោយសារជម្ងឺឈឺគ្រុន ។

ដានី ៖ ទី៦?

សារ៉ុន ៖ អាត់ ស្លាប់ហើយ ។

ដានី ៖ គាត់ស្រី ហើយប្រុស?

សារ៉ុន ៖ ស្រី ។

ដានី ៖ គាត់ស្លាប់ដោយសារអីដែរ?

សារ៉ុន ៖ ឈឺគ្រុន ។

ដានី ៖ ទី៧?

សារ៉ុន ៖ ឡាត់ ។

ដានី ៖ ឈ្មោះ ឡាត់?

សារ៉ុន ៖ ស្លាប់ហើយ បាទ!ស្លាប់ឆ្នាំទៅនេះ បាទ! ឈឺរោគអីរោគ ។

ដានី ៖ ស្រីដែរ?

សារ៉ុន ៖ ស្រីដែរ ទៅដេកពេទ្យដល់សៀមរាប ដល់ឧត្តរមានជ័យ មកស្លាប់នៅផ្ទះ ។

ដានី ៖ ផ្ទះគាត់នៅណា?

សារ៉ុន ៖ នោះ ។

ដានី ៖ ផ្ទះនេះ?

សារ៉ុន ៖ អត់ទេ ខាងមុខនោះទៀត ហួសពីដី៤ផ្ទះបានដល់ផ្ទះ ។

ដានី ៖ ទី៨ឈ្មោះអីទៅ?

សារ៉ុន ៖ ទី៨ ណាលី ។

ដានី ៖ ណាលី ស្រី ហើយប្រុស?

សារ៉ុន ៖ ស្រី ។

ដានី ៖ នៅរស់ ឬក៏?

សារ៉ុន ៖ នៅរស់នៅស្រុក ។

ដានី ៖ នៅស្រុកណា?

សារ៉ុន ៖ ស្រុកកោះញ៉ែក។

ដានី ៖ នៅកោះញ៉ែក នៅកោះម៉ាយើល?

សារ៉ុន ៖ អត់ទេ នៅស្រុកកោះញ៉ែកនឹងម៉ង។

ដានី ៖ ទី៩?

សារ៉ុន ៖ ទី៩ ប្រុស។

ដានី ៖ ទី៩ ប្រុស គាត់ឈ្មោះអីដែរ?

សារ៉ុន ៖ ឈ្មោះ ចាំពី។

ដានី ៖ សំពី?

សារ៉ុន ៖ បាទ!

ដានី ៖ សំពី?

សារ៉ុន ៖ ចាំពី ច-ាំ-ពី។

ដានី ៖ ចាំពី?

សារ៉ុន ៖ បាទ!

ដានី ៖ គាត់ប្រុស សព្វថ្ងៃគាត់នៅណា?

សារ៉ុន ៖ នៅនោះ នៅមណ្ឌលគិរីនឹងដែរ។

ដានី ៖ រស់នៅមណ្ឌលគិរី នៅខេត្តម៉ង?

សារ៉ុន ៖ បាទ! នៅទីរួមខេត្ត។

ដានី ៖ ចុះទី១០?

សារ៉ុន ៖ ទី១០ ប្រុស ប៊ុតស៊ី ស្លាប់ហើយ។

ដានី ៖ គាត់ឈ្មោះអី?

សារ៉ុន ៖ ប៊ុតស៊ី។

ដានី ៖ គាត់ស្លាប់នៅណា?

សារ៉ុន ៖ ស្លាប់នៅស្រុក។

ដានី ៖ ស្លាប់នៅស្រុកកោះញ៉ែកនឹង?

សារ៉ុន ៖ បាទ!

ដានី ៖ ចុះអ៊ំកាលពីក្មេងៗអ៊ំនៅកោះម៉ាយើល?

សារ៉ុន ៖ បាទ! នៅកោះម៉ាយើល កំណើតពុកម៉ែ និងជីដូនតា គឺកើតនៅនឹងម៉ង ។

ដានី ៖ ចុះអ៊ំកាលនឹងអ៊ំបានរៀនសូត្រអីដល់ណាដែរ កាលពីក្មេងៗ ?

សារ៉ុន ៖ អត់ទេ បានរៀនវត្ត ។

ដានី ៖ ទៅរៀននៅសាលាវត្ត?

សារ៉ុន ៖ បាទ!រៀននៅវត្តប្រហែល២-៣ខែ ពុកថាសុំទៅលេងផ្ទះ ឈប់រៀនទៅ កាលនឹងគេរៀន អក្សរលាវ លោកនឹងមកពីស្រុកលាវ នៅធ្វើវត្តនឹង ។ ធ្វើវត្តអីហើយបានគេទៅវិញបាន គេប្រគល់ឲ្យលោកខ្មែរយើង ។

ដានី ៖ កាលរៀននៅវត្តនឹង រៀននៅវត្តណា?

សារ៉ុន ៖ វត្តពាមជីនៀត ។

ដានី ៖ កាលរៀននៅវត្តពាមជីនៀត?

សារ៉ុន ៖ បាទ!

ដានី ៖ តែរៀនអក្សរលាវទេ?

សារ៉ុន ៖ អក្សរលាវ ។

ដានី ៖ អត់រៀនអក្សរខ្មែរចឹង?

សារ៉ុន ៖ អត់ទេ រៀនអក្សរលាវ ចុះលោកលាវ មកធ្វើវត្ត មកកសាងវត្តនឹង ។

ដានី ៖ ចឹងអ៊ំចេះអក្សរខ្មែរទេ?

សារ៉ុន ៖ (ស្តាប់មិនច្បាស់) ចេះ ។

ដានី ៖ ចេះ?

សារ៉ុន ៖ បាទ! ដល់ចេះអក្សរខ្មែរនឹង លោកគ្រូគេទៅបង្រៀននៅកូនក្មេងនឹង គេមានគ្រូម្នាក់ គាត់ចាស់ដែរនឹង គេរៀនអក្ខរកម្ម យប់ៗទៅគេហៅចាស់ៗនឹងទៅរៀនម៉ោម៉ោងអី ទៅ សម្រាក ចឹងបានចេះអានតិចតួចទៅ ។ រៀននឹងក៏មិនបានយូរដែរ ពីព្រោះធម្មតាយើង រកស៊ី បានរៀនតែយប់ៗនឹង ។

ដានី ៖ កាលជំនាន់នៅក្មេងៗដែរ រៀនអក្សរខ្មែរនឹង?

សារ៉ុន ៖ អឺ! យកប្រពន្ធមានកូន ។

ដានី ៖ រៀនជាមួយលោក?

សារ៉ុន ៖ អត់ទេ លោកគ្រូ ។

ដានី ៖ លោកគ្រូហ៎?

សារ៉ុន ៖ លោកគ្រូគេទៅបង្រៀនក្មេងនឹង គេក៏ចែករំលែកឲ្យគ្រូម្នាក់គាត់ចាស់ទុំដែរ ឲ្យរៀនពេលយប់ រៀនចាស់ៗនឹង គេរៀនមានប្រុសមានស្រី រៀនយប់ ។

ដានី ៖ រៀនពេលយប់ៗ?

សារ៉ុន ៖ បាទ!

ដានី ៖ អ៊ំចេះអាន ចេះសរសេរច្បាស់ដែរ?

សារ៉ុន ៖ អត់សូវច្បាស់ទេ ។

ដានី ៖ អត់សូវច្បាស់ទេ?

សារ៉ុន ៖ បាទ! បើពាក្យជ្រៅជ្រះខ្ញុំអានក៏អត់ដាច់ដែរ អានតែពាក្យអក្សរច្រើន អក្សរលោវក៏ចឹងដែរវាចេះឲ្យស្ទាត់មែនទែនក៏អត់ចេះដែរ អានបានសរសេរបានតិចតួច ។

ដានី ៖ ហើយអ៊ំមានប្រពន្ធឆ្នាំណាទៅ?

សារ៉ុន ៖ អឺ! អត់ចាំទេក្មួយ ឆ្នាំណាទេ ដូចថា ។

ដានី ៖ តាំងពីជំនាន់សម្ដេចសីហនុ ឬក៏?

សារ៉ុន ៖ តាំងពីជំនាន់បារាំងនោះ ។

ដានី ៖ អ៊ំយកប្រពន្ធតាំងពីជំនាន់បារាំង?

សារ៉ុន ៖ បាទ! រួចគេ បារាំងដកចេញពីឥណ្ឌូចិននឹងណា ៥៤ មានសន្និសិទហ្សឺណែវនឹង ខ្ញុំអាច ៥៥អ៊ីយកប្រពន្ធ ។

ដានី ៖ យកប្រពន្ធឆ្នាំ៥៥?

សារ៉ុន ៖ អឺ! វាក្រោយបារាំងវាដកពីឥណ្ឌូចិនវិញ ។

ដានី ៖ អ៊ំស្រីអាយុប៉ុន្មាន កាលឆ្នាំ៥៥?

សារ៉ុន ៖ អឺ! ដូចអត់ដឹងទេ អាយុប៉ុន្មាន ។

ដានី ៖ ចឹងបន្ទាប់ពីបារាំងដកចេញពីឥណ្ឌូចិនឆ្នាំ៥៤ ឆ្នាំ៥៥អ៊ំយកប្រពន្ធ?

សារ៉ុន ៖ បាទ!

ដានី ៖ កាលនឹងអ៊ំធ្វើអីដែរ កាល?

សារ៉ុន ៖ អត់មានធ្វើអីទេ ធ្វើស្រែធ្វើចំការធម្មតា ។

ដានី ៖ អត់ទាន់មានចូលបដិវត្តន៍តស៊ូនៅ?

សារ៉ុន ៖ អត់ទេ មិនទាន់ដឹងបដិវត្តន៍បក្សអីទេ ធ្វើស្រែធ្វើចំការទៅ ។

ដានី ៖ ចឹងពេលដែលអ៊ំយកប្រពន្ធហើយ អ៊ំធ្វើស្រែ ធ្វើចំការនៅណាទៅ?

សារ៉ុន ៖ ធ្វើនៅភូមិកោះម៉ាយើលនឹងដដែល ។

ដានី ៖ នៅភូមិកោះម៉ាយើលនឹង?

សារ៉ុន ៖ បាទ!

ដានី ៖ ជីវភាពអ៊ីយ៉ាងម៉េចដែរ ដូចយើងធ្វើស្រែធ្វើចំការ?

សារ៉ុន ៖ ល្មមហូបគ្រប់គ្រាន់ ។

ដានី ៖ ល្មមហូបគ្រប់គ្រាន់?

សារ៉ុន ៖ បាទ! ធ្វើស្រែធ្វើចំការចិញ្ចឹមមាន់ ចិញ្ចឹមជ្រូក ល្មមហូបគ្រប់គ្រាន់ ខ្វះក៏មិនខ្វះ មានក៏មិនមានល្មមម៉ាគ្រប់ ។

ដានី ៖ ហើយអ៊ីមានកូនប៉ុន្មាននាក់ទាំងអស់?

សារ៉ុន ៖ ១០នាក់ ។

ដានី ៖ កូន១០នាក់ដែរ?

សារ៉ុន ៖ បាទ! ប្រុស៥ ស្រី៥ ។

ដានី ៖ កូន១០នាក់ ប្រុស៥ ស្រី៥?

សារ៉ុន ៖ បាទ! ឥឡូវនេះនៅ៦នាក់ ស្លាប់អស់៤នាក់ ។

ដានី ៖ ចុះកូនអ៊ីនៅស្រុកភូមិនេះប៉ុន្មាននាក់ ទៅនៅស្រុកវិញប៉ុន្មាននាក់?

សារ៉ុន ៖ នៅស្រុកនេះ នៅ៤នាក់ ។

ដានី ៖ នៅភូមិយើងនៅភូមិថ្នល់កែង១០៥នេះ ៤នាក់?

សារ៉ុន ៖ ៤នាក់ ទៅនៅស្រុកវិញ២នាក់ ។

ដានី ៖ ចឹងនៅសល់៦ ស្លាប់អស់៤?

សារ៉ុន ៖ បាទ! នៅសល់៦នាក់ ។

ដានី ៖ កូនបងអាយុ?

សារ៉ុន ៖ អឺ! កូនបងជឹងអាយុប៉ុន្មានទេ គាត់ស្លាប់ បងទី១ ស្លាប់ឈឺគ្រុនដែរ ទី២នៅ ទី៣នៅ ទី៤ស្លាប់ ទី៥ស្លាប់ ទី៦នេះស្រីនេះ ទី៧ស្លាប់ ។ មើល នៅ៦នាក់ ស្លាប់អស់៤នាក់ ។

ដានី ៖ ចុះអ៊ីដល់ពេលអ៊ីដូចថាចាប់ផ្តើមយើងចូលធ្វើការ ចូលគស៊ូអីពីឆ្នាំណា?

សារ៉ុន ៖ អឺ! អត់ចាំទេ ឆ្នាំណាទេ តាំងពីឆ្នាំណាទេ តាំងពីរដ្ឋប្រហារនឹង រដ្ឋប្រហារលន់ នល់ រដ្ឋប្រហារសម្តេចសីហនុនឹងណា ។

ដានី ៖ លន់ នល់ធ្វើរដ្ឋប្រហារសម្តេចសីហនុ ឆ្នាំ៧០?

សារ៉ុន ៖ ៧០ សម្ដេចក៏អំពាវនាវថាឲ្យកូនចៅក្រោកឡើងវៃចក្រពត្តិអាមេរិច ក៏ធ្វើការតស៊ូពីនឹងទៅមកទៅ ។

ដានី ៖ ចឹងពីមុនឆ្នាំ៧០ អ៊ំអត់ទាន់មានចូលតស៊ូអីទេ?

សារ៉ុន ៖ អត់ទេ នៅធម្មតា ។

ដានី ៖ ទាល់តែឆ្នាំ៧០ ពេលសម្ដេចអំពាវនាវនឹង បានអ៊ំចូលតស៊ូ?

សារ៉ុន ៖ បាទ! ធ្វើតស៊ូ ។

ដានី ៖ ចុះអ៊ំកាលជំនាន់ តា ប៉ុល ពត, អៀង សារី, អីគាត់ទៅតស៊ូនៅខាងភាគឦសាន តាំងពីឆ្នាំ៦៦អី កាលនឹងអ៊ំដឹង អ៊ំបានចូលរួម?

សារ៉ុន ៖ អត់ដឹងទេ ឮតែគេថា គេប្រកាសថា ក្រោកឡើង កូនចៅវៃចក្រពត្តិអាមេរិចក៏យើងក្រោកឡើងទៅវៃអាមេរិចទៅ ។

ដានី ៖ កាលនឹងឆ្នាំ៧០នឹង អ៊ំចូលតស៊ូៗនឹងចូលតស៊ូនៅណា ហើយធ្វើអីដែរ?

សារ៉ុន ៖ នៅមណ្ឌលគិរីនឹង ធ្វើទាហាន ។

ដានី ៖ ធ្វើទាហានខាងខ្មែរក្រហម?

សារ៉ុន ៖ បាទ! ដល់គេប្រកាសចឹង ឃើញខ្មែរក្រហម គេថារួបរួមគ្នា វៃចក្រពត្តិអាមេរិចទៅ ។ មិនដឹងកាលមុនមិនដឹងថាខ្មែរក្រហម ខ្មែរខៀវអីទេ ពីព្រោះសម្ដេចអំពាវនាវចឹងទៅ នាំគ្នាវៃអាមេរិចទៅ ។

ដានី ៖ នៅកោះម៉ាយើលនឹងម៉ង?

សារ៉ុន ៖ បាទ! នៅកោះម៉ាយើលនឹងម៉ង ។

ដានី ៖ ចឹងកាលនឹងទាហានខ្មែរក្រហមគេទៅដល់កោះម៉ាយើល ខាងលន់ នល់ អត់មានគ្រប់គ្រងអីទេចឹង?

សារ៉ុន ៖ គ្រប់គ្រង តែវាវៃកាលនឹងវៃមើល វៃ៧០ក្នុង៧០នឹងវៃគឺរំដោះបាន៥ខេត្ត ម៉ាប្រឹប ។

ដានី ៖ ឆ្នាំ៧០នឹងវៃរំដោះបាន៥ខេត្ត ម៉ាប្រឹបនឹង?

សារ៉ុន ៖ ម៉ាប្រឹបនឹង ។

ដានី ៖ រំដោះបានខេត្តណា?

សារ៉ុន ៖ មើលមណ្ឌលគិរី រតនគិរី ស្ទឹងត្រែង ក្រចេះ ។

ដានី ៖ ព្រះវិហារ?

សារ៉ុន ៖ អឺ! ព្រះវិហារ ៥ខេត្ត ។

ដានី ៖ ក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី និងព្រះវិហារ?

សារ៉ុន ៖ បាទ!

ដានី ៖ ៥ខេត្តក្នុងឆ្នាំ៧០នឹង បន្ទាប់ពីធ្វើរដ្ឋប្រហារបានប៉ុន្មានខែ បានគេវ៉ៃរំដោះបាន?

សារ៉ុន ៖ អឺ! ប្រកាសប្រហែលម៉ាខែ ពីរខែនឹងគេប្រកាសហើយវ៉ៃតែម្តង ប្រឹបម៉ង ។

ដានី ៖ កាលនឹងអ៊ំធ្វើទាហាននឹង នៅក្នុងកង នៅក្នុងអង្គភាពណាដែរ កាលពីឆ្នាំ៧០?

សារ៉ុន ៖ អឺ! មិនអង្គភាពទេ កាលនឹងមិនដឹងអង្គភាពពីណាទេ គិតតែធ្វើទាហានទៅវ៉ៃម៉ង ។

ដានី ៖ កាលនឹងពីណាគេ ជាប្រធាន ជាអ្នកដឹកនាំនៅខាងមណ្ឌលគិរី ខាងកង?

សារ៉ុន ៖ អត់ដឹងពីណាដឹកនាំទេ ឃើញតែថានាំគ្នាទៅវ៉ៃម៉ង យើងក៏មិនបាននាំសួរ ។

ដានី ៖ គ្នាច្រើនទេ កាលនឹង កាលយើង?

សារ៉ុន ៖ អូ! ច្រើនដែរ រួមគ្នា ទាំងខ្មែរយើង ទាំងបងប្អូនវៀតណាម គេថារួមគ្នាវ៉ៃចក្រពត្តិអាមេរិចនឹងណា រួមគ្នា ទាំងវៀតណាមទាំងខ្មែរយើងវ៉ៃរួមគ្នា ។

ដានី ៖ កាលនឹងទាំងវៀតណាម ទាំងខ្មែរទាំងអីយើងវ៉ៃរួមគ្នា?

សារ៉ុន ៖ បាទ! វ៉ៃរួម ។

ដានី ៖ ប៉ុន្តែមានគេអ្នកដឹកនាំវ៉ៃ មានដែរ?

សារ៉ុន ៖ មាន ។

ដានី ៖ តែអ៊ំស្គាល់ហ៎?

សារ៉ុន ៖ អត់ស្គាល់ទេ ។

ដានី ៖ អត់ស្គាល់ទេនោះ?

សារ៉ុន ៖ បាទ! អត់ស្គាល់ទេ ពីព្រោះច្រើនបងប្អូនវៀតណាម ដឹកនាំរួមណា ។

ដានី ៖ គេហៅវៀតកុង គេហៅអីគេ?

សារ៉ុន ៖ គេហៅវៀតកុង ។ កាលនឹងភាគច្រើនគេហៅវៀតកុង ។

ដានី ៖ ចុះកាលនឹងដូចជាខាង ប៉ុល ពត អៀង សារី អីគាត់មានទៅខាងកោះញែកទៅខាងកោះម៉ាយើលដែរអត់?

សារ៉ុន ៖ អត់ទេ អត់ឃើញគាត់ទេ ។

ដានី ៖ អត់ឃើញ?

សារ៉ុន ៖ បាទ!

ដានី ៖ ចុះអ៊ំធ្វើកងទ័ព ពេលដែលយើងរំដោះបាន៩ខេត្តភ្នំមនឹងធ្វើអីទៀតទៅ យ៉ាងម៉េចទៀតទៅ?

សារ៉ុន ៖ មួងនេះ គេ៧១នឹង គេដកមកធ្វើការងារមូលដ្ឋាន។ គេដកពីកងទ័ពមកវិញ ពីព្រោះវាអត់មានមនុស្សការងារមូលដ្ឋាននោះ គេដកមកវិញ មកធ្វើការស្រុក។

ដានី ៖ ទៅកាន់ស្រុកអីគេកាលនឹង?

សារ៉ុន ៖ ស្រុកពេជ្រចិន្តា។

ដានី ៖ តាំងពី៧១មក?

សារ៉ុន ៖ បាទ! តាំងពី៧១។

ដានី ៖ កាលដកមកឲ្យអ៊ំធ្វើជាអ្នកគ្រប់គ្រងនៅស្រុកពេជ្រចិន្តា?

សារ៉ុន ៖ បាទ!

ដានី ៖ តាំងពី៧១មក ពីណាគេអ្នកដូចថាយើងបែងចែកដកមកធ្វើមូលដ្ឋាននឹង ពីណាគេអ្នករៀបចំឲ្យអ៊ំធ្វើ?

សារ៉ុន ៖ មើលខាងគណៈតំបន់គេ។

ដានី ៖ កាលនឹងតំបន់ប៉ុន្មានទៅ ៧១?

សារ៉ុន ៖ គេ៧១ គេហៅតំបន់១០៥នឹង។

ដានី ៖ មានតំបន់១០៥ តាំងពី?

សារ៉ុន ៖ បាទ!

ដានី ៖ តាំងពី?

សារ៉ុន ៖ បាទ! តាំងពីនឹងមក។

ដានី ៖ តាំងពីនឹងមក?

សារ៉ុន ៖ បាទ! មណ្ឌលគិរី១០៥ គេដាក់តំបន់១០៥។ ដល់ក្រចេះនេះគេហៅថាតំបន់៥០៥។

ដានី ៖ ក្រចេះ៥០៥, មណ្ឌលគិរី១០៥ ចុះរតនគិរី?

សារ៉ុន ៖ រតនគិរីអត់ដឹងទេ មិនបានសួរទេ ដឹងគេដាក់លេខប៉ុន្មានៗ ដឹងតែពីខេត្តនឹង។

ដានី ៖ កាលនោះ កាលគណៈតំបន់១០៥ កាលឆ្នាំ៧១ កាលនឹងពីណាគេខ្លះទៅ?

សារ៉ុន ៖ មើល តា ឡាំង, ជនជាតិព្នងដែរ។

ដានី ៖ ពីណាទៀតគណៈតំបន់?

សារ៉ុន ៖ តា ម៉ៃ។

ដានី ៖ គាត់ជនជាតិអីដែរ តា ម៉ៃ?

សារ៉ុន ៖ ខ្មែរ ។

ដានី ៖ តែពីរនឹងទេ?

សារ៉ុន ៖ មាន ដូចពីរ៣នាក់ ។

ដានី ៖ ចុះ តា ខាំភួន?

សារ៉ុន ៖ អឺ! តា ខាំភួន នឹងម្នាក់ ។

ដានី ៖ តា ខាំភួន នឹងម្នាក់ទៀត?

សារ៉ុន ៖ បាទ! គណៈតំបន់គេ ។

ដានី ៖ តា ខាំភួន ជនជាតិអីដែរ?

សារ៉ុន ៖ ជនជាតិលាវ ។

ដានី ៖ ចុះអ៊ំ ស្គាល់ តា ឡាំង, តា ម៉ៃ, តា ខាំភួន នឹង ស្គាល់គាត់តាំងពីអង្កាល់?

សារ៉ុន ៖ ស្គាល់ កាលរំដោះខេត្តហើយនឹង ។

ដានី ៖ កាលរំដោះខេត្តហើយ កាលឆ្នាំ៧០នឹង?

សារ៉ុន ៖ បាទ!

ដានី ៖ ចុះអ៊ំកាលនឹងយើង ដូចថាយើងមានសមត្ថភាពយើងយ៉ាងម៉េច បានគេចាត់តាំងអ៊ំឲ្យអ៊ំធ្វើជាគណៈស្រុកនៅពេជ្រចិន្តា?

សារ៉ុន ៖ មិនដឹងម៉េចទេ គេចាត់តាំង ខ្ញុំចេះតែប្រកែកដែរ គេថាវាអត់មានមនុស្សទេ ក៏ខ្ញុំធ្វើទៅចឹងណា ។ សមត្ថភាពវាអត់មានទេ ដូចខ្ញុំនិយាយពីខាងដើម វប្បធម៌ អក្សរសាស្ត្រក៏មិនចេះ ហើយចេះតិចតួច ប៉ុនគេថាធ្វើទៅ ។ ចេះតែធ្វើទៅ គេក៏ចេះតែណែនាំទៅ ។

ដានី ៖ ប៉ុន្តែកាលនឹងដូចថា គាត់ស្និតស្នាលជាមួយអ៊ំដែរ ដូចថាកាលពេលដែលយើងរំដោះបានគាត់ស្គាល់អ៊ំច្បាស់ស្និតស្នាល?

សារ៉ុន ៖ បាទ!

ដានី ៖ ស្គាល់ប្រវត្តិអ៊ីអ៊ំច្បាស់ដែរ?

សារ៉ុន ៖ ស្គាល់ វាបានស្និតស្នាល ហើយរៀបចំការងារឲ្យខ្ញុំទៅធ្វើការងារនៅស្រុកនឹង ។

ដានី ៖ ចុះក្នុងចំណោម៣នាក់នឹង មួយណាដែលស្គាល់អ៊ំច្បាស់ជាងគេ?

សារ៉ុន ៖ ស្គាល់តែទាំងអស់ច្បាស់ហើយ ពីព្រោះនៅក្នុងក្របខណ្ឌស្រុក ហើយគេគ្រប់គ្រង ។

ដានី ៖ ស្គាល់ច្បាស់ទាំងអស់?

សារ៉ុន ៈ បាទ!

ដានី ៈ មុនដែលគេចាត់តាំងឲ្យអ៊ំទៅស្រុក?

សារ៉ុន ៈ បាទ!

ដានី ៈ អ៊ំដូចថា តាៗមួយណាដែលស្គាល់អ៊ំច្បាស់ ដូចថាអ្នកចាត់តាំងអ៊ំម៉េនពីណាគេ?

សារ៉ុន ៈ តា ឡាំង ។

ដានី ៈ តា ឡាំង គាត់មានឈ្មោះអីផ្សេងទៀត?

សារ៉ុន ៈ ដឹង ឃើញតែពួកគេហៅ តា ឡាំងៗ តា ម៉ៃ ក៏ចឹងដែរ ។

ដានី ៈ តា ម៉ៃ, តា ឡាំង អីចឹង ។ ចុះ តា ហម?

សារ៉ុន ៈ ឈ្មោះ តែមួយនឹងទេ ។

ដានី ៈ តា ហម ឈ្មោះពីណាគេ?

សារ៉ុន ៈ គាត់ឈ្មោះ តា ឡាំង នឹងឯង ។

ដានី ៈ តា ឡាំង គេហៅ តា ហម ចឹងដែរ?

សារ៉ុន ៈ បាទ!

ដានី ៈ ម៉េចបានគេហៅគាត់ តា ហម?

សារ៉ុន ៈ ដឹងគេ គេដូរដោះឈ្មោះ អត់ដឹងនឹងគេដែរ ។

ដានី ៈ ឈ្មោះ គាត់តែមួយតែមួយទេ?

សារ៉ុន ៈ ហ្នឹងហើយឈ្មោះ តែមួយ ។

ដានី ៈ ចុះ តា ម៉ៃ គាត់មានឈ្មោះអីផ្សេងទៀត?

សារ៉ុន ៈ អត់ឃើញពួកទេ ពួកតែគេហៅ តា ម៉ៃ ព្រោះគាត់មកពីក្រោមមក ។

ដានី ៈ គាត់មកនៅតស៊ូនឹងយូរហើយក៏យ៉ាងម៉េច?

សារ៉ុន ៈ យូរ តាំងពីនៅមិនទាន់រំដោះខេត្ត គាត់ទៅបង្កប់ខ្លួននៅក្នុងភូមិជនជាតិ តាមគាត់ប្រាប់ នេះណា អត់ដឹងគាត់ដែរ ។ អត់ដឹង គាត់ប្រាប់ គេរកចាប់ទៅ បែកការណ៍ធ្វើការងារ នៅកំពង់ធំនឹង ។ គាត់នៅកំពង់ធំទេ ។

ដានី ៈ ស្រុកកំណើតគាត់នៅកំពង់ធំ?

សារ៉ុន ៈ អឺ! គាត់ធ្វើគ្រូ ។

ដានី ៈ គាត់ធ្វើគ្រូនៅកំពង់ធំ តា ម៉ៃ?

សារ៉ុន ៖ បាទ! ដោយសារបែកការណ៍ទៅ គាត់រត់ទៅខាងមណ្ឌលគិរីទៅ ហើយទៅភៀសខ្លួនតាមភូមិជនជាតិ ហើយទៅចេះភាសាព្នងស្ទាត់ទៀត ។

ដានី ៖ គាត់ចេះភាសាព្នងស្ទាត់?

សារ៉ុន ៖ អូ! ស្ទាត់ណាស់ ។

ដានី ៖ ចុះ តា ឡាំង គាត់អ្នកស្រុកកំណើតនៅណា?

សារ៉ុន ៖ នៅកោះម៉ាយើលនឹងឯង ។

ដានី ៖ នៅកោះម៉ាយើលជាមួយអ៊ីដែរ?

សារ៉ុន ៖ បាទ!

ដានី ៖ តា ឡាំង ហើយអ៊ីពីណាអាយុច្រើនជាង?

សារ៉ុន ៖ គាត់ហើយ ។

ដានី ៖ គាត់អាយុច្រើនជាង?

សារ៉ុន ៖ បាទ!

ដានី ៖ គាត់ចាស់ជាង កាលជំនាន់អ៊ំនេះនឹង?

សារ៉ុន ៖ បាទ! គាត់ចាស់ជាង ។

ដានី ៖ ចុះ តា ខាំភួន គាត់នៅណា?

សារ៉ុន ៖ នៅជាមួយគ្នា តា ឡាំង នឹងដែរ ។

ដានី ៖ នៅកោះម៉ាយើលដែរ?

សារ៉ុន ៖ អត់ទេ ពាមជីទៀត ។

ដានី ៖ ស្រុកកំណើតគាត់នៅពាមជីទៀត ប៉ុន្តែ តា ឡាំង នៅកោះម៉ាយើល?

សារ៉ុន ៖ បាទ!

ដានី ៖ ចុះ តា ខាំភួន គាត់ចំណាស់ណាដែរ ចំណាស់អ៊ំ ឬក៏ចាស់ជាងអ៊ំ កាលជំនាន់នឹង?

សារ៉ុន ៖ គាត់ចាស់ជាងខ្ញុំតិច ប្រហែលជាបង២-៣ឆ្នាំនឹងឯង ។

ដានី ៖ ប៉ុន្តែកាលពីមុនតស៊ូ ក៏អ៊ំស្គាល់ តា ឡាំង, តា ខាំភួន ក៏អ៊ំស្គាល់ដែរ កាលនៅស្រុកកំណើត?

សារ៉ុន ៖ តា ឡាំង ស្គាល់ពីព្រោះនៅភូមិជាមួយគ្នានឹង ។

ដានី ៖ អត់មានជាប់សាច់ញាតិគ្នា?

សារ៉ុន ៖ អត់ទេ ។

ដានី ៖ ចុះអ៊ំ តា ឡាំង, តា ខាំភួន, តា ម៉ៃ គាត់តស៊ូតាំងពីមុនឆ្នាំ៧០ទៀត ហើយក៏យ៉ាង ម៉េច?

សារ៉ុន ៖ ដឹងគេធ្វើពេលនឹង អាចមុនហើយតាមមើលទៅ មើលបានគាត់រត់ពីកំពង់ធំមកលាក់ខ្លួន នៅមណ្ឌលគិរី នៅភូមិជនជាតិ បែបមុនហើយ ពីព្រោះមើលទៅអាចមុនទៅហើយ ពីព្រោះគាត់ធ្វើគ្រូបង្រៀនវាបែកការណ៍ៗ គ្រូបង្រៀន ហើយគាត់សាស្ត្រចារ្យដង បែកការណ៍ពីកំពង់ធំមកគាត់រត់មកមណ្ឌលគិរី លាក់ខ្លួននៅភូមិជនជាតិ បានចេះនិយាយ ភាសាព្នង ចេះទាំងប្រើទៀតណា ។

ដានី ៖ គាត់ចេះអីគេភាសាព្នង?

សារ៉ុន ៖ ចេះចំរៀងភាសាទៀត ។

ដានី ៖ ចេះចំរៀង ចេះច្រៀងភាសាជនជាតិទៀត?

សារ៉ុន ៖ បាទ! គាត់ចេះ ។

ដានី ៖ ពូកែ?

សារ៉ុន ៖ បាទ! ពូកែ គាត់រៀន ។

ដានី ៖ កាលនឹងគេចាប់ផ្តើមធ្វើដូចថា បែងចែកអ្នកធ្វើការនៅមូលដ្ឋាន ដូចជានៅតាមស្រុក ចាប់ផ្តើមពីឆ្នាំ៧១មក?

សារ៉ុន ៖ បាទ! ៧១ ។

ដានី ៖ ពីឆ្នាំ៧០អត់ទាន់?

សារ៉ុន ៖ អត់ទាន់ទេ គេខាងតំបន់គេគ្រប់គ្រងទាំងអស់ ។

ដានី ៖ ដល់ពេលឆ្នាំ៧១នឹង?

សារ៉ុន ៖ ខាងយោធានឹងគេធ្វើ ខាងយោធាគេនឹងមិនទាន់រៀបចំស្រុក រៀបចំភូមិអីទេខាងយោធា គេកាន់កាប់ ។

ដានី ៖ ចុះអ៊ំនៅស្រុកពេជ្រចិន្តាអ៊ំមានគ្នាប៉ុន្មាននាក់ អ៊ំមួយ ពីណាទៀត?

សារ៉ុន ៖ មើលខ្ញុំម្នាក់ បងម្នាក់ បងថ្លៃខ្ញុំម្នាក់ ទៅម្នាក់នឹង ទាំងអស់៤នាក់ ។

ដានី ៖ បងអ៊ំឈ្មោះអី ដែលធ្វើការខាងនឹង?

សារ៉ុន ៖ បង ដាក់ ។

ដានី ៖ ឈ្មោះ បង ដាក់?

សារ៉ុន ៖ បាទ! ស្លាប់ហើយ ស្លាប់ឆ្នាំទៅ ។

ដានី ៖ បងបង្កើត?

សារ៉ុន ៖ អត់ទេ បងថ្លៃ។

ដានី ៖ ហើយពីណាទៀត?

សារ៉ុន ៖ បង ដាំង នឹង ក៏បងថ្លៃដែរ។

ដានី ៖ ចឹងបងរបស់អ៊ំ ឈ្មោះ បង ដាក់, ដាំង នឹង សុទ្ធតែបងថ្លៃអ៊ំទាំងពីរ?

សារ៉ុន ៖ បាទ! បងថ្លៃ។

ដានី ៖ គាត់ធ្វើអនុរបស់អ៊ំ?

សារ៉ុន ៖ បាទ! ធ្វើរង ហើយមួយនឹង ប៊ុន ស៊ូ។

ដានី ៖ ប៊ុន ស៊ូ នឹងត្រូវជាម៉េចអ៊ំ?

សារ៉ុន ៖ អានឹងគាត់ជនជាតិទំពួន មកពីរតនគិរី។

ដានី ៖ ប៉ុន្តែអត់ជាប់សាច់ញាតិអ៊ំទេ?

សារ៉ុន ៖ អត់ទេ។

ដានី ៖ ចឹងមាន៤នាក់?

សារ៉ុន ៖ បាទ! ៤នាក់។

ដានី ៖ ប៊ុន ស៊ូ នឹងគាត់ទទួលផ្នែកអី?

សារ៉ុន ៖ គាត់ទទួលខាងផ្នែកអីទេ ទទួលផ្នែកខាងសេដ្ឋកិច្ច។

ដានី ៖ សេដ្ឋកិច្ច?

សារ៉ុន ៖ បាទ! បង ដាក់ នេះ គាត់ទទួលខាងទាហាន។

ដានី ៖ បង ដាក់ នេះ គាត់ខាងយោធា?

សារ៉ុន ៖ បាទ! បង ដាំង នេះ គាត់ទទួលខាងសង្គមកិច្ច។

ដានី ៖ ដល់ពេលគ្នាប់រួមអ៊ំ?

សារ៉ុន ៖ បាទ!

ដានី ៖ ចុះកាលនឹងនៅតំបន់១០៥ មានប៉ុន្មានស្រុកទៅ?

សារ៉ុន ៖ មាន៥។

ដានី ៖ ៥ពេជ្រចិន្តា?

សារ៉ុន ៖ កោះញែក។

ដានី ៖ ពេជ្រចិន្តា អ៊ំ, ដាក់, ដាំង, ប៊ុន ស៊ូ ចឹង?

សារ៉ុន ៖ បាទ!

ដានី ៖ ចុះពេជ្រចិន្តាហើយកោះញ៉ែក?

សារ៉ុន ៖ កោះញ៉ែក ។

ដានី ៖ មានស្រុកកោះញ៉ែក?

សារ៉ុន ៖ បាទ!

ដានី ៖ ស្រុកកោះញ៉ែក កាលនឹងពីណា ទទួលស្រុកកោះញ៉ែក?

សារ៉ុន ៖ មើលដូចពីណាគេមើល មាន ស្វាយ, មាន វ៉ា, មាន កែន ចាន់ ។

ដានី ៖ មាន ស្វាយ ហើយវ៉ា កែន ចាន់?

សារ៉ុន ៖ បាទ!

ដានី ៖ ស្វាយគាត់ជនជាតិអីដែរ?

សារ៉ុន ៖ ទំពួន ។

ដានី ៖ វ៉ា?

សារ៉ុន ៖ ជនជាតិលាវទំពួន ។ ម៉ែទំពួន ឪពុកលាវ ។

ដានី ៖ ចុះ កែន ចាន់?

សារ៉ុន ៖ គាត់លាវទំពួនដូចគ្នា ។

ដានី ៖ ហ្នឹងតាំងពីឆ្នាំ៧១មកដែរ?

សារ៉ុន ៖ បាទ! តាំងពី៧១មក ។

ដានី ៖ ចុះស្រុកពេជ្រចិន្តា, ស្រុកកោះញ៉ែក ស្រុកអីទៀត?

សារ៉ុន ៖ ស្រុកច្បារ ។

ដានី ៖ ស្រុកច្បារនៅកន្លែងណាទៅ បើឥឡូវអត់មានស្រុកច្បារផង?

សារ៉ុន ៖ នៅកន្លែងដេអេនោះ ផ្លូវទៅខេត ។

ដានី ៖ អូ! ដេអេអូររាំង?

សារ៉ុន ៖ អើ! អត់ទេ អូររាំងនៅនោះទៀត នៅត្បូងទៀត ដេអេផ្លូវយើងទៅខេត្តនឹង អានឹងគេហៅពីដើមគេហៅស្រុកច្បារ ។

ដានី ៖ ប៉ុន្តែឥឡូវគេអត់មានដាក់មានស្រុកច្បារ?

សារ៉ុន ៖ អត់ទេ មានតែ៤ ពីដើមគេដាក់៥ តាំងពីសម្តេចឪគ្រប់គ្រង ៥ស្រុក ឥឡូវនេះមានតែ ៤ ។

ដានី ៖ ស្រុកច្បារពីណាគេទទួល?

សារ៉ុន ៖ មើល បងអី បង លក ។

ដានី ៖ លក?

សារ៉ុន ៖ បាទ! ហើយពីណាទៀតទេ ខ្ញុំភ្លេចហើយ ។ បង លក, បង ហាន ហើយពីណាគេពីរនាក់ទៀត ខ្ញុំភ្លេចអស់ហើយ មិនបានចាំ ។

ដានី ៖ ចុះឈ្មោះ ចាំ?

សារ៉ុន ៖ អឺ! ចាំ ម្នាក់ ។

ដានី ៖ ចាំ ដែរ?

សារ៉ុន ៖ បាទ! ខ្មែរដែរ ។

ដានី ៖ ចាំ នឹងខ្មែរទេ?

សារ៉ុន ៖ បាទ! ខ្មែរ ។

ដានី ៖ ចុះ លក?

សារ៉ុន ៖ ជនជាតិ ព្នង-ទំពួន ។

ដានី ៖ ចុះ ហាន?

សារ៉ុន ៖ ព្នង ។

ដានី ៖ ពីណាគេទទួលរួម?

សារ៉ុន ៖ ចាំ ។

ដានី ៖ លក ហើយនិង ហាន អនុ រងរបស់គាត់?

សារ៉ុន ៖ បាទ! ស្លាប់អស់ហើយ ឈឺគ្រុន លក នឹងចាស់ជរា ស្លាប់នៅនេះដែរ ។

ដានី ៖ ពីណាគេស្លាប់?

សារ៉ុន ៖ លក ស្លាប់នៅនេះ ។

ដានី ៖ ចុះ ហាន?

សារ៉ុន ៖ ស្លាប់អស់ដែរ ស្លាប់សមាហរណកម្មហើយនេះ ។

ដានី ៖ ចុះ ស្វាយ?

សារ៉ុន ៖ ស្លាប់ហើយ ។

ដានី ៖ ចុះ រ៉ា?

សារ៉ុន ៖ ស្លាប់ហើយ ។

ដានី ៖ កែន ចាំ?

សារ៉ុន ៖ ស្លាប់ហើយ ។

ដានី ៖ គាត់ស្លាប់ពីអង្កាល់ ស្វាយ?

សារ៉ុន ៖ ស្លាប់ពី៧០ប៉ុន្មានទេ តាំងពី៧០ប៉ុន្មាន៧៦ ៧៧នឹងឯង ។

ដានី ៖ គាត់ស្លាប់ដោយសារមូលហេតុអី?

សារ៉ុន ៖ ស្លាប់ចងកខ្លួនឯង ។

ដានី ៖ ម៉េចចឹង គាត់ធ្វើធំ ម៉េចគាត់ចងកខ្លួនឯង?

សារ៉ុន ៖ ដឹងគាត់ ។

ដានី ៖ មានដឹងរឿងមូលហេតុអីបានគាត់ចងក?

សារ៉ុន ៖ អត់ដឹង ខ្ញុំមិនបានសាកសួរគេ ។

ដានី ៖ ចុះបើ ក៏ា អីគាត់យ៉ាងម៉េចដែរ គាត់ស្លាប់នៅស្រុកណា?

សារ៉ុន ៖ ស្លាប់ឈឺគ្រុនទេ ។

ដានី ៖ ស្លាប់នៅណា?

សារ៉ុន ៖ ស្លាប់នៅកោះញែក ។

ដានី ៖ ស្លាប់ពីអង្កាល់ទៅ?

សារ៉ុន ៖ អត់ដឹងពីណាទេ អត់ចាំទេ ខ្ញុំអត់ចាំទេ ថ្ងៃណាខែណាអត់ចាំ ។

ដានី ៖ ចុះ កែន ចាំ?

សារ៉ុន ៖ ស្លាប់ដែរ ។

ដានី ៖ មកស្លាប់នៅនេះ?

សារ៉ុន ៖ ស្លាប់នៅកោះញែកទាំងអស់ ។

ដានី ៖ ស្លាប់នៅកោះញែកដែរ?

សារ៉ុន ៖ ពេលវៀតណាមវ៉ៃរំដោះ ។

ដានី ៖ ចុះឈ្មោះ ចាំ?

សារ៉ុន ៖ ចាំ ដឹងគេហៅកាលនឹងភ្នំពេញ បាត់រហូត ។

ដានី ៖ ហៅទៅភ្នំពេញបាត់រហូត?

សារ៉ុន ៖ បាទ! គេហៅ អានឹងភ្នំពេញ បាត់រហូត ។

ដានី ៖ គេហៅទៅភ្នំពេញ បាត់រហូត?

សារ៉ុន ៖ បាទ! គេថាហៅទៅធ្វើការគ្មានឃើញមកវិញ ។

ដានី ៖ មិញស្រុកពេជ្រចិន្តា ស្រុកកោះញ៉ែក ស្រុកច្បារ ស្រុកអីទៀត?

សារ៉ុន ៖ ស្រុកអូររាំង ។

ដានី ៖ ពីណាគេទទួល អូររាំង?

សារ៉ុន ៖ គឺ ។

ដានី ៖ អូររាំងឈ្មោះ គឺ?

សារ៉ុន ៖ បាទ!

ដានី ៖ ពីណាទៀត?

សារ៉ុន ៖ ឃឿន ។

ដានី ៖ គឺ ទទួលរួម ឃឿន ក្រោម?

សារ៉ុន ៖ ក្រោម ។

ដានី ៖ គឺ គាត់ជនជាតិអីដែរ?

សារ៉ុន ៖ ជនជាតិ លាវ ចារាយ ។

ដានី ៖ ឃឿន?

សារ៉ុន ៖ ពួង សុទ្ធៗតែមានឋានៈខ្ពស់ ឪប្អូម ។

ដានី ៖ គាត់ឪប្អូមដែរ?

សារ៉ុន ៖ បាទ!

ដានី ៖ តែពីរនាក់នឹងទេ?

សារ៉ុន ៖ បាទ! ៣ ក្លេចហើយម្នាក់នេះឈ្មោះអីទេ នឹកអត់ឃើញទេ វាមាន៣នាក់ ។

ដានី ៖ ចុះស្រុកពេជ្រចិន្តា កោះញ៉ែក ច្បារ អូររាំង ស្រុកមួយទៀត ស្រុកអីគេ?

សារ៉ុន ៖ កែវសីម៉ា ។

ដានី ៖ កែវសីម៉ា ពីណាគេទទួលរួម?

សារ៉ុន ៖ ខាំភួន ។

ដានី ៖ ខាំភួន គាត់គណៈតំបន់?

សារ៉ុន ៖ គណៈតំបន់ ។

ដានី ៖ គណៈតំបន់ គាត់ទទួលស្រុកកែវសីម៉ាមួយទៀត?

សារ៉ុន ៖ បាទ!

ដានី ៖ ពីណាទៀត?

សារ៉ុន ៖ ចាន់ ដើរ ។

ដានី ៖ ចាន់ ដើរ?

សារ៉ុន ៖ បាទ!

ដានី ៖ ខាំភួន គណៈតំបន់នឹង គាត់ជាគណៈស្រុកកែវសីម៉ាទៀត?

សារ៉ុន ៖ បាទ!

ដានី ៖ ចាន់ ដើរ គាត់ជនជាតិអីដែរ?

សារ៉ុន ៖ ជនជាតិព្នង ។

ដានី ៖ តែពីរនឹងទេ?

សារ៉ុន ៖ ណា៎! ខាំ ទៀត ។

ដានី ៖ ខាំ?

សារ៉ុន ៖ ខាំៗ តែ៣នាក់នឹងទេ ។

ដានី ៖ ខាំ គាត់ជនជាតិអីគេ?

សារ៉ុន ៖ ជនជាតិទំពួនលាយ លាវ-ទំពួន ៣នាក់នឹង ។

ដានី ៖ អានឹងគេបែងចែកឆ្នាំ៧១ម៉ង៎?

សារ៉ុន ៖ បាទ! ៧១ បានគេរៀបចំ កាលមុននឹងមានគេខាងខាហានគេគ្រប់គ្រង ។

ដានី ៖ កាលនឹងនៅក្នុងខាងភូមិភាគណាទៅ?

សារ៉ុន ៖ ទេ! នៅមណ្ឌលគិរីនេះតំបន់ស្វយ័ត ។

ដានី ៖ តំបន់ស្វយ័ត?

សារ៉ុន ៖ បាទ!

ដានី ៖ អត់មាននៅក្រោមភូមិភាគ?

សារ៉ុន ៖ អត់ទេ ។

ដានី ៖ មិនមែនភូមិភាគឥសានចឹង?

សារ៉ុន ៖ ភូមិភាគឥសានដែរ ប៉ុន្តែតំបន់មណ្ឌលគិរីនេះ វាជាតំបន់ស្វយ័តទេ ។

ដានី ៖ តំបន់ស្វយ័ត?

សារ៉ុន ៖ បាទ! វានៅក្នុងក្របខ័ណ្ឌឥសាននឹងដែរ ។

ដានី ៖ តែមានការអីយើងទាក់ទងមកខាងមជ្ឈិមនៅភ្នំពេញនឹងបណ្ដោយ?

សារ៉ុន ៖ បាទ! មិនបានទាក់ទងទៅភូមិភាគទេ ។

ដានី ៖ ចឹងអត់ដែលធ្វើការជាមួយខាងភាគ ខាងគណៈភូមិភាគអីទេ?

សារ៉ុន ៖ អត់ទេ ។

ដានី ៖ ចុះកាលនឹងពីឆ្នាំ៧១នឹង គេដូចថាអីចាប់ផ្ដើមជាទទួលខាងស្រុកទទួលអី យើងទៅប្រជុំទៅរៀនសូត្រអីជាមួយខាងណាទៅ?

សារ៉ុន ៖ ខាងតំបន់ ។

ដានី ៖ ខាងតំបន់នឹងដូចថាគាត់បង្រៀនយើងចាប់ផ្ដើមមានមាគ៌ាយ៉ាងម៉េច ដឹកនាំប្រជាជន?

សារ៉ុន ៖ បាទ! គេទទួលមកពីខាងលើ គេបង្រៀនគេរៀបរយអីមានទៅខាងតំបន់ទេ គេអ្នកចុះដាប់ ។

ដានី ៖ កាលនឹងភាគច្រើន អីប៉ុន្មានថ្ងៃប៉ុន្មានខែយើងមកប្រជុំនៅតំបន់?

សារ៉ុន ៖ តែថាវាអត់ទៀងទេ ជួនកាលម៉ាខែម៉ាដងៗហើយ ជួនកាលវាមានសភាពការណ៍វាអានឹងអាមេរិចវាធ្វើសកម្មភាពខ្លាំងទៅក៏វាលើសខែដែរ គិតពីរឿងវ៉ៃរឿងអីទៅ ។

ដានី ៖ កាលនឹងយើងដូចថារៀបចំភូមិឃុំយ៉ាងម៉េចទៅ?

សារ៉ុន ៖ ឃុំនឹងយើងរៀបចំតាមឃុំចាស់គេ ។

ដានី ៖ ឃុំចាស់គេ?

សារ៉ុន ៖ បាទ! ភូមិក៏រៀបចំតាមចាស់គេ ដល់រៀបចំតាមចាស់គេទាំងអស់ តាមប្រព័ន្ធចាស់គេ ។

ដានី ៖ រៀបតាមភូមិចាស់គេទៅ?

សារ៉ុន ៖ បាទ! តាមភូមិចាស់គេ ។

ដានី ៖ ចុះមានរៀបចំកងទ័ពអីដែរអត់?

សារ៉ុន ៖ អត់ទេ តាមភូមិនេះ គេមានតែចាត់តាំងកងឈ្លប អ្នកស្រុកនឹង គេឲ្យតែស្រុកមួយគេឲ្យតែ៣០នាក់ទេ កងទ័ព ។

ដានី ៖ ម៉ាស្រុកគេឲ្យតែ៣០នាក់ទេ?

សារ៉ុន ៖ បាទ! កងស្រុកតែ៣០នាក់ ម៉ាអនុសេនាតូចទេ ។

ដានី ៖ ចុះតំបន់មានកងពលដែរអត់?

សារ៉ុន ៖ អត់មានទេ ។

ដានី ៖ ត្រឹមអីគេតំបន់?

សារ៉ុន ៖ ត្រឹមវរសេនាតូច ។

ដានី ៖ ម៉ាតំបន់?

សារ៉ុន ៖ ម៉ាតំបន់នឹងវាមានពីរវរសេនាតូច តែប៉ុននឹង ។

ដានី ៖ មានតែពីរវរសេនាតូចទេ?

សារ៉ុន ៖ បាទ!

ដានី ៖ តំបន់១០៥ កាលនឹងពីណាគេទទួលខាងយោធាតំបន់?

សារ៉ុន ៖ មើលកាលនឹងមិនដឹងពីណាគេ ខ្ញុំមិនបានចាំ ដែលគេទទួលខាងយោធានឹង ពីណាៗគេ ។

ដានី ៖ ចុះអឹដល់ពេល ពី៧១មក៧២ ៧៣ ៧៤ ៧៥នឹង យ៉ាងម៉េចខ្លះទៅ ដូចថាយើងគ្រប់គ្រងកាលនឹងនៅមានលន់ នល់ មានអី ពីមុនយើងមិនប្រទាញប្រទុងយើងវិគ្នា?

សារ៉ុន ៖ បាទ!

ដានី ៖ ពី៧១ ៧២ ៧៣ ៧៤ ៧៥?

សារ៉ុន ៖ បាទ!

ដានី ៖ យើងយ៉ាងម៉េចទៅ យើងដំណើរការក្នុងស្រុកភូមិយើងៗត្រូវរៀបចំប្រជាជនយ៉ាងម៉េច គាត់ធ្វើស្រែធ្វើចំការតាមផ្ទះ ឬក៏គាត់ចាប់ផ្ដើមដូចថាយើងធ្វើរួម យើងហូបរួមយ៉ាងម៉េចទៅ?

សារ៉ុន ៖ បាទ! តាំងពី៧១ រហូតមក៧៥ គេធ្វើហូបតាមគ្រួសាររៀងៗខ្លួនទេ គេឯកជន ប៉ុន្តែគេមានក្រុមគេហៅថាក្រុមសាមគ្គី ដូចយើងចាត់តាំងឥឡូវនេះ គេហៅក្រុមដឹកនាំ គេប្រវាស់ដៃគ្នា អត់មានថាធ្វើរួមធ្វើអីទេ ។ ប្រវាស់ដៃគ្នាពីណាក្រុមណាចេះហើយមុនទៅក៏ទៅជួយគ្នាៗទៅឆាប់ហើយ ប៉ុននឹងទេ ហូបចុកតាមផ្ទះធ្វើស្រែក៏មិនកើត ស៊ីតាមគ្រួសារ រៀងៗខ្លួន ។ មិនថាស៊ីបាយរួម ហូបរួមអីទេ តាំងពី៧១ណានៅឯកជននៅឡើយទេ ។

ដានី ៖ នៅឯកជននៅឡើយទេ?

សារ៉ុន ៖ បាទ! លុយកាក់ក៏នៅចាយដែរ ។

ដានី ៖ ចុះកាលនឹងដូចថាយុវជន យុវនារីយើងត្រូវឲ្យពួកគាត់ធ្វើអីខ្លះទៅ ដូចថាយុវជនយុវនារីជទង់ៗប៉ុននឹងនេះ ប៉ុនៗអាអូន?

សារ៉ុន ៖ បើខាងយោធា គេមានតែយាមល្បាត តាមវិពួកកុម្ម៉ង់ដូរ ពួកអីចុះពីយន្តហោះវាទម្លាក់ឆ័ត្រ ពួកយុវជនភារកិច្ចមានតែទាហាន ពួកនៅមន្ទីរអីម្នាក់ពីរនាក់ គ្រាន់តែថាការពារមន្ទីរដាំផ្ទះអីតិចតួចទៅ ។ ព្រោះខាងកងទ័ពទៅគេយាមល្បាត ទៅឃើញត្រង់ណាប្រមូល

ចុះទៅក៏យើងធ្វើការព័ទ្ធទៅ គេយកអាហារកង់ទ័ពមកជួយទៅវ៉ៃទៅ វ៉ៃកើតក៏ឈ្នះទៅ វ៉ៃមិនកើតក៏ចាញ់គេទៅ ។ ទៅកើតក៏បានសម្ភារៈក៏ ។ និយាយពួកនឹង បើពួកចុះពីភូមិអណ្ដូងមិនសូវតយើងប៉ុន្មានទេ ។

ដានី ៖ អត់សូវទេ?

សារ៉ុន ៖ អឺ! ដាក់តែម៉ាប្រាវរត់អស់ចោលអីវ៉ាន់ ។

ដានី ៖ អាហាររត់?

សារ៉ុន ៖ រត់ពួកវាអត់សំខាន់ទេ ពួកនឹង ។ ពួកនេះវាវ៉ៃបុកមក (ស្ដាប់មិនបាន) អានឹងខ្លាំងដែរ ។

ដានី ៖ ពួកណា?

សារ៉ុន ៖ ពួកអាមេរិចនឹង ។

ដានី ៖ ពួកអាមេរិចនឹង?

សារ៉ុន ៖ បាទ! វាបុកមកវាយកតែអាហារមកពីវៀតណាមខាងត្បូង បុកមកវ៉ៃឈ្នះចូល បុកមកពេជ្រចិន្ដានោះម៉ាខ្សែ បុកមកពីខាងខេត្តនោះម៉ាខ្សែ បុកមកពីខាងកែវសីម៉ានោះម៉ាខ្សែមកដើង អានឹងរថក្រោះអន្ដរាគមន៍ ខាងលើយន្ដហោះ ។ អូ! វ៉ៃខ្លាំងមែនទែនពីជំនាន់នឹង ធ្វើយោធា សហការជាមួយបងប្អូនវៀតណាមនឹង ព្រោះកងពួកខ្ញុំនឹងវ៉ៃខាងក្រោយទប់ ហើយខាងយួននឹងគេវ៉ៃទប់ខាងមុខ ហើយខ្ញុំវ៉ៃស្កាត់ខាងក្រោយខ្លាចគេយកកម្លាំងមកជួយ ។ វ៉ៃៗខ្លាំងមែនទែន វ៉ៃតាំងយប់វ៉ៃតាំងថ្ងៃហើយ ។ វ៉ៃនឹងយប់ៗវាទម្លាក់អាសត្វធ្វើភ្លើង ភ្លើងដូចភ្លើងអគ្គិសនីយើងប្រៀបចឹង ឃើញប្រៀបអស់ហើយវាបាញ់មកទៀត ។ អស់ហើយវាបាញ់មកទៀត ភ្លឹតជាប់ចឹង ។

ដានី ៖ ចុះអ៊ំកាលពីយើងនៅតាមមូលដ្ឋាន តាមភូមិអីចឹង អ៊ំដែលធ្លាប់មកប្រជុំយកផែនការណ៍អីពីមជ្ឈិមដែរអត់?

សារ៉ុន ៖ អត់ទេ មានទៅប្រជុំ នៅត្រឹមតំបន់ ។

ដានី ៖ ប្រជុំតែត្រឹមតំបន់ទេ?

សារ៉ុន ៖ បាទ!

ដានី ៖ អត់ដែលមកប្រជុំ ជាមួយតាៗនៅ?

សារ៉ុន ៖ អត់ទេ ប្រជុំនៅក្នុងតំបន់ ។

ដានី ៖ ចុះអ៊ំដល់ពេលបែកភ្នំពេញឆ្នាំ៧៥ហើយ ពេលនឹងយើងទទួលជ័យជំនះហើយ?

សារ៉ុន ៖ អឺ!

ដានី ៖ ពេលដែលយើងទទួលជ័យជំនះហើយ ខាងនេះដូចថាកម្មាភិបាលដែលយើងទទួលតាមស្រុក តាមតំបន់នេះ មានការប្រែប្រួលមានផ្លាស់ប្តូរ?

សារ៉ុន ៖ ៧៥ នៅមិនទាន់មានផ្លាស់ប្តូរទេ នៅដដែល ។

ដានី ៖ ប្រធានដែលតែងតាំងពី៧១នឹងនៅទាំងអស់?

សារ៉ុន ៖ បាទ! នៅទាំងអស់ ។

ដានី ៖ គណៈតំបន់ក៏អត់មានការផ្លាស់ប្តូរដែរ?

សារ៉ុន ៖ អត់ទេ ។

ដានី ៖ ចុះខាងលើ ខាងតា១ ខាងកងទ័ពអីគេមានទៅខាងនឹងដែរអត់?

សារ៉ុន ៖ ៩១ កងពល ។

ដានី ៖ ទៅម៉ាកងពល?

សារ៉ុន ៖ ទៅម៉ាកងពល អាររំដោះភ្នំពេញហើយ ទៅម៉ាកងពល គេហៅថាកងពល៩២០ ។

ដានី ៖ កងពល៩២០ទៅ?

សារ៉ុន ៖ បាទ! កងពលធំរបស់គេទាហានគេច្រើន ដឹកជួយការពារតាមព្រំដែន ។ ច្រើនដែរកងពលគេនឹង ទាហានប្រហែលជា៣០០០-៤០០០ មើលទៅទាហានគេ ។

ដានី ៖ គេទៅឈរនៅណាទៅ កងពល?

សារ៉ុន ៖ គេឈរនៅទន្លេ ។

ដានី ៖ ទន្លេណា?

សារ៉ុន ៖ ទន្លេស្រែពក នៅភូមចាស់ ភូមិខ្ញុំហើយនៅកោះម៉ាយើល ។

ដានី ៖ នៅកោះម៉ាយើលនឹង?

សារ៉ុន ៖ បាទ! គេទៅធ្វើមន្ទីរកងពលនៅនឹង ។ ក្រោយមកគេទៅធ្វើនៅខាងនេះវិញ ខាងស្រុកច្បារនេះ តាំងពីមាត់ច្បារនឹង នៅជិតខាងតំបន់នឹងមានបញ្ហាអី ពិភាក្សាគ្នាលឿន ។

ដានី ៖ ហើយចុះប៉ុន្តែកងពលគេដាក់ពង្រាយតាមស្រុកដែរ?

សារ៉ុន ៖ ពង្រាយគ្រប់ស្រុក ។

ដានី ៖ ម៉ាស្រុកពេជ្រចិន្តារបស់លោកអ៊ំមានខាងកងពល៩២០នៅដែរ?

សារ៉ុន ៖ បាទ! គេដាក់ស្រុកមួយៗគេដាក់មួយវរសេនាធំ កាលមុននេះ ឥឡូវនេះគេហៅថាកងពលតូច ពីមុនគេហៅវរសេនាធំ ។

ដានី ៖ ដាក់ម៉ាវរសេនាធំ?

សារ៉ុន ៖ បាទ!

ដានី ៖ ស្រុកកោះញ៉ែកម៉ាវរសេនាធំទៅ, ស្រុកពេជ្រចិន្តាម៉ាវរសេនាធំទៅ?

សារ៉ុន ៖ បាទ! គ្រប់ស្រុក និយាយរួមគ្រប់ស្រុក រាយតាមព្រំដែននឹងម៉ង ។

ដានី ៖ ដល់ពេលកងទ័ពស្រុកមានអត់ ពេលនឹងពេល៧៥ហើយ?

សារ៉ុន ៖ មាន នៅមានដដែល ។

ដានី ៖ មានប៉ុន្មាន?

សារ៉ុន ៖ តែ៣០នាក់នឹងដដែល ។

ដានី ៖ តែ៣០នាក់នឹង?

សារ៉ុន ៖ ហាំ! គាត់គេថាការពារជុំវិញស្រុកតែប៉ុននឹង ។

ដានី ៖ ចុះពេលបែកឆ្នាំ៧៥ហើយ មានប្រជាជនជម្លៀសមកពីឆ្ងាយៗមកនៅស្រុកអីទេ?

សារ៉ុន ៖ អត់ទេ! មុនដំបូងអាមេរិចវចូលមកនឹង វាភៀវទៅស្រុកយួនទាំងអស់ ព្រោះខ្ញុំទៅនឹងអត់ឃើញមានប្រជាជនទេ រលីងតែម្តង វាភៀវទៅស្រុកយួនអស់ ។

ដានី ៖ ឆ្នាំណានឹង?

សារ៉ុន ៖ កាល៧០ ។

ដានី ៖ ឆ្នាំ៧០នឹង?

សារ៉ុន ៖ អឺ! អស់រលីងម៉ង ប្រជាជនតាមព្រំដែន អត់មានទេ ។ ហើយយើងទៅធ្វើការតាមព្រំដែននឹង ជួបគេមកដឹកអីវ៉ែអីវ៉ាន់គេ មកយកស្រូវអង្ករគេ ជួបម្នាក់ពីរនាក់ទៅ យើងសុំអំពាវនាវ ឥឡូវនេះកងរណសិរ្សរួបរួមជាតិ ថាឥឡូវយើងរំដោះខេត្តខ្លួនយើងអស់ហើយ សូមបងប្អូនមកចុះ អត់មានអីទេ ឲ្យតែមកទៅ ម្តងនេះគេក៏តៗគេពុនេះគេមកបណ្តើរៗមកពេញស្រុកដដែល ។ ពីមុនអាមេរិចចូលមក គេយកទៅទាំងអស់ គ្រាប់បែកភូមិខ្លះត្រូវអាគ្រាប់បែក៥២នឹង ស្លាប់អស់ម៉ាភូមិៗក៏មានដែរ ។ ទម្លាក់បេ៥២នឹង មកម្តង៣គ្រាប់ ទម្លាក់ទៅរហូតៗ៣គ្រឿង ឡប់ទៅវិញ៣គ្រឿងមកទៀត ទម្លាក់ទាំងយប់ទាំងថ្ងៃ អាបេ៥២ ។

ដានី ៖ ទម្លាក់តាមភូមិ?

សារ៉ុន ៖ ទម្លាក់តាមព្រំដែន វាត្រូវភូមិតាមព្រំដែន ស្លាប់គោក្របីក៏ស្លាប់មិនតិចទេ ។

ដានី ៖ គោក្របីស្លាប់ មនុស្សក៏ស្លាប់ដែរ?

សារ៉ុន ៖ អឺ! មនុស្សក៏ស្លាប់ដែរ ។

ដានី ៖	ពីឆ្នាំណាដល់ឆ្នាំណាដែរទម្លាក់គ្រាប់បែក?

សារ៉ុន ៖	ពី៧០មក តាំងពី៧៣ ៧៤មករហូតទល់តែយើងរំដោះភ្នំពេញនេះបានឈប់ទម្លាក់ នៅតែទម្លាក់ទៀត រំដោះភ្នំពេញហើយនៅតែទម្លាក់ទៀតតាមព្រំដែន ទម្លាក់រហូត ។

ដានី ៖	ប៉ុន្តែ អាមេរិចមកកៀរប្រជាជននៅតាមព្រំដែនអីទៅនឹងតាំងពីឆ្នាំ៧០?

សារ៉ុន ៖	ពីឆ្នាំ៧០ ។

ដានី ៖	៧០កៀរទៅ?

សារ៉ុន ៖	កៀរទៅអស់ម៉ាភូមិៗ ។

ដានី ៖	ចុះនៅពេជ្រចិន្តាកៀរទៅអស់ដែរអត់?

សារ៉ុន ៖	អស់ នៅប្រហែល២ភូមិ ។

ដានី ៖	សល់២ភូមិ?

សារ៉ុន ៖	បាទ! ភូមិក្រាំងទេស និងគេហៅភូមិចាក់យ៉ាន់ ។

ដានី ៖	ចាក់យ៉ាន់ និងក្រងទេស?

សារ៉ុន ៖	ពីរភូមិនឹងក៏នៅមិនគ្រប់ទៀត នៅប្រហែលជា៤-៥គ្រួសារដែរ ។

ដានី ៖	ចុះពេលដែលអ៊ំទៅគ្រប់គ្រងនៅមូលដ្ឋាននឹង មានប៉ុន្មាន តែពីរភូមិនឹង?

សារ៉ុន ៖	តែពីរភូមិនឹង ហើយយើងដើរធ្វើការតាមភូមិ ទៅជួបគេមក យកអីវ៉ែអីវ៉ាន់គេ យកស្រូវអង្ករ ពីព្រោះនៅនោះវាមានស្រូវណាហូប មានអង្ករណាហូប នៅត្រូតម្នាក់ពីរនាក់ទៅក៏ណែនាំគេធ្វើម៉េច ឥឡូវកងទ័ពរណសិរ្សយើងរំដោះខេត្តស្រុកយើងអស់ហើយឥឡូវនឹងសុំអំពាវនាវបងប្អូនប្រាប់គ ទៅឲ្យមកកាន់ស្រុកភូមិយើងចុះ ។ គេក៏មកជាបន្តបន្ទាប់ម្តងរយៈប្រហែលចុងខែឆ្នាំ៧១ ដើម៧២ទៅក៏ពេញភូមិវិញ ។

ដានី ៖	ដល់ពេល៧២ទៅពេញភូមិវិញ?

សារ៉ុន ៖	ពេញភូមិវិញ ។

ដានី ៖	មកអស់វិញចឹង?

សារ៉ុន ៖	អ្នកខ្លះអត់មក ។

ដានី ៖	អ្នកខ្លះអត់មក?

សារ៉ុន ៖	អឺ! អត់មកនឹងភាគតិចទេ ។

ដានី ៖	អត់មកភាគតិច?

សារ៉ុន ៖ បាទ! អ្នកមកភាគច្រើនៗ មកក៏យើង គេនៅតាមផ្ទះចាស់គេដដែល ផ្ទះស្រែចំការគេ របស់របរគេ យើងក៏មិនថែរក្សាទុកទេ មិនឲ្យកងទ័ពទៅធ្វើអានឹងប៉ះពាល់របស់របរគេទេ ស្រុកគោក្របីគេ វាប្រលែងចោលតាមស្រែតាមភ្លឺនឹង យើងក៏អត់មានឲ្យកងទ័ពយើងប៉ះពាល់អីទេ តាំងពីជ្រូក តាំងពីមាន់ៗ

ដានី ៖ ចឹងដល់ពេលឆ្នាំ៧២មក មានប្រជាជនមកវិញច្រើន?

សារ៉ុន ៖ បាទ!

ដានី ៖ មានប៉ុន្មានឃុំកាលនឹងកាលអ៊ំទៅគ្រប់គ្រង?

សារ៉ុន ៖ មើលឃុំក្រាំងទេស ឃុំប៉ូស្រោៗ

ដានី ៖ ឃុំប៉ូស្រោ?

សារ៉ុន ៖ ឃុំក្រាំងទេស អានឹងឃុំៗ

ដានី ៖ ឃុំក្រាំងទេស ឃុំប៉ូស្រោ ឃុំ?

សារ៉ុន ៖ ឃុំប៉ូស្រោ ឃុំទៅស្វាយ ឃុំកៅផ្ទៃ មាន៥ឃុំៗ

ដានី ៖ ឥឡូវបានតែ៤?

សារ៉ុន ៖ មើលក្រាំងទេស ប៉ូស្រោ ទៅស្វាយ កៅផ្ទៃ ពិបាកណាស់ធ្វើតាមពាក្យភាសាបងប្អូនៗ

ដានី ៖ មាន៤ឃុំ?

សារ៉ុន ៖ បាទ! ៤ឃុំៗ

ដានី ៖ ហើយប្រជាជនទាំងអស់មានប៉ុន្មានទៅ សរុប?

សារ៉ុន ៖ អឺ!ចាំអត់បានទេ ពីព្រោះវារត់ទៅអាមេរិចវាទៅកៀរទៅវៀតណាមខ្លះ វានៅសល់ដល់មកដល់ស្រុកទេសវិញដូចជា៣ពាន់ជាង ៣៦០០-៣៧០០ៗ

ដានី ៖ ហើយដល់ពេលយើងបែកភ្នំពេញឆ្នាំ៧៥នេះ មានប្រជាជនមកពីណាគេ ជម្លៀសឲ្យមកនៅនឹងដែរ?

សារ៉ុន ៖ អត់ទេ នៅតែប្រជាជនចាស់ដដែលៗ

ដានី ៖ ចុះនៅស្រុកផ្សេងៗមានប្រជាជនជម្លៀសមកនៅអត់?

សារ៉ុន ៖ អត់ទេ ប្រជាជនចាស់ តាំងពីបូរាណ(ស្តាប់មិនបាន)នៅ អាមេរិចវាកៀរទៅទាំងអស់ៗ ដល់យើងអំពាវនាវទៅជួបម្នាក់ពីរនាក់គេមកយកស្រូវយកអង្ករទៅ គេចេះតែទៅមកៗបណ្តើរចឹងៗ

ដានី ៖ ចុះប្រជាជនមុនដែលរស់នៅកន្លែងទីរួមខេត្តមណ្ឌលគិរី ដល់ពេលឆ្នាំ៧៥ គេជម្លៀសទៅណាទៅ?

សារ៉ុន ៖ អត់បានជម្លៀសទេ តាំងពីបែកមណ្ឌលគិរីទៅ វាថាគ្រាប់បែកនោះ ក៏រត់ទៅតាមជនបទទៅ ទម្លាក់គ្រាប់បែកមែនទែនណា ។

ដានី ៖ ទម្លាក់គ្រាប់បែកខ្លាំង?

សារ៉ុន ៖ បាទ!

ដានី ៖ ចឹងដល់ពេលទម្លាក់គ្រាប់បែកខ្លាំង ប្រជាជននៅខេត្តមណ្ឌលគិរីក៏នាំគ្នាទៅនៅតាមស្រុក?

សារ៉ុន ៖ អត់មានទេ មានតែខាងរដ្ឋការទេ ប្រជាជនមានអ្នកធ្វើការតិចតួច គេទៅភូមិទៅស្រុកគេ មានខាងរដ្ឋការ មានខាងទាហាន ។ គេនៅនឹងវាអត់មានដីស្រែដីចំការ ពីដើមមានតែពួកលក់ដូរតិចតួច ។ ដល់យើងរំដោះខេត្តទៅ អាមេរិចទម្លាក់គ្រាប់បែកទៅ គេក៏ទៅនៅតាមស្រុកតាមព្រៃភូមិចាស់គេវិញ ។

ដានី ៖ ចុះដល់ពេលយើងវៃភ្នំពេញឆ្នាំ៧៥ យើងចាប់ផ្ដើមរៀបចំយ៉ាងម៉េចទៀត?

សារ៉ុន ៖ ហ្នឹង៧៥ នៅមិនទាន់ចាត់តាំងសហករណ៍អីទេ នៅតែក្រុមសាមគ្គីដដែល ៧៥-៧៦នេះ គេរៀបចំសហករណ៍ស៊ីបាយរួម សម្ភារៈដាក់រួម ។

ដានី ៖ ឆ្នាំណា?

សារ៉ុន ៖ ៧៥-៧៦ហើយ ។

ដានី ៖ ៧៦?

សារ៉ុន ៖ បាទ!

ដានី ៖ ដល់ពេល៧៦យើងចាប់ផ្ដើមរៀបចំសហករណ៍សម្ភារៈអីដាក់រួម?

សារ៉ុន ៖ បាទ! ដាក់រួមដូចជាគោក្របីណា ។ ដាក់រួមមែន ប៉ុន្តែម្ចាស់គេៗនៅថែរបស់គេរៀងៗខ្លួនចឹងណា ។

ដានី ៖ ម្ចាស់គេមកថែរៀងខ្លួនៗទៅ?

សារ៉ុន ៖ អឺ! រៀងៗខ្លួនទៅ ។

ដានី ៖ ប៉ុន្តែដល់ពេលយើងរៀបចំសហករណ៍រៀបចំដាក់រួមនឹង អ៊ំទទួលផែនការមកពីខាងណា?

សារ៉ុន ៖ ពីតំបន់ដដែល ។

ដានី ៖ អ្នកណាគេអ្នកប្រាប់នឹង?

សារ៉ុន ៖ តា ឡាំង ដដែល ។

ដានី ៖ តា ឡាំង?

សារ៉ុន ៖ បាទ!

ដានី ៖ គាត់ប្រាប់ថាម៉េច?

សារ៉ុន ៖ មានអីតាមផែនការរដ្ឋាភិបាល គាត់យើងត្រូវរៀបចំសហករណ៍ បានថានយោបាយដាក់រួមចឹង បានយើងកសាងយើងទៅវាលឿនដោះស្រាយជីវភាពអីនឹងណា ។

ដានី ៖ ប៉ុន្តែកាលនឹងគាត់មានប្រាប់ថា ការរៀបចំសហករណ៍ៗនឹង យើងត្រូវធ្វើអីខ្លះៗគាត់មាននិយាយ?

សារ៉ុន ៖ មានអី មានតែឲ្យធ្វើស្រែ ធ្វើទំនប់តែប៉ុននឹង ។

ដានី ៖ ធ្វើស្រែធ្វើទំនប់?

សារ៉ុន ៖ បាទ!

ដានី ៖ មានលើកទំនប់ ជីកប្រឡាយដែរ?

សារ៉ុន ៖ មាន ។

ដានី ៖ នៅស្រុកលោកអ៊ំជីកនៅកន្លែងណាទៅ?

សារ៉ុន ៖ មើល អូរបាក់ខាំម៉ាកន្លែងទៅ ទំនប់ធំមានម៉ាកន្លែងទេ ។

ដានី ៖ នៅអូរបាក់ខាំ?

សារ៉ុន ៖ បាទ! អូរបាក់ខាំ ក្រៅពីនឹងទំនប់តូចៗ ទប់ទឹកភ្លៀងដើម្បីស្រោចស្រង់យើងណា ។

ដានី ៖ ចុះចឹងដល់ពេលនៅសហករណ៍ចឹង យើងចាប់ផ្តើមបែងចែកកម្លាំងអីយ៉ាងម៉េចទៅ កម្លាំងតូចៗមីងៗ យុវជន យុវនារីអី?

សារ៉ុន ៖ អឺ! មានចែកអីទេ មានតែប្រធានសហករណ៍គេ អ្នកណាដូចថាខែភ្ជួរអ្នកណាប៉ុន្មាននាក់ដែលភ្ជួរ ។ ភ្ជួរអ្នកណាប៉ុន្មាននាក់ប្រុស ស្រីៗនឹងគេដកសំណាប ។ ពេលសន្ទូងនឹងយើងលើកភ្លឺៗនឹងលើកស្អាតមែនទែន ក្រឡាចក្រត្រង់ ឲ្យមានប្រឡាយ ឧទាហរណ៍ថាក្រឡាដៃយើងម៉ាគីឡូបួនជ្រុងចឹង គេថាឲ្យធ្វើប្រឡាយធំជុំវិញ វាមានដីស្រែតទៅទៀត ប៉ុនអាធំនឹងតមកខាងនេះទៀត ម៉ាគីឡូបួនជ្រុងទៀត ។ ម្តងនេះ៣ហិចតា គេរាប់ពីប្រឡាយធំ ១ហិចតា ២ហិចតា ៣ហិចតា ។ ១ហិចតា ២ហិចតា នេះមានប្រឡាយតូចមួយខាងៗកាត់ទទឹងកាត់បណ្តោយ ។ បើយើងចង់បាន ទឹកបញ្ចូលក្នុងស្រែយើងៗទប់ប្រឡាយធំនេះ វាហូរតាមប្រឡាយតូចនេះចូលស្រែ ។ អានឹងអត់ព្រួយពីរឿងរាំងស្ងួតទេ ឲ្យតែយើងមានទឹកទំនប់ មានអាងទឹក ។ ត្រង់ណាអត់ដល់នឹង ទឹកវាអត់ដល់ ដីវាខ្ពស់នឹងបូម

គេឲ្យម៉ាស៊ីនបូមទឹក ម៉ាស៊ីនបូមចូលកន្លែងណាដែលដីខ្ពស់នឹងគេបូម ប្រើម៉ាស៊ីនបូម ម៉ាស៊ីនយ៉ាម៉ាយើង។ ម៉ាសហករណ៍មួយៗនឹង ម៉ាស៊ីនគេឲ្យបូមទឹសម្រាប់ចូលស្រែនឹង ៣-៤គ្រឿងទេ។

ដានី ៖ ប៉ុន្តែគេបែងចែកកម្លាំងដូចថាកងចល័ត កងកុមារ កងពួៗកងមីងៗ យើងបែងចែកៗ ចឹងដែរអត់?

សារ៉ុន ៖ អឺ! អត់ទេ កងចល័តនឹងក្នុងស្រុកគេមានម៉ាកងទៅ គេសម្រាប់ត្រង់ណាមិនទាន់ហើយ សន្ទូង ព្រោះអានឹងទៅជួយ កងចល័តទៅជួយ ឬក៏ពេលណាកន្លែងណាវាភ្លៀងខ្លាំងទំនប់ វាបែកវាធ្លាយ កងចល័តនឹងគេទៅថែទាំ ម្តងបើវាបែកខ្លាំង ទឹកវាហូរខ្លាំង កងចល័តនឹង គេរាយការណ៍មក ប្រធានឃុំគេ ប្រធានសហករណ៍នឹង ដូចថាប្រធានឃុំនឹង យកកម្លាំង ទៅជួយទប់ទឹកនឹង។ កងចល័តនឹង គេសម្រាប់តែចល័តតែប៉ុននឹងទេ កន្លែងណាអត់ទៅ រួច គេទៅជួយ ឬទំនប់ណាត្រង់ណាវាបែកគេទៅជួយ។

ដានី ៖ ចុះនៅស្រុករបស់អ៊ំគេមានបែងចែក ប្រជាជនមូលដ្ឋាន ប្រជាជន១៧មេសាអីដែរ អត់?

សារ៉ុន ៖ អត់មានទេ។

ដានី ៖ ម៉េចចឹង?

សារ៉ុន ៖ មានតែប្រជាជនតែមួយគត់។

ដានី ៖ មានតែប្រជាជនតែមួយគត់?

សារ៉ុន ៖ បាទ! អត់មាន១៧មេសា អត់មានថាបែងចែកថាប្រជាជន១៧មេសាអីអត់មានទេ ពី នោះមានដកមកប្រជាជន(ស្តាប់មិនបាន)អី ភូមិចាស់ គេនៅនឹង។ អត់មានបែងចែក ចឹងទេ។

ដានី ៖ ចុះប្រជាជន ដែលគាត់ធ្លាបទៅនៅវៀតណាមអី ប្រជាជនដែលអាមេរិចកាំងកៀរទៅ វៀតណាម ពេលគាត់មកវិញនោះ គេចាត់ទុកប្រជាជន??

សារ៉ុន ៖ ប្រជាជនភូមិដដែល។

ដានី ៖ ដដែល ដូចថាយើងអាចមានសមាសភាព ល្អ មិនល្អ មានអត់?

សារ៉ុន ៖ អត់ទេ អត់បែងចែកទេ។

ដានី ៖ អត់បែងចែកទេ?

សារ៉ុន ៖ បាទ! ចេះរួមរស់នៅក្នុងភូមិគេ មេភូមិមេឃុំគេ ផ្ទះគេរៀបរយចាត់ចែងអប់រំរៀនសូត្រ

ដានី ៖ ចុះនៅក្នុងភូមិរបស់អ៊ំ មានដូចថាប្រជាជនដែលជាសមាសភាពដូចជា សេ.អ៊ី.អា. ដូចជាកាហ្សេបេរបស់សូវៀត ឬក៏មានដែលជាជាតិដែលចូលដៃចូលជើង ជាមួយវៀតណាមអី?

សារ៉ុន ៖ អត់មានទេ ។ អត់ឃើញមានទេ ។

ដានី ៖ អត់មាន?

សារ៉ុន ៖ បាទ! អត់មានទេ ។ យើងមិនបានបែងចែកចឹង ខ្ញុំទៅដល់ខាងលើគេអ្នកណែនាំ ខ្ញុំអត់មានបែងចែកទេ ឲ្យតែរួមរស់នៅក្នុងជាតិយើង សង្គមជាតិយើង គឺជាអ្នកល្អទាំងអស់ ។

ដានី ៖ ចុះអ្នកដែលធ្វើការនៅក្នុងស្រុកយើង ដែលធ្វើការរតាមសហករណ៍ ដែលគាត់ដូចថា ធ្វើការមិនសូវល្អ ដែលគាត់ធ្វើឲ្យខូចខាតរបស់រួមអី យើងមានចាត់ទុកគាត់ថាជា?

សារ៉ុន ៖ អត់ទេ អត់បានចាត់ទុកទេ មានតែអប់រំណែនាំ ។

ដានី ៖ អប់រំណែនាំ?

សារ៉ុន ៖ បាទ! ណែនាំធ្វើយ៉ាងម៉េច យើងចេះសន្សំរបស់របរប្រើប្រាស់ យើងចេញសង្គ្រាមនេះ យើងក្រលំបាកណាស់ ។

ដានី ៖ ចុះមានមន្ទីរអប់រំ កែប្រែ មន្ទីរលុតដំអីដែរ?

សារ៉ុន ៖ អត់ទេ អត់មាន ។

ដានី ៖ ចុះតំបន់មានអត់?

សារ៉ុន ៖ តំបន់មាន ។

ដានី ៖ គេហៅអីគេនឹង?

សារ៉ុន ៖ គេហៅអីហៅសន្តិសុខ ។

ដានី ៖ ហៅមន្ទីរសន្តិសុខ ឬក៏ហៅមន្ទីរ?

សារ៉ុន ៖ ហៅត្រឹមមន្ទីរកែប្រែ ។

ដានី ៖ មន្ទីរកែប្រែតំបន់?

សារ៉ុន ៖ បាទ!

ដានី ៖ អានឹងនៅកន្លែងណាមន្ទីរកែប្រែ?

សារ៉ុន ៖ នៅកន្លែងតំបន់?

ដានី ៖ តំបន់នៅណា មន្ទីរតំបន់?

សារ៉ុន ៖ គេដាក់នៅភ្នំក្រោល នៅស្រុកកោះញ៉ែក ។

ដានី ៖ នៅភ្នំក្រោល ស្រុកកោះញ៉ែក?

សារ៉ុន ៖ បាទ!

ដានី ៖ ពីណាគេគាត់ទទួលខាងមន្ទីរកែប្រែ?

សារ៉ុន ៖ អឺ! សុខ គា ។

ដានី ៖ សុខ គា ត្រូវជាបងប្អូនអីដែរ?

សារ៉ុន ៖ អត់ទេ រៀងឆ្ងាយដែរ ។

ដានី ៖ គាត់ជនជាតិអីដែរ សុខ គា?

សារ៉ុន ៖ អឺ! ខ្មែរ-ចារាយ ឪពុកគាត់ខ្មែរៗកម្ពុជាក្រោម ម៉ែគាត់ចារាយ ។

ដានី ៖ មិនមែនគាត់ជាប់បងប្អូន ត្រូវជាប្អូនថ្លៃអី?

សារ៉ុន ៖ អត់ទេ ។

ដានី ៖ ដល់ពេលយើងធ្វើការដូចថានៅសហករណ៍អីនឹង យើងប្រជាជនគាត់បានហូបគ្រប់គ្រាន់ដែរអត់ ដូចថាបានហូបបាយហូបអី?

សារ៉ុន ៖ បើនិយាយរួមខេត្តមណ្ឌលគិរី ការហូបសល់ ។

ដានី ៖ ហូបសល់ទៀត?

សារ៉ុន ៖ អឺ! ហូប៣ពេល ម៉ាថ្ងៃគេកំណត់ឲ្យហូប៣ពេល ស្រូវអង្ករម៉ាឆ្នាំៗ ជូនទៅខាងលើ គេថាយកគ្រប់សហករណ៍ជូនទៅគេហៅដោះដូរសម្ភារៈ មកចែកជូនសហករណ៍វិញ (ស្តាប់មិនបាន)អង្ករ ពីព្រោះម៉ាស៊ីនអង្ករម៉ាស៊ីនកិនស្រូវ ម៉ាស្រុកដូចជាមានឲ្យ២គ្រប់នៅក្នុងសហករណ៍នឹង គេកិនឲ្យស្មើៗគ្នា មានគណកម្មការគេចែកចឹង ១៥ថ្ងៃគេចែកម្តង ។ ក្មេងក្បាំងអីរបបស្មើគ្នា អត់មានអត់បាយទេ មណ្ឌលគិរីណា ។

ដានី ៖ អត់ទេ?

សារ៉ុន ៖ អត់ទេ ។

ដានី ៖ ចុះកាលនឹង ពេលដែលយើងនៅស្រុក ប្រជុំនៅតំបន់អី កម្មបទ គេមានដាក់ផែនការថាយើងត្រូវធ្វើស្រែម៉ាហិចតាបានប៉ុន្មានតោន ហើយយើងត្រូវជូនទៅខាងអង្គការប៉ុន្មានគេមានដាក់មុខការចឹងដែរ?

សារ៉ុន ៖ គេកំណត់ថាម៉ាហិចតា គេកំណត់ថាម្នាក់ធ្វើយ៉ាងម៉េចឲ្យបានម៉ាហិចតា បើ៣ពាន់នាក់ ៣០០០ហិចតាដែរ គេលើកដីបូង ។ បើគ្រប់ហើយ លើកក្រោយទេ បើយើងនៅមានដីមានធ្លីពង្រីកទៀត យើងពង្រីកទៀត ។ បើស្រូវអង្ករ យើងជូនទៅខាងលើគេថា បាន

សហករណ៍ណាជូនប៉ុន្មានៗ ធ្វើការដោះដូរបានសម្ភារៈមែន ធ្វើជូនមកមែន រឿងខោអាវ ស្បៀកពាក់អត់ខ្វះ ប្រជាពលរដ្ឋអត់មានកន្លែងដាក់ផង ខោអាវ មុង ភួយ ស្បែកជើង អំបិល ប៊ីចេង ស្បែកអីៗអត់មានខ្វះទេ សហករណ៍នីមួយៗនឹង គេឲ្យម៉ាស៊ីនដេរនឹង ៣០គ្រឿងសម្រាប់ដេរ គេច្រើនឲ្យតែក្រណាត់ៗ

ដានី : គេឲ្យសហករណ៍មួយៗមានម៉ាស៊ីនដេរ៣០គ្រឿង?

សារ៉ុន : បាទ!

ដានី : ហើយគេចែកក្រណាត់ឲ្យទៀត?

សារ៉ុន : ចែកក្រណាត់ឲ្យទៀតៗ

ដានី : ឲ្យយើងដេរខោអាវ សំលៀកបំពាក់ចែកប្រជាជន?

សារ៉ុន : ចែកប្រជាជន ម្នាក់គេកំណត់ថាឲ្យ៣កំប្លេ៉រ បើរបស់ដូចជាគេថារបស់ជ័យភ័ណ្ឌអានឹងអត់កំណត់ មកដល់ស្ថានណាចែកស្ថាននឹង ឲ្យតែឡានខាងគេដឹកជញ្ជូនមកដល់ចែក អំបិលអត់ខ្វះៗ

ដានី : អំបិលអត់ខ្វះ ប៊ីចេងអត់ខ្វះ?

សារ៉ុន : អឺ! ប៊ីចេងអត់ខ្វះ អំបិលនឹងឲ្យគោក្របីស៊ីទៀតៗ

ដានី : ចឹងខោអាវអំបិលអី ប៊ីចេងអត់ខ្វះ?

សារ៉ុន : អត់ខ្វះទេៗ

ដានី : ចុះប្រហុក ផ្អក?

សារ៉ុន : ប្រហុកនឹងយើងរកខ្លួនយើងៗ

ដានី : រកខ្លួនយើងៗធ្វើខ្លួនយើង?

សារ៉ុន : យើងធ្វើខ្លួនយើងៗ

ដានី : ចុះម្ហូបសំបូរដែរ?

សារ៉ុន : ម្ហូបអានឹងគេចាត់តាំងតាមសហករណ៍គេ ចាត់តាំងក្រុមទៅរកបរបាញ់ ចាត់តាំងក្រុមដាក់ម៉ងៗអួសអួនអីដាក់ បានត្រីមកគេប្រគល់ឲ្យនឹងអ្នកចុងភៅសហករណ៍នឹងគេកាន់កាប់ធ្វើសម្លប៉ុន្មានមុខ អានឹងស្រេចតែគេគណកម្មការគេអ្នកគេអ្នកទៅរៀបរកៗ អត់ខ្វះទេរឿងម្ហូបៗ

ដានី : ចុះម្ហូបយើងហូបៗ បើបាយយើងហូប៣ពេល?

សារ៉ុន : ៣ពេលៗ

ដានី ៖ ព្រឹក ថ្ងៃត្រង់ និងល្ងាច?

សារ៉ុន ៖ ម៉ោង៧នឹង ហូបម៉ាសារ ។

ដានី ៖ ហូបអីគេ?

សារ៉ុន ៖ អានឹងហូបបបរ ។

ដានី ៖ ហើយដល់ពេលថ្ងៃ?

សារ៉ុន ៖ ថ្ងៃត្រង់ហូបបាយ ល្ងាចហូបបាយ ។

ដានី ៖ យើងហូបម៉ាឆ្អែត ឬក៏យើងមានរបប?

សារ៉ុន ៖ អត់មានរបប ។

ដានី ៖ អត់មានទេ?

សារ៉ុន ៖ បាទ! អត់មានទេ ហូបម៉ាឆ្អែត សល់ក៏ធ្វើហូបបាយកកទៀត ។

ដានី ៖ ចុះអ៊ីដល់ពេល កាលពីខាងតំបន់គេថា យើងម្នាក់ៗយើងត្រូវធ្វើម៉េចឲ្យបានម៉ាហិចតា ហើយបើមនុស្សពាពាន់នាក់ យើងត្រូវធ្វើឲ្យបាន៣ហិចតា?

សារ៉ុន ៖ បាទ! ៣០០០ហិចតាដែរ ។

ដានី ៖ ហើយក្នុងម៉ាហិចតា យើងត្រូវធ្វើឲ្យបានទិន្នផលស្រូវប៉ុន្មាន?

សារ៉ុន ៖ បើយើងធ្វើល្អ សំណាបល្អម៉ាហិចតា៣តោន ទៅ៤តោន ។

ដានី ៖ ប៉ុន្តែយើងធ្វើបានអត់?

សារ៉ុន ៖ យើងស្ទូងឲ្យល្អ យើងរាស់ឲ្យស្មើ ដីឲ្យស្មើ ទឹករត់ស្មើ កន្លែងណាអត់ល្អទេយើងបន្ថែមដាក់ជីធម្មជាតិៗយើងណា អាចម៍គោអាចក្របី កន្លែងណាល្អហើយ យើងមិនបាច់ដាក់ទេ ។

ដានី ៖ ប៉ុន្តែផលស្រូវដែលយើងជូនទៅខាងអង្គការ ទៅខាងតំបន់ប៉ុន្មានទៅ ស្រុក ដែលយើងសល់ពីហូប?

សារ៉ុន ៖ ម៉ាឆ្នាំអាចបាន ជូនកាលបាន៤តោន ៥តោន ១០តោនវាអត់ទៀងណា វាសល់ច្រើនយើងជូនច្រើនទៅ ។ ឃើញតែដាក់ដោតៗ ស្ទូងៗទៅ ។

ដានី ៖ ប៉ុន្តែយើងបើកបញ្ជូនទៅ យើងទុកសម្រាប់ហូបហើយ ឬអត់?

សារ៉ុន ៖ ឲ្យគ្រប់ គេគិតថាម្នាក់៣០ប៉ោត ទាំងក្មេង ឲ្យតែធ្លាក់ពីពោះ គិត៣០ប៉ោតស្មើ ។

ដានី ៖ ម៉ាឆ្នាំ?

សារ៉ុន ៖ ម៉ាឆ្នាំ ។

ដានី ៈ ទុក៣០ប៉ោត?

សារ៉ុន ៈ ៣០ប៉ោតក្នុងម្នាក់ វា៣០០គីឡូ៣០ប៉ោត ។

ដានី ៈ ទុកហូបចឹងម៉ង?

សារ៉ុន ៈ អឺ! ទុកហូបចឹង ។

ដានី ៈ ដល់ពេលនៅសល់ប៉ុន្មានយើងជូនទៅ?

សារ៉ុន ៈ បាទ! ហើយយើងត្រៀមបំរុងទៀត ត្រៀមបំរុងខ្វាចវាមានភ្លៀវមានអី ឬក៏មានអាសន្ន អីខ្វះខាត ត្រៀមបំរុងអាច៨-១០តោនទៀត ។

ដានី ៈ ចុះអ៊ីដល់ពេលស្រូវដែលសល់ យើងបញ្ជូនទៅខាងតំបន់ ឬបញ្ជូនមកខាងភ្នំពេញ?

សារ៉ុន ៈ បញ្ជូនទៅតំបន់ៗគេបញ្ជូនទៅភ្នំពេញ ដល់បានត្រឹមសម្ភារៈមក គេបញ្ជូនតាមរយៈតំបន់ គេក៏បញ្ជូនមកឲ្យយើងសហករណ៍ ។

ដានី ៈ ចុះពេលដែលគេបញ្ជូនទៅតំបន់ៗមានដែលបន្ទោសអ៊ីអី ថាបានតិចថាបានច្រើនអីក៏យ៉ាង ម៉េច បន្ទោស គេសរសេរម៉េចដែរ?

សារ៉ុន ៈ អត់ទេ អត់មានបន្ទោស អត់មានសរសើរទេ គ្រាន់តែថាយើងជូនទៅ គេក៏អ្នកគេទទួល សហករណ៍ណាទៅជូនទទួល បានសម្ភារៈម៉េចក៏គេចែកពួកយើង ។

ដានី ៈ ចុះអ៊ីកាលនឹងយើងធ្វើការជាមួយតំបន់ ជាមួយខាងកងពលគេទៅពីភ្នំពេញ ដែលអ៊ីមាន ប្រសាសន៍ថាកងពល៩២០ យើងធ្វើការជាមួយគេណាស់ ហើយក៏អត់ទេ?

សារ៉ុន ៈ អត់ទេ មានតែខាងតំបន់ទេគេធ្វើ ។

ដានី ៈ មានតែខាងតំបន់ទេគេធ្វើ?

សារ៉ុន ៈ បាទ! ខាងស្រុកអត់មានទេ ។

ដានី ៈ ខាងស្រុកអត់មានទេ?

សារ៉ុន ៈ បាទ! ច្រើនតែពេលមានដែរ គេខ្វះខាត(ស្តាប់មិនបាន) គេមកសុំ ។

ដានី ៈ ចុះអ៊ីក្រៅពីធ្វើស្រែលើកទំនប់ យើងមានធ្វើអីទៀត?

សារ៉ុន ៈ ចំការ ដាំបន្លែៗគ្រប់មុខ ដូចជាពោតជាដើម បន្លែគ្រប់មុខ កបម្ទេសអី អត់ខ្វះទេ គ្រឿងហូប ។

ដានី ៈ អត់ខ្វះទេ ដាំបន្លែ ដាំស្រូវអី?

សារ៉ុន ៈ បាទ! ស្រូវ កណ្តាប់ខ្វះដែរ ។ ថ្ងៃអាទិត្យសម្រាកអត់ឲ្យធ្វើការទេ ។

ដានី ៈ ថ្ងៃអាទិត្យសម្រាកអត់ឲ្យធ្វើការទេ?

សារ៉ុន ៖ អត់ទេ សម្រាកៗហើយមានខាងមន្ទីរគេធ្វើបង្អែមធ្វើអីហូប ប្រុសៗក៏ទៅរកត្រីរកអីមកហូប អត់ឲ្យធ្វើការទេថ្ងៃអាទិត្យ ។

ដានី ៖ គ្រប់ស្រុក?

សារ៉ុន ៖ គ្រប់ស្រុក ។

ដានី ៖ ធ្វើតែចឹង ហើយក៏តែស្រុករបស់អ៊ំបង្កើតខ្លួនឯង?

សារ៉ុន ៖ គ្រប់ស្រុកចឹងម៉ង ។

ដានី ៖ ខាងតំបន់គេប្រាប់មកឲ្យធ្វើចឹង ឬក៏ធ្វើខ្លួនឯង?

សារ៉ុន ៖ តំបន់គេប្រកាសចឹងម៉ង ថាទទួលកិច្ចការមកពីលើថ្ងៃអាទិត្យគេអត់ធ្វើម៉ង ការងារ លើកលែងតែទំនប់ដាច់អីនឹងណា ខ្លាចដាច់ធំទៅ យើងជួសជុលមិនបានត្រូវជួស ។ ថ្ងៃអាទិត្យវាមានត្រឹមមន្ទីរធ្វើបង្អែម ធ្វើអីហូប សម្រាកការងារទាំងអស់អត់បានធ្វើទេ ដើរលេងដើរអីទៅរកបរបាញ់សត្វអីធម្មតាទៅ មានគ្រប់ស្រុកគឺចឹងម៉ង ។

ដានី ៖ កាលនឹងអត់មានភ័យខ្លាចអី?

សារ៉ុន ៖ អត់ទេ ។

ដានី ៖ ចុះអ៊ំដល់ពេលឆ្នាំណាទៅ មានព្រឹត្តិការណ៍យើងបែកបាក់គ្នា មានគេហៅទៅភ្នំពេញ មានគេចាប់គេអីមានដែរអត់?

សារ៉ុន ៖ មានតាំងពី៧៧ ៧៨នេះ ។

ដានី ៖ ៧៧ ៧៨មានអីខ្លះទៅកើតបញ្ហាកើតឡើងអីខ្លះទៅ?

សារ៉ុន ៖ មានគេទៅហៅទៅបាត់ចឹង មិនដឹងថារឿងអីកើតអី ។

ដានី ៖ កាលឆ្នាំ៧៧គេហៅពីណាខ្លះទៅបាត់?

សារ៉ុន ៖ មើលហៅ តា ចាំ ហៅ តា ម៉ៃ ម្នាក់ ។

ដានី ៖ តា ចាំ តាណា?

សារ៉ុន ៖ តា ម៉ៃ ។

ដានី ៖ តា ចាំ, តា ម៉ៃ?

សារ៉ុន ៖ ពីណាទៀត ភ្លេចអស់ហើយ ខ្ញុំចាស់ហើយវាវង្វេង ។

ដានី ៖ ចុះខាង បើស្រុករបស់អ៊ំ៤នាក់នេះ គេអត់មានហៅទៅណាទេ?

សារ៉ុន ៖ អត់ទេ អត់មានហៅទៅណាទេ ។

ដានី ៖ ចុះខាងស្រុកកោះញ៉ែក មាន ស្វាយ រ៉ា កែម ចាន់ អីនឹងគេមានហៅទៅដែរអត់ទេ?

សារ៉ុន ៖ ហៅម្នាក់ ។

ដានី ៖ ហៅពីណា?

សារ៉ុន ៖ ហៅ ភ៊ា ។

ដានី ៖ ហើយខាងស្រុកច្បារមានហៅ ចាន់ ទៅមួយ ចុះ ហាន់?

សារ៉ុន ៖ អត់ទេ នៅទាំងអស់ ។

ដានី ៖ លក អីអត់មាន?

សារ៉ុន ៖ អត់ៗ ។

ដានី ៖ ហៅតែ ចាំ មួយទេ?

សារ៉ុន ៖ បាទ!

ដានី ៖ ហើយចុះស្រុកអូររាំងមានឈ្មោះ គី ឈ្មោះ ឃឿន?

សារ៉ុន ៖ អត់មានហៅម្នាក់ ។

ដានី ៖ អត់មានហៅទេ?

សារ៉ុន ៖ បាទ!

ដានី ៖ ចុះស្រុកកែវសីម៉ា មាន ខាំភួន, មាន ចាន់ដើ, មាន ខាំ?

សារ៉ុន ៖ ហៅតែ ខាំភួន ទេ ។ ក្រៅពីនឹងស្រុកនៅទាំងអស់ អត់មានអីទេ ។

ដានី ៖ ចុះខាងតំបន់គេហៅទៅ តំបន់វាមាន តា ឡាំង, តា ខាំភួន, តា ម៉ៃ, ?

សារ៉ុន ៖ មានហៅគាត់ពីរនាក់នឹង ។

ដានី ៖ ហៅពីណាខ្លះ?

សារ៉ុន ៖ ហៅ តា ឡាំង ហៅ ខាំភួន នឹង ។

ដានី ៖ ហៅ តា ឡាំង, តា ខាំភួន?

សារ៉ុន ៖ បាទ!

ដានី ៖ តា ម៉ៃ ដែរ?

សារ៉ុន ៖ តា ម៉ៃ ដែរ ។

ដានី ៖ ចឹងហៅទៅអស់រលីង?

សារ៉ុន ៖ បាទ!អស់ តា ម៉ៃ ហៅទៅមុនគេ ក្រោយមកហៅ ចាំ ក្រោយមកហៅ ខាំភួន ហើយ និង ឡាំង ។

ដានី ៖ កាលនឹងអ៊ំដឹងពីគោលការណ៍គេយ៉ាងម៉េចបានគេហៅទៅ?

សារ៉ុន ៖ អឺ! អត់ដឹងទេ ។

ដានី ៖ អត់ដឹង?

សារ៉ុន ៖ បាទ! ឮតែគេថាហៅទៅធ្វើការៗ ហៅទៅបាត់ៗ ។

ដានី ៖ ទៅបាត់អត់ឃើញមកវិញ?

សារ៉ុន ៖ អត់ឃើញមកវិញ ។

ដានី ៖ អត់ឃើញមកវិញ ចឹងយើងសង្ស័យថាយ៉ាងម៉េចទៅ?

សារ៉ុន ៖ សង្ស័យហើយណា យើងនៅក្រោយចេះតែភ័យហើយណា ម្ដងនេះភ័យហើយ ។

ដានី ៖ ម្ដងនេះភ័យលែងសប្បាយដូចមុន?

សារ៉ុន ៖ បាទ! ភ័យហើយហៅបាត់ៗចឹង ថាទៅធ្វើការៗ ម៉េចក៏បាត់ទៅចឹង ចេះតែសង្ស័យហើយ ។

ដានី ៖ ចុះអ៊ំមានដែលឮព័ត៌មានឮគេនិយាយថា ចុះ តា ខាំភួន តា ឡាំង អីនៅភ្នំពេញអីយ៉ាងម៉េចដែរ គាត់ស្លាប់ ឬក៏យ៉ាងម៉េច ឬក៏គេធ្វើអីគាត់មានដែលឮអត់?

សារ៉ុន ៖ អឺ! ឮដែរ ឮថាគេស្លាប់គ្នា ។

ដានី ៖ សម្លាប់គ្នា?

សារ៉ុន ៖ បាទ! តា ភួន, និង តា ឡាំង ឮគេដែលប្រាប់ខ្ញុំ ។

ដានី ៖ ពីណាគេអ្នកប្រាប់នឹង?

សារ៉ុន ៖ ជួន បងប្អូនថ្លៃគាត់ ។

ដានី ៖ ឈ្មោះអី?

សារ៉ុន ៖ ជួន ។

ដានី ៖ ឈ្មោះ ជួន អ្នកប្រាប់?

សារ៉ុន ៖ បាទ! មកប្រាប់ខ្ញុំនៅស្រុកពេជ្រចិន្ដា គេថា តា ឡាំង, តា ខាំភួន នឹងស្លាប់ហើយ ដឹងតែប៉ុននឹង ។

ដានី ៖ តា ឡាំង, តា ខាំភួន ស្លាប់ហើយ គាត់ថាមូលហេតុអីបានស្លាប់?

សារ៉ុន ៖ គេសម្លាប់គ្នា ។

ដានី ៖ តា ឡាំង, តា ខាំភួន នឹង សម្លាប់គ្នា?

សារ៉ុន ៖ បាទ!

ដានី ៖ ម៉េចបានគាត់សម្លាប់គ្នា?

សារ៉ុន ៖ មើលគេហៅទៅធ្វើការនឹង នៅមិនទាន់បានធ្វើការទេ តាមជនរាយការណ៍ ថានៅនឹងម្តងនេះថាដល់ម៉ោងហូបបាយទៅមិនឃើញចុះមកហូបបាយ ក្មេងៗនៅក្រោម ។ តាមគេប្រាប់ ខ្ញុំអត់ឃើញអីទេ ខ្ញុំនៅស្រុកនោះ ។ ឡើងទៅមើលឃើញមនុស្សនឹងស្លាប់ទាំងពីរ នៅលើផ្ទះជាន់ទី២ ។

ដានី ៖ ផ្ទះនៅណា?

សារ៉ុន ៖ នៅភ្នំពេញ ។

ដានី ៖ នៅភ្នំពេញម្តុំណា ដែលស្លាប់នឹង?

សារ៉ុន ៖ នៅជិតមុខវាំងនឹង ។

ដានី ៖ ជិតមុខវាំងនឹង?

សារ៉ុន ៖ អឺ! ទៅជិតទន្លេបួនមុខនឹង ។

ដានី ៖ ប៉ុន្តែគេអត់ឃើញគាត់សម្លាប់គ្នាឯងផ្ទាល់ភ្នែក ឃើញតែគាត់ស្លាប់ហើយទេ?

សារ៉ុន ៖ អត់ឃើញ ។

ដានី ៖ ប៉ុន្តែ តាពីរនាក់នឹងគាត់កាលនៅស្រុក គាត់ត្រូវគ្នា មានដែលឈ្លោះគ្នាដែរអត់?

សារ៉ុន ៖ អត់មានដែលឈ្លោះគ្នា បងប្អូនគេនឹងទៀតណា បងថ្លៃគាត់ទៀត ។

ដានី ៖ បងថ្លៃទៀត?

សារ៉ុន ៖ អឺ!

ដានី ៖ ពីណាបងថ្លៃពីណា?

សារ៉ុន ៖ ខាំភួន នោះបងថ្លៃ តាឡាំង ។

ដានី ៖ ប្រពន្ធ តា ឡាំង ត្រូវប្អូនស្រី តា ខាំភួន?

សារ៉ុន ៖ បាទ!

ដានី ៖ ហើយដល់ពេលទៅដល់ភ្នំពេញ ឮដំណឹងថាគាត់ឈ្លោះគ្នា វ៉ៃគ្នា សម្លាប់គ្នា?

សារ៉ុន ៖ អត់ឮថាឈ្លោះគ្នាអីទេ ឃើញតែស្លាប់គ្នា ។

ដានី ៖ ចុះ ជួន នឹងត្រូវជាម៉េច តា ឡាំង, តា ខាំភួន?

សារ៉ុន ៖ ប្អូន ។

ដានី ៖ ប្អូនតា?

សារ៉ុន ៖ ប្អូន តា ឡាំង ។

ដានី ៖ ប្អូន តា ឡាំង?

សារ៉ុន ៖ បាទ! បួនថ្ងៃ ។

ដានី ៖ បួនថ្ងៃ តា ឡាំង មកប្រាប់ថា តា ឡាំង និង តា ខាំភួន គាត់ឈ្មោះគ្នា?

សារ៉ុន ៖ អត់ទេ អត់ពូល្អិតប្រាប់ថាចឹងទេ ឃើញថាប្រាប់ថាស្លាប់ហើយ តែប៉ុននឹង ។

ដានី ៖ ប្រាប់ថាស្លាប់ហើយ?

សារ៉ុន ៖ បាទ! អត់ពូថាប្រាប់ថាមូលហេតុចេះចុះ ឈ្មោះគ្នា វ៉ៃគ្នាចេះចុះ អត់ពូទេ ពូតែប្រាប់ថា គាត់ស្លាប់ហើយ ។ គាត់មកប្រាប់ខ្ញុំ ថាមូលហេតុអីបានស្លាប់ចឹង ថាវ៉ៃ តា ខាំភួន វ៉ៃ តា ឡាំង ថាចេះរួចនឹង តា ភួន ក៏បាញ់ខ្លួនឯង ។ ខាំភួន បាញ់ខ្លួនឯងនឹង បៀមគ្រាប់ ចឹង ប្រាប់តែប៉ុននឹង ខ្ញុំអត់ដឹងដែរ ខ្ញុំនៅស្រុកនឹង ។

ដានី ៖ ចុះ ជួន គាត់ធ្វើអីគេ?

សារ៉ុន ៖ គាត់ប្រចាំនៅភ្នំពេញ- ក្រចេះ ។

ដានី ៖ ខាងអីប្រចាំនៅ?

សារ៉ុន ៖ គាត់ខាងទទួលសម្ភារៈខាងពាណិជ្ជ ។

ដានី ៖ ខាងពាណិជ្ជ?

សារ៉ុន ៖ ទទួលសម្ភារៈពីខាងលើមក ចែកចាយមកខាងតំបន់នឹង តែគាត់នឹងទៅទទួលនឹង ដឹកជញ្ជូន មកពីភ្នំពេញនឹងក៏គាត់នឹងឯង ។

ដានី ៖ ពីភ្នំពេញមកក្រចេះ?

សារ៉ុន ៖ បាទ!

ដានី ៖ មណ្ឌលគិរីដែរ?

សារ៉ុន ៖ បាទ! ហ្នឹងហើយដឹកមកដល់មណ្ឌលគិរីនឹង ។

ដានី ៖ គ្រាន់ដឹងចឹង ឆ្នាំណាដែល តា ខាំភួន, តា ឡាំង គាត់ទៅភ្នំពេញ ហើយស្លាប់នឹង ៧៧ ហើយក៏៧៨?

សារ៉ុន ៖ ៧៨ ។

ដានី ៖ ខែប៉ុន្មាន បានន័យថាខែប្រាំង ហើយក៏ខែវស្សា ពេលដែលគេហៅគាត់ទៅភ្នំពេញ?

សារ៉ុន ៖ ខែមើល ខែ១២នឹងឯង យើងប្រូតឆ្លងមិនទាន់ហើយ ។

ដានី ៖ ប្រូតស្រូវហើយ?

សារ៉ុន ៖ អត់ទេ នៅ ។

ដានី ៖ អត់ទាន់ប្រូតស្រូវទេ?

សារ៉ុន ៖ ច្រូតដែរ ប៉ុន្តែវានៅមិនទាន់ហើយ ។

ដានី ៖ ច្រូតស្រូវមិនទាន់ហើយ?

សារ៉ុន ៖ បាទ!

ដានី ៖ អានឹងចុងឆ្នាំ៧៧ ហើយក៏៧៨?

សារ៉ុន ៖ ៧៨ ។

ដានី ៖ បានន័យថាច្រូតស្រូវហើយឆ្នាំ៧៨ មិនវៀតណាមវ៉ៃចូល?

សារ៉ុន ៖ អត់ទេ ៧៩តើ វៀតណាមចូល ។

ដានី ៖ វៀតណាមវាដើមខែ៧៩?

សារ៉ុន ៖ បាទ! ដើមខែ៧៩ ថ្ងៃ១ ៧៩ ។

ដានី ៖ ចឹង តា ឡាំង, តា ខាំភួន, គាត់ទៅមុនប្រហែលប៉ុន្មាន រយៈពេលប៉ុន្មាន?

សារ៉ុន ៖ អត់ដឹងដែរ ។

ដានី ៖ អាចមុនដែលវៀតណាមវ៉ៃចូលប្រហែលប៉ុន្មានខែ?

សារ៉ុន ៖ មើល៧៨ មុនវៀតណាមចូលនឹងវា៣ខែ ។

ដានី ៖ មុន៣ខែទេ?

សារ៉ុន ៖ ៣ខែ មើល៧៨ ៧៩ៗ មើលខែ៨ ខែ៩ ខែ១០ ខែ១១ ខែ១នឹងវៀតណាមចូលពេញស្រុក ។

ដានី ៖ ចឹងគាត់ទៅនៅខែ៩?

សារ៉ុន ៖ ខែ៨ ។

ដានី ៖ ខែ៨ គាត់ទៅ?

សារ៉ុន ៖ បាទ! អូ! មិនខែ៨ទេ ខែអីយើងច្រូតស្រូវនឹង ខែ១២នឹងឯង ។

ដានី ៖ ខែ១២ ខែ១ ម៉ាខែនឹង?

សារ៉ុន ៖ អឺ! ខែ១២នឹង ខែ១២ ខែ១០អីនឹងឯង ព្រោះយើងច្រូតស្រូវវានៅមិនទាន់ហើយ ។

ដានី ៖ ចុះគណៈតំបន់ ទៅគេហៅពីភ្នំពេញទាំងអស់នឹង បានពីណាគ្រប់គ្រងជំនួសគាត់ទៅ?

សារ៉ុន ៖ អត់មានទេ កាលនឹង គាត់ឲ្យខាងលើនឹង ឲ្យខាងកងពល និងគ្រប់គ្រង និងប្អូនថ្លៃគាត់ឈ្មោះ ជួន នឹង ។

ដានី ៖ ចឹងដល់ពេលគេហៅទៅបាត់ទៅ ខាងលើឲ្យកងពលគ្រប់គ្រងវិញ?

សារ៉ុន ៖ បាទ!

ដានី ៖ ឲ្យពីណាគេ?

សារ៉ុន ៖ តា សាន ។

ដានី ៖ ឲ្យ តា សាន គ្រប់គ្រងជំនួស?

សារ៉ុន ៖ បាទ! គាត់គ្រាន់តែណែនាំ ជួន នឹង គាត់ណែនាំ តំបន់គាត់គ្រាន់ណែនាំពីលើមក ទទួល អី ការងារពីលើណា៎ គាត់ចាំតែណែនាំធ្វើចេះធ្វើចុះតែប៉ុននឹងទេ ។

ដានី ៖ ចឹងខាង តា សាន គាត់គ្រាន់តែណែនាំពីលើ ឲ្យ ជួន នឹងគ្រប់គ្រង ប៉ុន្តែ តា សាន គាត់ណែនាំពីលើ?

សារ៉ុន ៖ បាទ! ពីព្រោះគាត់កងពលធំ ប្រចាំនៅខេត្តនឹងហើយ គាត់អ្នកនាំ ។

ដានី ៖ ជួន គាត់នៅណាឥឡូវ?

សារ៉ុន ៖ ស្លាប់ហើយ ។

ដានី ៖ គាត់ស្លាប់ពីអន្កាល់?

សារ៉ុន ៖ ដឹង គេហៅទៅបាត់ទៅ ។

ដានី ៖ គេហៅពេលនឹងដែរ?

សារ៉ុន ៖ អត់ទេ ក្រោយៗទៀត ។

ដានី ៖ ក្រោយពេលណាទៅ?

សារ៉ុន ៖ អឺ! មិនដឹងពេលណាទេ អត់ចាំ ។

ដានី ៖ ពេលដែលយើងរត់យួនហើយ ឬក៏ពេលនៅ?

សារ៉ុន ៖ នៅមិនទាន់រត់យួនទេ ។

ដានី ៖ គេហៅទៅម៉ាសារទៀតចឹង?

សារ៉ុន ៖ ហៅម៉ាសារទៀត ក៏បាត់ទៅ ។

ដានី ៖ ដោយសារជាប់ពាក់ព័ន្ធជាមួយ តា ឡាំង និង ខាំភួន នឹងយ៉ាងម៉េច?

សារ៉ុន ៖ ដឹងគេ យើងអត់ដឹងដែរ ។

ដានី ៖ ដល់ពេលគេហៅ ជួន ទៅទៀត ពីណាទៀត អ្នកទទួលនៅតំបន់?

សារ៉ុន ៖ មានអីគេឲ្យខ្ញុំៗមិនបានទទួល ខ្ញុំគ្រាន់តែមកម្តងៗឃើញចឹង ។

ដានី ៖ ដល់ពេលចឹងទៅ អស់ទៅ គេប្រាប់ឲ្យអ៊ំឲ្យមកទទួលតំបន់?

សារ៉ុន ៖ បាទ! ទទួលខ្ញុំក៏មកម្តងៗទៅ ម៉ាអាទិត្យខ្ញុំមកម៉ាថ្ងៃអីទៅ ។

ដានី ៖ បានប៉ុន្មានខែ ដែលអ៊ំបានមកនឹង?

សារ៉ុន ៖ មើលខែ៨ អឺ! ខែ១០ខ្ញុំមក ខែ១១ ខែ១២ ខែ១ វៀតណាមចូលស្រុករត់ចូលព្រៃអស់ ។

ដានី ៖ ចឹងគេចាប់ផ្ដើមប្រគល់តួនាទីឲ្យអ៊ំជាគណៈតំបន់នឹងពីខែ១០?

សារ៉ុន ៖ ពីខែ ចុងខែ៩ ដើមខែ ។

ដានី ៖ កាលនឹងអ៊ំទៅទទួលតំបន់ទៅប៉ុន្មាននាក់?

សារ៉ុន ៖ តែម្នាក់ខ្ញុំ ។

ដានី ៖ អត់មាន ចុះអ្នករងអី?

សារ៉ុន ៖ អត់មានទេ មានតែខ្ញុំ មានខាងលើនេះ ខាងតំបន់ ហើយបងគាត់បង លក ម្នាក់តែ ប៉ុននឹង ។

ដានី ៖ ឈ្មោះ លក ម្នាក់ទៀត?

សារ៉ុន ៖ បាទ! បងគាត់ ។

ដានី ៖ បងពីណាគេ?

សារ៉ុន ៖ បង តា ឡាំង ។

ដានី ៖ លក នឹង ត្រូវជាបងរបស់ តា ឡាំង?

សារ៉ុន ៖ បាទ!

ដានី ៖ គណៈស្រុកនៅជាមួយ តា ចាំ នៅច្បារនឹង?

សារ៉ុន ៖ ហ្នឹងហើយ ។

ដានី ៖ ចុះខាងអ៊ំ អន ស៊ី អីគាត់អត់មានទទួល?

សារ៉ុន ៖ អត់ទេ គាត់នៅស្រុក ។

ដានី ៖ នៅស្រុកណាវិញ?

សារ៉ុន ៖ កាលមុនគាត់នៅស្រុកអូររាំង ។

ដានី ៖ ក្រែងអូររាំង តា គី, តា យឿន?

សារ៉ុន ៖ អូ! មានគាត់ម្នាក់ ខ្ញុំភ្លេចហើយ ។

ដានី ៖ ចឹងនៅអូររាំងនឹង ចឹង គី, យឿន ហើយនឹង អ៊ំ អន ស៊ី?

សារ៉ុន ៖ បាទ! ហ្នឹងហើយ ។

ដានី ៖ ប៉ុន្តែ អន ស៊ី គាត់មិនមែនគណៈស្រុកគេ?

សារ៉ុន ៖ គាត់គណៈស្រុក ។

ដានី ៖ ពីណាធំជាងគេ ក្នុង?

សារ៉ុន ៖ តា គី នឹង ។

ដានី ៖ តា គី ធំ?

សារ៉ុន ៖ បាទ! ប្រធាន ។

ដានី ៖ តា គី ហើយរងគាត់មាន តា អន ស៊ុ ហើយនឹង យឿន?

សារ៉ុន ៖ យឿន ។

ដានី ៖ ហើយចុះមួយទៀត កាស៊ី?

សារ៉ុន ៖ កាស៊ី នៅខាងកែវសីម៉ា ។

ដានី ៖ គាត់នៅកែវសីម៉ា ក្រែង តា ខាំភួន គាត់?

សារ៉ុន ៖ ប្រធាន តាស៊ី អីនឹងរង ចាន់ដើរ អីរងទាំងអស់ ។

ដានី ៖ កាស៊ី នឹងរង?

សារ៉ុន ៖ បាទ!

ដានី ៖ ចឹងអ៊ីដល់ពេល តា ឡាំង, តា ខាំភួន បាត់ទៅ ។ ដួន គាត់មកប្រហែលប៉ុន្មាន បានគេប្រគល់តួនាទីឲ្យអ៊ី?

សារ៉ុន ៖ មើលបើនៅជាមួយខ្ញុំ មុនដំបូងខ្ញុំអត់មកណា ។

ដានី ៖ ដំបូងគេតែងតាំងឲ្យអ៊ីដែរ តែអ៊ីអត់មក?

សារ៉ុន ៖ ខ្ញុំអត់ព្រម ។

ដានី ៖ អត់ព្រម?

សារ៉ុន ៖ បាទ! ខ្ញុំដដែក មើលខ្ញុំថាខ្ញុំអត់ចេះធ្វើការងារទេ ខ្ញុំវប្បធម៌ក៏ទាប ខ្ញុំអត់ធ្វើទេ គាត់ថាចេះតែធ្វើទៅៗ ។ ខ្ញុំថាខ្ញុំអត់ធ្វើទេ ទៅក៏មានលួចប្រជុំស្រុក សន្និបាតនៅទូទាំងប្រទេស គេហៅតំណាងទៅ មួងនេះគេថាតែងតាំងខ្ញុំគេថាមានការបោះឆ្នោត ដូចបោះឆ្នោតចឹង ថាឲ្យខ្ញុំនឹងមកទទួលតំបន់ ។ ខ្ញុំមកពីនឹងទៅ ខ្ញុំខែ៩មកដល់ ឬខែ១០ ខ្ញុំក៏ហួសទៅស្រុក ខ្ញុំពេជ្រចិន្តានោះ ប្រគល់ការងារឲ្យបងប្អូនទៅ ខ្ញុំក៏(ស្តាប់មិនបាន)មកនៅនឹង នៅបាន ប៉ុន្មានខែៗ១០ ខែ១១ ខែ១២ ខែ១យួនពេញស្រុក ។

ដានី ៖ កាលនឹងគេតែងតាំងអ៊ី គេហៅអ៊ីមកភ្នំពេញដែរ?

សារ៉ុន ៖ បាទ!

ដានី ៖ កាលនឹងពីណាអ្នកតែងតាំងអ៊ី?

សារ៉ុន ៖ តា ប៉ុល ពត នឹង ។

ដានី ៖ តា ប៉ុល ពត ស្គាល់អីដែរ?

សារ៉ុន ៖ អត់ស្គាល់ទេ ពីព្រោះគេស្គាល់តាមរយៈតំបន់ទេ ។

ដានី ៖ តា ប៉ុល ពត អ្នកតែងតាំងអីផ្ទាល់ម៉ង់ចឹង?

សារ៉ុន ៖ បាទ!

ដានី ៖ រួចអីប្រកែកម៉េច បើគេតែងតាំងក្នុងសន្និបាទ?

សារ៉ុន ៖ មុនដំបូង មុននឹងគាត់ទៅនឹង តា ឡាំង ស្លាប់នឹង គាត់ហៅខ្ញុំទៅ ថាឲ្យខ្ញុំទទួលការងារនៅក្នុងតំបន់ ខ្ញុំថាខ្ញុំអត់ទទួលទេ ខ្ញុំអត់ចេះ ។

ដានី ៖ តា ប៉ុល ពត គាត់អ្នកប្រាប់ផ្ទាល់ម៉ង់ គាត់ហៅទៅជួបផ្ទាល់?

សារ៉ុន ៖ បាទ! ខ្ញុំអត់ចេះអត់ដឹងអីទេ ខ្ញុំមនុស្សកសិករ និងអក្សរចេះតិចតួចទៅធ្វើការងារអីកើត ខ្ញុំថា បានប៉ុន្មានខែខ្ញុំក៏មកៗទៅ ។ ដល់គេសន្និបាទនឹងគេបោះឆ្នោត ។

ដានី ៖ បោះឆ្នោត មានពីណាខ្លះអ្នកបោះឆ្នោត?

សារ៉ុន ៖ ច្រើនឯណា មនុស្សទៅប្រជុំសន្និបាទនឹងរាប់រយ ។

ដានី ៖ ចុះមនុស្សរាប់រយនឹង គេស្គាល់អីដែរ?

សារ៉ុន ៖ អត់ទេ ។

ដានី ៖ ចុះគេបោះឆ្នោតឲ្យអីដែរ?

សារ៉ុន ៖ គេប្រកាស យោងតាមឈ្មោះនៅសាលានោះ ។

ដានី ៖ ចឹងកាលមុនបោះឆ្នោត មុនប្រជុំ តា ប៉ុល ពត ហៅអីទៅជួបហើយ?

សារ៉ុន ៖ បាទ!

ដានី ៖ ទៅជួបផ្ទាល់ជាមួយគាត់?

សារ៉ុន ៖ បាទ!

ដានី ៖ ចុះ តា ប៉ុល ពត មានពីណាទៀត ដែលនៅជួប?

សារ៉ុន ៖ អត់ទេ មានឃើញតែគាត់នឹង ។

ដានី ៖ ចុះ តា នួន ជា នៅក្បែរគាត់ដែរអត់?

សារ៉ុន ៖ ទេ! សន្និបាតនេះឃើញ ។

ដានី ៖ ប៉ុន្តែពេលដែលហៅអីទៅជួបផ្ទាល់?

សារ៉ុន ៖ អត់ទេ មានតែគាត់ម្នាក់ ។

ដានី ៖ មានតែ តា ប៉ុល ពត ម្នាក់?

សារ៉ុន ៖ បាទ!

ដានី ៖ ជួបគាត់នៅណាកាលនឹង?

សារ៉ុន ៖ នៅភ្នំពេញ ។

ដានី ៖ នៅភ្នំពេញ នៅម្តុំណា ទៅជួបជាមួយ តា ប៉ុល ពត?

សារ៉ុន ៖ អត់ដឹងម្តុំណាទេ វាំងសម្តេចនឹង ។

ដានី ៖ ចុះ តា ប៉ុល ពត គាត់មាននិយាយប្រាប់ តា ឡាំង, តា ខាំភួន ស្លាប់ម៉េចៗ គាត់មាននិយាយអត់?

សារ៉ុន ៖ គាត់ប្រាប់ ។

ដានី ៖ គាត់ប្រាប់ថាម៉េច?

សារ៉ុន ៖ គាត់ប្រាប់ថាស្លាប់ហើយ ស្លាប់វ៉ៃគ្នា បានជាមកទៅគាត់ទទួលធាតុមកឲ្យបងប្អូនគេធ្វើបុណ្យណា ធាតុតាឡាំងនឹង ។

ដានី ៖ គាត់ឲ្យយកធាតុមកវិញដែរ?

សារ៉ុន ៖ បាទ! ឲ្យយកមក ។

ដានី ៖ តា ប៉ុល ពត គាត់ប្រាប់ថា តា ឡាំង ហើយ តា ខាំភួន ស្លាប់ដោយសារវ៉ៃគ្នាឯង?

សារ៉ុន ៖ បាទ!

ដានី ៖ វ៉ៃគ្នា?

សារ៉ុន ៖ បាទ!

ដានី ៖ វ៉ៃគ្នាអីចឹង គាត់ប្រាប់ឲ្យអ៊ំឲ្យយកធាតុ តា ឡាំង?

សារ៉ុន ៖ បាទ!

ដានី ៖ តា ខាំភួន អត់ទេ?

សារ៉ុន ៖ អត់ទេ ។

ដានី ៖ ឲ្យយកធាតុតា ឡាំង មួយទេ?

សារ៉ុន ៖ បាទ!

ដានី ៖ ហេតុអីបានគេអត់ឲ្យយកធាតុ តា ខាំភួន?

សារ៉ុន ៖ មិនដឹងគេ ពីព្រោះគេថា តា ខាំភួន វ៉ៃ តា ឡាំង ។

ដានី ៖ គេថា តា ខាំភួន វ៉ៃ តា ឡាំង?

សារ៉ុន ៖ បាទ! គេឲ្យតែធាតុ តា ឡាំង នឹងមកឲ្យបងប្អូនគេ ។

ដានី ៖ អ៊ំយកធាតុ តា ឡាំង មកផ្ទាល់ដែរអត់?

សារ៉ុន ៖ យកមកផ្ទាល់ ។

ដានី ៖ គាត់ឈប់ និយាយតែប៉ុននឹងទេ?

សារ៉ុន ៖ បាទ! និយាយតែប៉ុននឹង ។

ដានី ៖ គាត់អត់មាននិយាយណែនាំអីនិយាយច្រើន គាត់គ្រាន់តែប្រាប់ថា ។ កាលនឹងគេហៅតែអ៊ំម្នាក់ចូល ឬក៏មានពីណាទៅជាមួយអ៊ំដែរ?

សារ៉ុន ៖ អត់ទេ មានតែខ្ញុំ ។

ដានី ៖ ចុះ លក នេះ មានទៅជាមួយដែរអត់?

សារ៉ុន ៖ អត់បានទៅ ។

ដានី ៖ ចឹងទៅពីមណ្ឌលគិរីទៅ មានតែអ៊ំម្នាក់ទៅ?

សារ៉ុន ៖ បាទ!

ដានី ៖ ប៉ុន្តែ ដួន នេះគេហៅទៅបាត់ដែរហើយ ដល់ពេលដែលគេហៅអ៊ំទៅ?

សារ៉ុន ៖ នៅទេៗ ដល់ក្រោយទេ បានគេហៅទៅបាត់ ។

ដានី ៖ ដល់ពេលគេហៅទៅភ្នំពេញ ទៅជួបជាមួយ ប៉ុល ពត នឹង ដំបូងគាត់មានហៅឈ្មោះអ៊ំហើយនិយាយណែនាំ ប្រាប់អត់?

សារ៉ុន ៖ អត់ឃើញណែនាំរឿងអីទេ ។ មានតែប្រាប់ថា ពីរនាក់នឹង គាត់ស្ងាប់គ្នា ឲ្យធ្វើការងារ ចន្លោះទៅ ។ ខ្ញុំថាអត់ធ្វើទេ អ៊ំ ។ កាលនោះយើងថាហៅអ៊ំៗ ។ ខ្ញុំអត់ធ្វើទេ ខ្ញុំអត់មានសមត្ថភាពអីធ្វើទេ ។

ដានី ៖ ប្រាប់គាត់ថា អ៊ំ ខ្ញុំអត់មានសមត្ថភាពចឹង គាត់ថាម៉េច?

សារ៉ុន ៖ គាត់ថាយើងធ្វើទៅ ។ ខ្ញុំថាខ្ញុំអត់ធ្វើ បានប្រកែកគ្នាចឹង គាត់ថាចេះតែធ្វើទៅណា ។ ខ្ញុំថាអត់ធ្វើទេ អត់ចេះ ធ្វើទៅគិតខុសត្រូវ គិតថាចោទប្រជុំចេះ ចប់ ខ្ញុំអត់ធ្វើទេ ។ ខ្ញុំថានិយាយប្រាប់ឲ្យត្រង់ចឹងឯង អត់ធ្វើទេ ខ្ញុំជនជាតិផង អត់ដឹងអីផង ។ ប្រាប់គាត់ត្រង់ចឹង ។ ធ្វើទៅ ខ្ញុំថាអត់ទេ ខ្ញុំអត់ធ្វើទេ ។ អត់អីទេ គាត់ថា រឿងរ៉ាវអីខ្ញុំធានា ។ អត់ទេ ខ្ញុំថាខ្ញុំអត់ធ្វើទេ ខ្ញុំអត់ចេះទេ ។ មិនដឹងទេប្រវត្តិតស៊ូនឹងណា ខ្ញុំសុំជម្រាបក្មួយឯងប៉ុននឹង

ដានី ៖ ដល់ពេលចឹងទៅ ដល់ពេលគេបោះឆ្នោត គេនៅតែឲ្យអ៊ំធ្វើដដែល?

សារ៉ុន ៖ បាទ! ឲ្យធ្វើដដែល ។

ដានី ៖ ដល់ពេលគេបោះឆ្នោតឲ្យធ្វើដដែល អ៊ំមកវិញ អ៊ំធ្វើអី?

សារ៉ុន ៖ បាទ! ធ្វើទៅ ធ្វើបានប៉ុន្មានខែទៅវៀតណាមចូលស្រុក ។

ដានី ៖ ទៅធ្វើទៅ ហើយ ជួន អីទៅធ្វើជាមួយអ៊ំដែរ នៅក្នុងចង្ក្រោមជាមួយអ៊ំ?

សារ៉ុន ៖ បាទ! ធ្វើ រួចនឹង គេហៅទៅបាត់ខ្លួន ។

ដានី ៖ ដល់ហើយគេហៅ ជួន ទៅ ។ ដល់អ៊ំអត់មានដែលមកប៉ះពាល់ មកហៅអ៊ំទេ?

សារ៉ុន ៖ អត់ទេ ។

ដានី ៖ អ៊ំភ័យអត់កាលនឹង?

សារ៉ុន ៖ ភ័យដែរណា ពីណាក៏បាត់ៗ មិនភ័យម៉េច នៅនេះតិច ដឹងថាគេហៅអី ទើបដឹងទៀត មិនភ័យម៉េចហៅបាត់ៗដឹងថាទៅធ្វើការ ។

ដានី ៖ ហើយចុះ តា សាន អីគាត់មានដែលចុះមកណែនាំអីអ៊ំដែរអត់?

សារ៉ុន ៖ អឺ! ណែនាំដែរ គាត់ថាមានរៀងខំធ្វើទៅ គ្រប់គ្រងភូមិស្រុកខេត្តយើង ល្អដែរតើ គាត់ ខាងទាហានទេ គាត់ណែនាំម្តងៗ គាត់គិតតែពីរឿងបាញ់រឿងតប់ ។

ដានី ៖ តែអ៊ំពេលដែលអ៊ំឡើងគណៈតំបន់នឹង គេមានណែនាំថាអ្នកណាក្បត់អីឲ្យយើងរាយការណ៍ ទៅគេ ឲ្យគេហៅទៅភ្នំពេញអីអត់ គេមានប្រាប់អ៊ំអត់?

សារ៉ុន ៖ អត់ឃើញប្រាប់ទេ ។

ដានី ៖ គាត់អត់ប្រាប់?

សារ៉ុន ៖ អត់ទេ ។

ដានី ៖ កាលគេហៅ ជួន ទៅក៏អត់ប្រាប់អ៊ំដែរ?

សារ៉ុន ៖ អត់ទេ ។

ដានី ៖ ដូចថាយើងជាគណៈតំបន់អីគេមកប្រាប់ថា ហៅ ជួន ទៅចេះចុះអី?

សារ៉ុន ៖ អត់ទេ អត់មានប្រាប់ទេ ។

ដានី ៖ ហៅអត់មានប្រាប់?

សារ៉ុន ៖ អត់ទេ ។

ដានី ៖ ចុះ សុភា នេះគេហៅទៅដែរអត់ទេ?

សារ៉ុន ៖ ហៅទៅដែរ ។

ដានី ៖ គេហៅទៅជំនាន់ណាដែរ?

សារ៉ុន ៖ ជំនាន់ប៉ុន្មានទេ ភ្លេចហើយ ។

ដានី ៖ ហៅទៅក្រោយ ជួន, ក្រោយ តា ឡាំង, តា ខាំភួន, ហើយក៏ទៅមុន?

សារ៉ុន ៖ ក្រោយៗ តា ឡាំង ។

ដានី ៖ គាត់ខុសអីបានគេហៅទៅដែរ?

សារ៉ុន ៖ អត់ដឹងរឿងខុស រឿងត្រូវទេ ឃើញតែគេហៅទៅក៏បាត់ទៅៗ ហៅទៅធ្វើការ ដឹងធ្វើការមិនឃើញមក ។

ដានី ៖ ចុះកន្លែងមន្ទីរគាត់ អ្នកដែលគេហៅទៅ មានអ្នកខុសៗគេហៅទៅមន្ទីរគាត់គេមានប្រាប់អ៊ំ?

សារ៉ុន ៖ អត់ទេ ។

ដានី ៖ ចុះ សុភា នេះបន្ទាប់ពីគេហៅទៅបាត់ទៅ ពីណាមកជំនួសគាត់?

សារ៉ុន ៖ អត់មាន ។

ដានី ៖ អត់មានទេ?

សារ៉ុន ៖ បាទ!

ដានី ៖ ចឹងពេលដែលអ៊ំឡើងជាគណៈតំបន់ហើយ មិនមែនអ៊ំសប្បាយចិត្តទេ អ៊ំភ័យវិញ?

សារ៉ុន ៖ ភ័យ ។

ដានី ៖ ឡើងកាន់តែធំ កាន់តែភ័យចឹង?

សារ៉ុន ៖ កាន់តែភ័យ ។

ដានី ៖ ម៉េចចឹងធ្វើម៉េចបានយើងកាន់តែភ័យ?

សារ៉ុន ៖ ភ័យហើយណា ហៅពីណាមកមិនឃើញមក ទៅថាធ្វើការមិនឃើញមក អានឹងយើងភ័យ ។

ដានី ៖ ចុះអ៊ំពេលដែលគេហៅអ៊ំទៅសន្និបាទនោះ ហើយ ប៉ុល ពត ហៅទៅជួបអ៊ំផ្ទាល់ តែងតាំងអ៊ំជាគណៈតំបន់ ប៉ុននឹងកាលគេហៅអ៊ំទៅនឹង ភ័យអត់?

សារ៉ុន ៖ ទៅសន្និបាទទៅគ្នាច្រើននេះវាភ័យដែរ ។ ម៉េចមិនភ័យ ហៅទៅ ។

ដានី ៖ ពេលដែលអ៊ំទៅជួប ប៉ុល ពត ផ្ទាល់កាលនឹងអ៊ំមានអារម្មណ៍ម៉េចដែរ ពេលដែលយើងគាត់ហៅអ៊ំទៅជួបផ្ទាល់ ពេលដែលនិយាយ?

សារ៉ុន ៖ អារម្មណ៍ហើយណា ខ្លាចដែរ ហើយមនុស្សអត់ចេះ អត់ដឹងផង នៅក្រោមគេផង យើងនៅស្រុកយើងមានដឹងអី សុទ្ធតែមានបញ្ហាពីតំបន់បានយើងចេះធ្វើ យើងមានទៅជួបខាងលើឯណា ឲ្យធ្វើយ៉ាងម៉េច គេធ្វើតាមនឹង ណែនាំដាំដុះ ធ្វើចំការដាំដុះដើម្បីដោះ

ស្រាយប្រជាជនឲ្យធូរឲ្យជា កុំឲ្យអត់ កុំឲ្យឃ្លាន ។ អានឹងគេណែនាំប៉ុនខាងតំបន់ គេណែនាំទំដឹកនាំប្រជាជនយើងឲ្យមានបាយ មានផ្ទះនៅ ។

ដានី : ចុះពេលដែលគេហៅអ៊ំទៅសន្និបាទ ហើយតែតាំងអ៊ំជាគណៈតំបន់ អ៊ំមានដឹងមុនពេលទៅ មានដឹងខ្លួនដែរអត់?

សារ៉ុន : អត់ដឹងទេ ។

ដានី : អត់ដឹងសោះ?

សារ៉ុន : បាទ! អត់ដឹងទេ ប៉ុននឹងទៅ រួចសន្និបាទទៅ គេក៏ ។

ដានី : ហើយមុនពេលដែលទៅជួប ប៉ុល ពត នឹងគេប្រាប់អ៊ំយ៉ាងម៉េច?

សារ៉ុន : គេប្រាប់រឿងអី?

ដានី : គេប្រាប់ថា អ៊ំត្រូវជួប ប៉ុល ពត អី ត្រូវជួបផ្ទាល់ជាមួយគាត់ គេមកប្រាប់អ៊ំថាម៉េចទៅ?

សារ៉ុន : អានឹងគេគេស្ដ តាមទូរលេខ ។

ដានី : គេស្ដទូរលេខពីត្រឹមណាទៅត្រង់ណា?

សារ៉ុន : ពីភ្នំពេញមកមណ្ឌលគិរី ។

ដានី : គេប្រាប់ថាម៉េច?

សារ៉ុន : គេថាយើងនេះ ត្រូវទៅធ្វើការសន្និបាទ គាត់ដឹងឲ្យខ្ញុំទៅជាមួយ តា សាន អី ។

ដានី : ទៅជាមួយ តា សាន?

សារ៉ុន : បាទ! កងពលនោះ គេថាខាងទាហាន ខាងនេះមូលដ្ឋានគេទៅផ្សេង ។

ដានី : ចុងខែ៩?

សារ៉ុន : ចុង ខែ៩ ។

ដានី : ចុងខែ ឆ្នាំ៧៨?

សារ៉ុន : បាទ!

ដានី : កាលនឹងអ៊ំជិះអីទៅ ជិះពីមណ្ឌលគិរីមកភ្នំពេញ?

សារ៉ុន : គេយកយន្តហោះមក ។

ដានី : គេយកយន្តហោះ?

សារ៉ុន : បាទ! គេយកអ្នករតនគិរី ស្ទឹងត្រែងទៅៗទាំងអស់គ្នា ទៅពីមណ្ឌលគិរីទៅ ចុះនៅរតនគិរី គេប្រមូលកម្លាំងនៅនឹង នាំគ្នាទៅៗ ។

ដានី ៖ ចឹងគេយកយន្តហោះមកពីមណ្ឌលគិរី អាំហើយនឹង តា សាន?

សារ៉ុន ៖ បាទ!

ដានី ៖ ពីណាទៀត ក្រៅពីអាំ ហើយ តា សាន?

សារ៉ុន ៖ ប៉ុននឹង ។

ដានី ៖ តែពីរនាក់នឹងទេ?

សារ៉ុន ៖ ពីរនាក់នឹង ។

ដានី ៖ ដល់ពេលចេញពីមណ្ឌលគិរី ទៅរតនគិរី?

សារ៉ុន ៖ ទៅរតនគិរី ។

ដានី ៖ ទៅរតនគិរី ពីណាគេមកជាមួយ?

សារ៉ុន ៖ ខ្ញុំអត់ចាំឈ្មោះគេទេ ។

ដានី ៖ អត់ចាំ?

សារ៉ុន ៖ ហ្នឹងអត់ចាំ ។

ដានី ៖ ដល់ពេលចេញពីរតនគិរី យើងមកណា មកភ្នំពេញត្រង់ ឬក៏ឈប់នៅណាទៀត?

សារ៉ុន ៖ អត់មានឈប់ត្រង់ណាទេ ឈប់នៅវាលយន្តហោះពោធិ៍ចិនតុង ។

ដានី ៖ ជិះយន្តហោះម៉ាក់អីដែលត្រូវទៅយកពីរតន?

សារ៉ុន ៖ អីយន្តហោះអាស្លាបវែងចឹង មិនមានម៉ាកអីទេ វាកង្ហារពីរខាងមុខ ។

ដានី ៖ មិនមែនអាកន្ទុំរុយ?

សារ៉ុន ៖ អត់ទេ ។

ដានី ៖ មិនមែនអេលេកូ?

សារ៉ុន ៖ គេហៅឡាប់បាតា គេហៅ ពួគេនិយាយហៅចឹង ។

ដានី ៖ ជិះប៉ុន្មាននាក់ក្នុងយន្តហោះនឹង?

សារ៉ុន ៖ បានច្រើនតើ បាន៣០-៤០នាក់ ។

ដានី ៖ បាន៣០-៤០នាក់ដែរ?

សារ៉ុន ៖ បាទ!

ដានី ៖ ដល់ពេលអីចុះនៅពោធិ៍ចិនតុង គេយកអីមកទទួលអាំទៀត?

សារ៉ុន ៖ គេយកឡាន ។

ដានី ៖ ឡានម៉ាកអី?

សារ៉ុន :	ដឹងឡានម៉ាក់អីទេ ហ៎! ខ្ញុំមិនស្គាល់ម៉ាកហើយឡានគេទេ ។

ដានី :	ពណ៌អីទៅ ឡាននឹងដែលមកយកអ៊ីនឹង?

សារ៉ុន :	ដឹងឡានពណ៌អីទេ ពណ៌ស ពណ៌ខ្មៅ នឹងណា ចុះមនុស្សវាច្រើនដែរ ។

ដានី :	ក្នុងឡាននឹង ជិះគ្នាប៉ុន្មាននាក់ ដែលគេយកចេញពីពោធិ៍ចិនតុងមក?

សារ៉ុន :	បាន៣-៤នាក់ ។

ដានី :	ហើយដឹកអ៊ំមកស្នាក់នៅកន្លែងណាទៅ?

សារ៉ុន :	ស្នាក់នៅកន្លែងផ្ទះសំណាក់គេប្រគល់ខាងមណ្ឌលគិរីនឹងមានផ្ទះប៉ុន្មានខ្នងទេ ។

ដានី :	នៅណាទៅនឹង?

សារ៉ុន :	នៅជិតមុខវាំងនឹង ។

ដានី :	មុំណាជិតមុខវាំង?

សារ៉ុន :	ចំនឹងទន្លេ៤មុខនឹងណា ។

ដានី :	ចំទន្លេបួនមុខ?

សារ៉ុន :	បាទ! ផ្ទះនឹងដឹងផ្ទះណាទេ ខ្ញុំអត់ដឹងទេ ។

ដានី :	ផ្ទះនឹងរៀងម៉េច ដែលអ៊ំស្នាក់នៅនឹង?

សារ៉ុន :	ផ្ទះនឹងខ្ពស់ណាស់ ២ជាន់ណា ។

ដានី :	ផ្ទះខ្ពស់ ២ជាន់ណា?

សារ៉ុន :	បាទ! ហើយផ្ទះអីៗទេ របស់គេនឹង ។

ដានី :	ដូចថាផ្ទះនឹងមានរបង អីយ៉ាងម៉េច មានរូបអីពីមុខអីយ៉ាងម៉េចដែរ បើតាមអ៊ំ?

សារ៉ុន :	អត់ឃើញមានអីទេ មានតែរបងគេ ។

ដានី :	ដល់ពេលចឹងហើយ ដល់ពេលអ៊ំមកដល់ភ្នំពេញហើយ ពេលដែលអ៊ំមុនទៅជួប ប៉ុល ពត គេមានមកប្រាប់ថា ផ្ទះនឹងថាម៉េចទៀតអត់?

សារ៉ុន :	អត់មានឃើញមកប្រាប់អីទេ ។

ដានី :	ហើយគេដឹកអ៊ំទៅ?

សារ៉ុន :	មានតែដឹកទៅ ពេលប្រជុំនឹងដឹកទៅទាំងអស់គ្នា ។

ដានី :	ដឹកទៅប៉ុន្តែមុននឹងធ្វើសន្និបាទ មានតែដឹកទៅជួបប៉ុល ពត ផ្ទាល់សិន?

សារ៉ុន :	អត់ទេ មានតែទៅដល់កន្លែងសាលាគេប្រជុំ ។

ដានី :	ទៅដល់កន្លែងសាលាប្រជុំហើយ បានទៅជួបប៉ុល ពត ផ្ទាល់?

សារ៉ុន ៖ ជួបនៅកន្លែងសាលាប្រជុំនឹងម៉ង ។

ដានី ៖ ជួបផ្ទាល់ជាមួយ ប៉ុល ពត នឹងម៉ង?

សារ៉ុន ៖ ជួបទាំងអស់គ្នាមនុស្សរាប់រយនឹងម៉ង ។

ដានី ៖ ហើយដល់ពេលចឹង ពេលទៅប្រជុំនៅភ្នំពេញប៉ុន្មានថ្ងៃ បានត្រឡប់មកវិញ?

សារ៉ុន ៖ ប៉ុន្មានថ្ងៃអត់ចាំទេ ម៉ាអាទិត្យអីដឹង ។

ដានី ៖ មុនដែលប្រជុំហើយ គេធ្វើសន្និបាទ គេតែងតាំងអីជាគណៈតំបន់ ហើយគេមានបង្ហាត់បង្រៀនអំពីគោលនយោបាយដែលយើងត្រូវដឹកនាំប្រជាជន ត្រូវធ្វើម៉េចៗ គេមានបង្រៀនថាម៉េចទៀតដែរ?

សារ៉ុន ៖ អត់មានបង្រៀនអីទេ គ្រាន់តែបញ្ជាក់ប្រជុំនឹង ប្រជុំរៀនសូត្រនឹង ។

ដានី ៖ ប្រជុំរៀនសូត្រ?

សារ៉ុន ៖ បាទ! រៀនសូត្រជារួមនឹង ។

ដានី ៖ គេអត់មានថា យើងត្រូវមកបង្រៀបពីគោលនយោបាយ ត្រូវដឹកនាំប្រជាជននៅតំបន់នឹងម៉េចៗអីទៀត គេអត់មានបង្រៀនអីដែរអត់?

សារ៉ុន ៖ អត់ទេ មានតែរៀនរួមនឹងឯង គ្រប់ខេត្តគ្រប់ស្រុក គ្រប់កងពល វិភាគរួម សមាជិកកងទ័ពធ្វើម៉េចឲ្យបានល្អ ដោះស្រាយជីវភាពប្រជាជនឲ្យបានល្អ ។

ដានី ៖ ចុះអ៊ំដល់ពេលមកវិញ អ៊ំជិះអីមកវិញ ពីភ្នំពេញមកមណ្ឌលគិរី?

សារ៉ុន ៖ អានឹងជិះកាបាល់ទឹក ដល់ក្រចេះជិះឡាន ។

ដានី ៖ លែងជិះយន្តហោះមកវិញហើយ?

សារ៉ុន ៖ អត់ទេ ។

ដានី ៖ ចឹងពេលដែលប្រជុំចប់ អ៊ំជិះកាប៉ាល់ទឹកពី?

សារ៉ុន ៖ បាទ! កាណូតនឹង ។

ដានី ៖ ជិះគ្នាច្រើនទេកាលនឹង?

សារ៉ុន ៖ ច្រើនតើ កាណូតនឹងធំដែរតើ ជិះបាន៣០-៤០នាក់ តែខ្ញុំទៅនឹងគេដឹកអីវ៉ាន់ទៅ ចេញកាណូតទៅ ខ្ញុំម្នាក់ទៅ ជិះទៅវិញ ពីព្រោះខាងកងពលគេជិះកាណូតគេទៅ ។

ដានី ៖ អ៊ំជិះមកជាមួយ តា សាន វិញដែរអត់ទេ?

សារ៉ុន ៖ អត់ទេ កាណូតគាត់ផ្សេង កាណូតខ្ញុំផ្សេង ។

ដានី ៖ កាណូតផ្សេងៗគ្នា?

សារ៉ុន ៖ បាទ!

ដានី ៖ កាណូតអ៊ំចេញពីត្រង់ណា?

សារ៉ុន ៖ ពីភ្នំពេញ ។

ដានី ៖ ចេញពីកន្លែងណាទៅ?

សារ៉ុន ៖ កន្លែងខ្ញុំថា កន្លែងទន្លេបួនមុខនឹង ។

ដានី ៖ ចេញមកចេញពីភ្នំពេញមកដល់ក្រចេះ?

សារ៉ុន ៖ មកដល់ក្រចេះ ។

ដានី ៖ មានដេកផ្លូវទេ ជិះពីភ្នំពេញមកក្រចេះ?

សារ៉ុន ៖ អត់ទេ ម៉ោង១១ព្រឹក ម៉ោង៩ ម៉ោង១០នឹងដល់ហើយ ។

ដានី ៖ មកដល់ក្រចេះ?

សារ៉ុន ៖ បាទ!

ដានី ៖ យើងសម្រាកនៅក្រចេះ?

សារ៉ុន ៖ បាទ! សម្រាកនៅក្រចេះ ។ ព្រលឹមឡើងគេជិះឡានមកមណ្ឌលគិរី ។

ដានី ៖ កាលនឹងគណៈតំបន់ក្រចេះ មានទៅជាមួយអ៊ំ?

សារ៉ុន ៖ អត់មានទេ ម្នាក់នៅនឹង ។

ដានី ៖ អត់មានទៅពេលដែលប្រជុំសន្និបាទនៅភ្នំពេញ?

សារ៉ុន ៖ អត់មានៗតែខ្ញុំម្នាក់នឹង ។

ដានី ៖ អានឹងដោយសារគេតែងតាំងអ៊ំថ្មីបានអ៊ំទៅជាមួយ?

សារ៉ុន ៖ (មិនឆ្លើយ)

ដានី ៖ ចុះអ៊ំពេលដែលអ៊ំទៅនឹង ខាងគណៈតំបន់ខាងក្រចេះ គេអត់ទៅទេ?

សារ៉ុន ៖ ខាងក្រចេះ ដូចទៅខ្ញុំភ្លេចអស់ហើយ ។

ដានី ៖ តែអ៊ំមានស្នាក់នៅក្រចេះម៉ាយប់អត់ មុនមកមណ្ឌលគិរី?

សារ៉ុន ៖ ស្នាក់ម៉ាយប់មកក្រចេះ ។

ដានី ៖ ស្នាក់នៅកន្លែងណា នៅក្រចេះ?

សារ៉ុន ៖ នៅគេឲ្យផ្ទះសំណាក់នៅផ្ទះ សម្រាប់ដឹករបស់របរមកក៏ដាក់នៅក្នុងផ្ទះនឹង បានដឹកមកមណ្ឌលគិរី ។

ដានី ៖ អ៊ំកាលនឹងដែលមានធ្លាប់ទំនាក់ទំនងជាមួយខាងគណៈតំបន់នៅក្រចេះ?

សារ៉ុន ៖ អត់ទេៗ ពីព្រោះខ្ញុំធ្វើការថ្មីមិនដែលស្គាល់គេផង ។

ដានី ៖ អ៊ំអត់ស្គាល់គណៈតំបន់នៅក្រចេះទេ?

សារ៉ុន ៖ អត់ទេ ។

ដានី ៖ គណៈតំបន់១០៥?

សារ៉ុន ៖ អឺ!

ដានី ៖ អឺ!៥០៥?

សារ៉ុន ៖ បាទ! អត់ស្គាល់គេទេ ។

ដានី ៖ អត់ដែលស្គាល់?

សារ៉ុន ៖ អឺ! ពីព្រោះយើងធ្វើការផារមុននៅតែស្រុកនឹង ស្គាល់តែគណៈតំបន់ខ្លួនឯង ក៏ប៉ុន្តែនឹង អត់មានស្គាល់ពីណាទេ ។

ដានី ៖ ចឹងអ៊ំដល់ពេលយើងត្រឡប់មកវិញ ដល់ពីចុងខែ៩ ខែ១០ ខែ១១ ខែ១២នឹង អ៊ំផ្លាស់ពីពេជ្រចិន្តាមកនៅខាងតំបន់មកនៅកន្លែងណា នៅ?

សារ៉ុន ៖ បាទ! នៅភ្នំក្រោលនឹង នៅកោះញ៉ែក ។

ដានី ៖ អ៊ំមានផ្ទះមួយនៅនឹងវិញ?

សារ៉ុន ៖ កាលទៅដល់នឹងខ្ទមតូច មកដល់នេះទៅធ្វើផ្ទះៗតូចដែរ ប៉ុនផ្ទះនោះដែរ ។

ដានី ៖ ប៉ុនផ្ទះនោះ?

សារ៉ុន ៖ បាទ! ប៉ុនផ្ទះគេប្រក់ស្បូវនោះណា ប៉ុននោះឯង ។

ដានី ៖ ហ្នឹងមកនៅភ្នំក្រោលនឹង?

សារ៉ុន ៖ បាទ!

ដានី ៖ ចុះយើងធ្វើការម៉េចទៅ មកដល់តំបន់?

សារ៉ុន ៖ មានធ្វើការម៉េច មានណែនាំតាមស្រុកឲ្យធ្វើការដឹកនាំប្រជាជនធ្វើស្រែ ធ្វើចំការ ធ្វើយ៉ាងម៉េចឲ្យមាន កុំឲ្យមានអីមានបញ្ហាអីយើងត្រូវដោះស្រាយធ្វើការឲ្យក្រុមរៀនសូត្រ

ដានី ៖ ប៉ុន្តែអ៊ំ ពេលនឹងពី៧៨នឹង មិនយើងចាប់ផ្តើមមានសង្គ្រាមជាមួយវៀតណាម?

សារ៉ុន ៖ មានហើយ ។

ដានី ៖ ពេលដែល៧៨ យើងមានសង្គ្រាមជាមួយវៀតណាម ហើយ?

សារ៉ុន ៖ មានហើយមិនមានវៃដល់ក្នុងទេ គេវៃតាមព្រំដែននឹងហើយ គេមានវៃតាមព្រំដែនដូចយើងជាមួយថៃសារមុនចឹង រប៉េះរប៉ោះវៃចឹងហើយ ។

ដានី ៖ ប៉ុន្តែដល់ពេលយើងវ៉ៃនៅតាមព្រំដែនអីចឹង ដូចជាអ៊ីជាគណៈតំបន់ហើយប្រជាជនអីយើង មានគោលនយោបាយ មានផែនការម៉េច ដើម្បីទប់ទល់ជាមួយវៀតណាម?

សារ៉ុន ៖ អានឹងយើងមានទប់ទល់អីទេ មានតែខាងកងទ័ពគេ មានយើងទៅថានៅម៉ាកន្ទែង តែប៉ុននឹងទៅ មានតែខាងកងទ័ពគេ ។

ដានី ៖ ខាងកងទ័ពខាងណា?

សារ៉ុន ៖ កងពល៩២០ ។

ដានី ៖ ចុះកងទ័ពៗតំបន់យើងអត់មានទៅវ៉ៃ?

សារ៉ុន ៖ ទៅសហការគ្នាដែរ ប៉ុន្តែយើងវាតិច ។

ដានី ៖ កាលនឹងទ័ពតំបន់យើងមានប៉ុន្មានកាលនឹង?

សារ៉ុន ៖ ២វរៈ មានប៉ុន្មាន ម៉ាវរៈ១០០ជាង១០០-២០០នាក់ វាអាចប្រហែលជាខ្ទង់៤០០ នាក់នឹង ។

ដានី ៖ ប្រហែល៤០០នាក់?

សារ៉ុន ៖ បាទ!

ដានី ៖ កាលនឹងពីណាគេប្រធានមេបញ្ជាការកងទ័ពតំបន់?

សារ៉ុន ៖ មើលភ្លេចអស់ហើយ ។

ដានី ៖ ឈ្មោះ វៀង?

សារ៉ុន ៖ វៀង ហ្នឹងហើយ ភ្លេចឈ្មោះ អត់ចាំទេ ។

ដានី ៖ ប៉ុន្តែកាលនឹងដូចថាខាងវៀតណាមអីមានដែលវ៉ៃចូលមកដល់ក្នុងដី តំបន់អី១០៥ដែរ អត់?

សារ៉ុន ៖ អត់ទេ ទាល់តែខែ១ វ៉ៃបុកចូលដល់១០៥ ។

ដានី ៖ ខែ១បានវ៉ៃបុកចូលមកម៉ង?

សារ៉ុន ៖ បាទ! កាលពីមុននឹងសឹងតែវ៉ៃគ្នាតាមព្រំដែន ដូចថៃវ៉ៃយើងនៅព្រះវិហារ នៅប្រាសាទតាមាន់នឹង វ៉ៃទប់គ្នានៅនឹង ដល់យូរៗទៅគេដុតទៅ គេចូលនឹងកងកម្លាំងច្រើនទៅ អត់ដឹង សុទ្ធតែប្រុច គេរាយការណ៍ថាមកដល់ជិតកោះញែកហើយ មកដល់ក៏រៀបចំកងទ័ពទប់ទល់វ៉ៃគ្នា វ៉ៃមែនទែនហើយណា ។

ដានី ៖ ចុះកាលនឹងអី ពេលដែលវ៉ៃគ្នាអីមានខាងកងទ័ព ខាងកងពលអីមានដែលចាប់បានវៀតណាមអី?

សារ៉ុន ៖ អត់ទេ មិនឃើញគេធ្វើចាប់បានៗ

ដានី ៖ អត់ដែលឃើញចាប់បាន?

សារ៉ុន ៖ បាទ!

ដានី ៖ ហើយពេលនឹងមានយើងមានផែនការ ប្លុកផ្ទះពអីយ៉ាងម៉េចទៅ ពេលដែលកងទ័ពខាងវៀតណាមវ៉ៃបុកខ្លាំង ត្រូវការបញ្ជូនកងទ័ពពីក្រោយអីទៅថែមអី គេមានផែនការណ៍នៅតំបន់អីអី មានទៅជ្រើសរើសកងទ័ពអីដែរ?

សារ៉ុន ៖ អត់ទេ អត់បានជ្រើសរើសទេ មានតែកងទ័ពចាស់ៗ

ដានី ៖ មានកងទ័ពចាស់?

សារ៉ុន ៖ មានកងទ័ពខាងកងពលគេ ពីព្រោះគេកម្លាំងប្រមូលផ្តុំ សហការគ្នាវ៉ៃទប់មានអីទៅ ឈ្នះគេណា គេកម្លាំងធំយើងកម្លាំងតិចៗ

ដានី ៖ ចុះអ៊ំ ពេលដែលអ៊ំមកកាន់ខាងតំបន់ ស្រុកពេជ្រចិន្ដា ត្រូវប្រគល់ឲ្យពីណាវិញទៅ?

សារ៉ុន ៖ ប្រគល់ឲ្យបង ខ្ញុំថាបង ដាក់ៗ

ដានី ៖ បង ដាក់?

សារ៉ុន ៖ បាទ! (ស្តាប់មិនបាន)

ដានី ៖ បង ដាក់ បងអ៊ំនឹងទៅគ្រប់គ្រងរួមវិញ?

សារ៉ុន ៖ អត់ ដូចជាថាគាត់ទទួលរួមទៅចុះ ពីព្រោះនៅក្នុង៣នាក់នឹង មាន ប៊ុនសូ មានបង ដាំង បងថ្លៃៗ

ដានី ៖ ចុះខាងកោះញ៉ែក បន្ទាប់ពី ស្វាយ មិនអ៊ំថាគាត់ចង់ក?

សារ៉ុន ៖ ចង់កៗ

ដានី ៖ អត់ដឹងថាមូលហេតុអីបានគាត់ចងក?

សារ៉ុន ៖ អត់ទេ អត់ដឹងទេៗ

ដានី ៖ បន្ទាប់ពីគាត់ចងទៅពីណាគ្រប់គ្រងរួមវិញ?

សារ៉ុន ៖ អឺ! ខ្ញុំអត់ដឹង អត់បានដឹងទេ ឃើញគេចងកទៅ គេតែងតាំងទៅ កាលនឹងនៅតំបន់ នឹងគេនៅទាំងអស់នឹងៗ

ដានី ៖ ហើយច្បារ បន្ទាប់មកឈ្មោះ លក នឹងគាត់មកខាងតំបន់ដែរ?

សារ៉ុន ៖ បាទ!

ដានី ៖ ហើយ ចាំ គេហៅមកភ្នំពេញ នៅសល់តែឈ្មោះ ហាន មួយ?

សារ៉ុន ៖ បាទ!

ដានី ៖ ពីណាគេគ្រប់គ្រង បន្ទាប់ពី ចាំ ហើយនិង លក គាត់ចេញទៅ?

សារ៉ុន ៖ មានអី បង លក, បង ហាន ។

ដានី ៖ នៅ លក ដដែល?

សារ៉ុន ៖ បាទ!

ដានី ៖ ហើយនៅអូររាំងឈ្មោះ គី នឹងគាត់កាន់?

សារ៉ុន ៖ បាទ!

ដានី ៖ ចុះអុំ អនស៊ី?

សារ៉ុន ៖ នៅជាមួយគ្នានឹង ។

ដានី ៖ ចុះកែវសីម៉ា បន្ទាប់ពី តា ខាំភួន គាត់មកភ្នំពេញ ហើយស្លាប់ទៅ ពីណាគេអ្នកទទួលរួម នៅកែវសីម៉ា?

សារ៉ុន ៖ មានអី មានមុនដំបូងមាន កាស៊ី មាន ចាន់ដើរ ។ រួចមកគេដកប្រជាជនមកកោះញ៉ែក ទាំងអស់ ។

ដានី ៖ ចឹងដកប្រជាជនមកកែវសីម៉ា មកកោះញ៉ែកទាំងអស់?

សារ៉ុន ៖ បាទ!

ដានី ៖ ចឹងលែងមានស្រុកកែវសីម៉ាទៀតហើយ?

សារ៉ុន ៖ អឺ! ប៉ុន្តែស្រុកកែវសីម៉ាដែរ តែមកនៅកោះញ៉ែកនឹងវិញ ។

ដានី ៖ មកនៅកោះញ៉ែក?

សារ៉ុន ៖ បាទ! គេរៀបតាមស្រុកៗដែរ ។

ដានី ៖ ពីណាគេទទួលរួមវិញ?

សារ៉ុន ៖ មិនដឹងពីណាគេទេ គេតាមគេនឹង ខ្ញុំអត់បានសួរ បានដឹង អានឹងសុំជម្រាបក្លាយប៉ុននឹង ព្រោះយើងមិនមែនអ្នកទទួលខុសត្រូវរួម ។

ដានី ៖ ចឹងអុំពេលដែល៧៩ ពេលដែលវៀតណាមចូលមក ខែមួយវៃចូលមកយ៉ាងម៉េចទៅ នៅតំបន់អុំ ដូចថាកម្មាភិបាលយើងត្រូវយ៉ាងម៉េចទៀត?

សារ៉ុន ៖ កាលមុននឹងវៀតណាមចូលមកដល់ហើយ ទប់គ្នាមែនទែនវៃ ដល់នេះកងខ្ញុំក៏រត់ចូលព្រៃ ទាំងអស់ ពីព្រោះខ្លាចៗ រត់ចូលព្រៃនឹង ទាំងវៀតណាមចូល ។ ម្តងនេះយើងអប់រំឲ្យ ប្រជាជនចូលក្នុងភូមិវិញ ឲ្យកងទ័ពទប់សិន យើងដឹកប្រជាជនទាំងយប់ទាំងថ្ងៃ ទាំងឡាន

អ្នកអត់មាន អ្នកខ្លះក៏ជិះរទេះគោមកទៅ ឡានយើងរាតិច ប្រជាជនរាប់ម៉ឺន យើងទៅការពារម៉េច នៅជុំព្រៃចាស់ម៉ាត្រើចតូចនោះ អត់ទេ ។ ឲ្យប្រជាជនមករួមរស់នៅក្នុងភូមិវិញទាំងអស់ ។ ហើយយើងដកតែកងទ័ពវិញ កងទ័ពណាដែលគេស្ម័គ្រចិត្តទៅភូមិក៏គេទៅភូមិ អ្នកណាគេស្ម័គ្រចិត្តតស៊ូ មកនៅព្រៃ ។

ដានី : ចុះកាលនឹងអ៊ំមកនៅព្រៃ?

សារ៉ុន : នៅព្រៃ ។

ដានី : នៅព្រៃ នៅកន្លែងណា នៅដំបូងពេលដែលឃួនមកនឹង?

សារ៉ុន : នៅកែវសីម៉ានឹង មានព្រៃធំត្រង់នឹង ។

ដានី : កាលនឹងបើប្រជាជនអ្នកណាស្ម័គ្រចិត្តចូលភូមវិញចូល អ្នកណានៅព្រៃៗ?

សារ៉ុន : អត់ទេ ប្រជាជនចូលភូមិទាំងអស់ ។

ដានី : នៅតែអ្នកធ្វើការទេ?

សារ៉ុន : នៅតែកងទ័ពទេ ។ កងទ័ពណាគេស្ម័គ្រចិត្តទៅភូមិក៏ឲ្យគេទៅភូមិ ។

ដានី : ប៉ុន្តែអ៊ំដល់ពេលដែលយើងមកនៅក្នុងព្រៃ អ៊ំចូលកងទ័ពវិញ?

សារ៉ុន : អឺ! គេចាត់តាំងធ្វើប្រធានកងពល ។

ដានី : គេចាត់តាំងអ៊ំឲ្យធ្វើប្រធានកងពលទៀត?

សារ៉ុន : អឺ!

ដានី : កងពលឈ្មោះកងពលអី?

សារ៉ុន : កងពល១០៥ ។

ដានី : ចឹងតំបន់១០៥ ដល់ពេលវៀតណាមចូលឆ្នាំ៧៩នឹង រៀបទៅជាកងពល១០៥វិញ?

សារ៉ុន : បាទ!

ដានី : ហើយចឹងអ៊ំធ្វើប្រធានកងពលវិញ?

សារ៉ុន : បាទ!

ដានី : ប្រធានកងពល១០៥ កាលនឹងមានគ្នាប៉ុន្មាននាក់ គណៈកងពល?

សារ៉ុន : ខ្ញុំ, អនស៊ី, ហើយឯណាទៀត ៣-៤នាក់ ខ្ញុំភ្លេចអស់ទៅ ។

ដានី : តា វៀង ដែរ?

សារ៉ុន : អឺ! វៀងដែរ ។

ដានី : អ៊ំប្រធាន, អនស៊ី រង, វៀង រង?

សារ៉ុន ៖ បាទ!

ដានី ៖ ហើយកាលនឹងកងពលអ៊ំមានប៉ុន្មានទៅ ១០៥?

សារ៉ុន ៖ ច្រើនណាស់ ប្រហែលជិត២០០០។

ដានី ៖ ជិត២០០០?

សារ៉ុន ៖ បាទ! មន្ទីរកងពល កងពលធំអី កងពលអី ប្រហែលចាញ់ហើយ ព្រោះខ្ញុំកងពលតូចទេ ទាំងប្រុសទាំងស្រី មនុស្សនៅកងពល១០៥នឹង ជាង៤០០០។

ដានី ៖ ជាង៤០០០?

សារ៉ុន ៖ បាទ!

ដានី ៖ កាលនឹងកងពលរបស់អ៊ំ១០៥នឹង ម៉េចបានដាក់ឈ្មោះ១០៥ចឹង?

សារ៉ុន ៖ ដឹងគេ តាំងពីនៅភូមិនោះ គេដាក់ចឹង។

ដានី ៖ ពីណាអ្នកដាក់ឲ្យ?

សារ៉ុន ៖ ដឹង ពូតែគេហៅ១០៥ៗ ថានិយាយតែចឹង។

ដានី ៖ ពីណាគេតែងតាំងអ៊ំជាប្រធានកងពល?

សារ៉ុន ៖ អឺ! គេនឹងហើយ គេរាយការណ៍ទៅខាងអគ្គបញ្ជាការៗទៅគេក៏ឯកភាពឲ្យខ្ញុំនឹងធ្វើប្រធានកងពលចឹង។

ដានី ៖ អគ្គបញ្ជាការ កាលនោះពីណាគេ?

សារ៉ុន ៖ ពីណា សុន សេន។

ដានី ៖ ហើយចុះក្នុងកងទ័ពរបស់អ៊ំនឹង កាលពីមុនមក មិនមានតែប្រហែលជា៤០០នាក់ទេ ជាកងទ័ព កាលពីជំនាន់៣ឆ្នាំ?

សារ៉ុន ៖ បាទ!

ដានី ៖ ដល់ពេល៧៩នឹង ថាម៉េច អ៊ំមានប្រសាសន៍មិញថា ៤០០០នាក់ ចឹងកងទ័ពនឹងបានមកពីណាទៀតមក?

សារ៉ុន ៖ អ្នកខ្លះគេនៅមិនបាន គេចាប់ដាក់គុកដាក់ច្រវ៉ាក់ទៅ គេក៏រត់មកៗចេះតែកេណ្ឌទៅ អ្នកខ្លះខេត្តផ្សេងៗទៅកងពលផ្សេងៗទៅគេឃើញ១០៥ទៅ គេមកនៅ១០៥ទៅ។

ដានី ៖ គេមកនៅ១០៥?

សារ៉ុន ៖ បាទ!

ដានី ៖ កាលនឹង៤០០០នាក់ យើងមានអាវុធគ្រប់ដៃដែរ?

សារ៉ុន ៈ អូ! ឲ្យតែកងទ័ពនឹងជិតទាន់នឹង គឺអត់ខ្វះទេ ។

ដានី ៈ អត់មានខ្វះអាវុធទេ?

សារ៉ុន ៈ បាទ! អត់ខ្វះទេ ។

ដានី ៈ ប៉ុន្តែកងទ័ពកាលនោះនៅកន្លែងព្រៃ កន្លែងស្រុកកែវសីម៉ា?

សារ៉ុន ៈ បាទ! ហើយមួយចំនួនគេឡើងមកនេះ តែមួយចំនួនគេនៅនោះ គេសម្រាប់ធ្វើការនឹង ព្រោះគេសំដៅធ្វើស្រែធ្វើចំការនៅកែវសីម៉ានឹង ។

ដានី ៈ ធ្វើស្រែនៅក្នុងព្រៃនឹង?

សារ៉ុន ៈ អឺ! ធ្វើស្រែនៅក្នុងព្រៃនឹង ធ្វើចំការដាំដំឡូងរាប់សែន ។

ដានី ៈ ចឹងម៉ាចំនួននៅក្នុងព្រៃកែវសីម៉ា ម៉ាចំនួនឡើងមកខាងយើងនឹង មកខាងភ្នំដងរែកនេះ?

សារ៉ុន ៈ បាទ!

ដានី ៈ តែកាលនឹងអ៊ំនៅណា?

សារ៉ុន ៈ នៅកែវសីម៉ា ជិតខេត្ត ។

ដានី ៈ ចុះក្រែងយើងធ្វើស្រែធ្វើចំការ ចុះយើងមានវៃអី ជាមួយខាងកងទ័ពវៀតណាមអីដែរ ហើយក៏អត់ទេ?

សារ៉ុន ៈ បើគេចេញមកវាគត្បាតវៃ គេមិនចេញមកក៏យើងអត់វៃគេ ខំធ្វើស្រែធ្វើចំការដាំដំឡូង រាប់ម៉ឺនរាប់សែន ។

ដានី ៈ ចុះដូចថាពេលនឹងយើងមានដាក់មីន ដាក់ចំរូងអីដែរអត់?

សារ៉ុន ៈ អត់ទេ យើងដាក់កន្លែងណា ប្រជាជនអត់ដើរបានយើងដាក់ បើដាក់ហើយក៏យើង ប្រកាសប្រាប់ប្រជាជន ដល់ណាយើងដាក់នឹង ក៏យើងប្រកាសប្រជាជនកុំទៅផ្លូវនេះៗ ខ្លាចត្រូវមីនរបស់យើងណា ។

ដានី ៈ ដាក់មីនទេ កាលនឹងមានគម្រោងដាក់ចំរូង?

សារ៉ុន ៈ ចំរូងខ្វះ មីនខ្វះ ។ មីននឹងយើងមិនសូវដាក់ច្រើនទេ យើងខ្លាចត្រូវប្រជាជន ខ្លាចស្លាប់ ។

ដានី ៈ ចំរូងនឹងយើងធ្វើរបៀបម៉េច ចំរូងនឹងយកទៅដាក់នឹង?

សារ៉ុន ៈ ដើមឫស្សីយើងនេះ ពុះហើយត្រូវឲ្យស្រួច បិទទៅវាស្រួចខាងចុះ ស្រួចខាងខ្នងក៏ដោត ទៅ ដោតៗ ហែលៗទៅ តែប៉ុននឹង ។

ដានី ៈ យើងដោតតាមផ្លូវ ឬក៏ដោតតាមណា?

សារ៉ុន ៈ ដោតតាមព្រៃក៏ដោត តាមផ្លូវក៏ដោត ។

ដានី ៖ អាចំរូងមុខវានឹងយើងមានលោបជាតិអីទៀតអត់?

សារ៉ុន ៖ អត់មានទេ ។

ដានី ៖ ចុះគេថា មានដ័រឆក់នោះ?

សារ៉ុន ៖ គេថាមាន ចំពោះខ្ញុំអត់បានលោប ខ្លាចត្រូវប្រជាជន ។

ដានី ៖ ខ្លាចត្រូវប្រជាជនការពារនៅកែវសីម៉ានឹង អត់មានដាក់ មានលោបទេ យើងដាក់តែចំរូងទទេរ?

សារ៉ុន ៖ បាទ! ដាក់ចំរូងទទេរ មីនក៏មិនសូវបានដាក់ ។

ដានី ៖ កាលនឹងកងទ័ពអ៊ំនៅនឹង មាន៤០០០នាក់ ហើយអ្នកដែលត្រូវពេលនឹងអ៊ំបែងចែកម្ខាងឡើងមកភ្នំដងរែក ម្ខាងនៅនឹង មានប៉ុន្មានវរៈទៅ?

សារ៉ុន ៖ នៅនឹងមានតែមួយវរៈទេ ប្រហែលជាកងទ័ពសុទ្ធ ប្រហែលជាង១០០នាក់ ២០០នាក់ទេ ។

ដានី ៖ នៅខាងកែវសីម៉ានឹង?

សារ៉ុន ៖ បាទ! អាវាច្រើន៤០០០នាក់នឹង វាទាំងស្រីទាំងប្រុស ទាំងកូនងែតកូនងាំនឹង ដែលសាច់ទ័ពនឹងតែជាង២០០០នាក់ទេ ។ ឃើញគេទៅនៅភូមិទៅ គេចោទគេប្រកាន់ចេះចុះយើងអ្នកកងទ័ពចាស់ៗនឹងចេះតែរត់មកៗ ។

ដានី ៖ ចុះអ៊ំនៅកែវសីម៉ាដល់រយៈពេលប៉ុន្មានទៅបានផ្លាស់ចេញពីកែវសីម៉ា?

សារ៉ុន ៖ មកតាំងពី៧៩រហូតមក៧៧ អូ!៧៦ គេទៅយកពួកខ្ញុំឡើងមកភ្នំ ។

ដានី ៖ ៧៩មកនៅព្រៃកែវសីម៉ា?

សារ៉ុន ៖ បាទ!

ដានី ៖ ដល់ឆ្នាំប៉ុន្មានបានគេទៅយក?

សារ៉ុន ៖ ពីឆ្នាំ ៧០អឺ! ៩៦ មិនមែន៧០ទេ ខ្ញុំច្រឡំនិយាយ ។

ដានី ៖ ៧៩មក ៨០?

សារ៉ុន ៖ បាទ! ដល់៨៦ បានគេទៅយកខ្ញុំ ។

ដានី ៖ ដល់៨៦គេទៅយក?

សារ៉ុន ៖ បាទ! ទៅយក ។

ដានី ៖ ពីណាទៅយក?

សារ៉ុន ៖ ខាងកងទ័ពគេនៅលើភ្នំ ។

ដានី ៖ កងទ័ពកងពលណាដែលគេទៅយកអ៊ំ?

សារ៉ុន ៖ កងពលចាស់របស់ខ្ញុំនឹង ។

ដានី ៖ កងពលដែលថាទៅម៉ាចំនួនមកខាងលើភ្នំដងរែកនឹង?

សារ៉ុន ៖ បាទ!

ដានី ៖ កាលនឹងមកលើភ្នំដងរែកនឹង ប៉ុន្មានវរៈមកដងរែកនឹង?

សារ៉ុន ៖ មើលកាលមុននឹង យើងមានពីរវរៈ។ទៅជំនួសមនុស្សនឹងវាច្រើន ព្រោះគ្នាចេះតែរត់។ មក។ គេក៏ចាត់តាំងកម្លាំងទៅយកពួកនឹងប្រហែល៦០នាក់ ។ ទៅយកហើយ ព្រោះខ្ញុំមិនត្រូវគ្នាក៏ខ្ញុំឆ្លងទន្លេមក គេមកទទួលដឹកមក ។ ច្រើនណាស់ មកនឹង ។

ដានី ៖ ចុះ អ៊ំ អនស៊ី, វៀងអី កាលនឹងនៅជាមួយអ៊ំដែរ ហើយក៏គេមក?

សារ៉ុន ៖ បាទ! ឡើងមកមុន ។

ដានី ៖ ឡើងមកមុនហើយ ចឹងអ៊ំនៅតែអ៊ំទេនៅនឹង?

សារ៉ុន ៖ បាទ! នេះវាចេះបានវានៅ មិត្តយើងទៅវៃគ្នានឹងទៅដាន់មីនរបួស២-៣នាក់ទៅ បើយើងសាប់អស់ទៅចោលកន្លែងកងទ័ពមានពីណា ទៅជួយព្យាបាលគេទិញថ្នាំទិញ ក៏គេចាត់តាំងឲ្យខ្ញុំចាំអ្នករបួសអ្នកអីនឹងទៅតាមបទបញ្ជាដឹកតាមកម្លាំងមកមុនទាំងអស់ ។ ដល់ ៨៦ ក៏គេចុះទៅយកខ្ញុំមកទៀត ។

ដានី ៖ តា អនស៊ី នឹងគាត់ទៅយកអ៊ំមក?

សារ៉ុន ៖ អត់ទេ គេឲ្យកម្លាំង ។

ដានី ៖ គេឲ្យកម្លាំងទៅយកទេ?

សារ៉ុន ៖ បាទ! (ស្តាប់មិនបាន) ។

ដានី ៖ តា វៀង អីក៏អត់ទៅដែរ?

សារ៉ុន ៖ អត់ទេ ។

ដានី ៖ ចឹងអ៊ំនៅខាងកែវសីម៉ានឹង ៦-៧ឆ្នាំដែរចឹង?

សារ៉ុន ៖ អឺ! ៦-៧ឆ្នាំ ។

ដានី ៖ ចឹងអ៊ំឆ្លងទន្លេមក ឆ្លងកន្លែងណា?

សារ៉ុន ៖ ឆ្លងកន្លែងកោះរង៉ាវ ។

ដានី ៖ ឆ្លងយ៉ាងម៉េច បើគ្នាដល់ទៅ២០០០-៣០០០នាក់?

សារ៉ុន ៖ មុនដែលយើងទៅនឹង យើងទិញកាណូតត្រៀមនៅនឹង៣គ្រឿង កាណូតធំៗ ។ ហើយពេលមកដល់ទៅ យើងទាក់ទងរកប្រជាជនមូលដ្ឋានជួលកាណូតគេដាក់ ឆ្លងតែអ្នកធ្វើការប្រជាជនគេជួយការពារឃាមកាម ដើម្បីឃើញទាហានអីចេញមកគេរាយការណ៍ ឆ្លងម៉ាយប់នឹងគឺអស់ ។

ដានី ៖ ២០០០នាក់ជាងនឹងគឺអស់ម៉ង?

សារ៉ុន ៖ អស់ម៉ង ។

ដានី ៖ ឆ្លងតែម៉ាយប់នឹងទេ?

សារ៉ុន ៖ តែម៉ាយប់ ។

ដានី ៖ ឆ្លងពីកោះរង៉ាវ ពីត្រើយខាងកើតមកត្រើយខាងលិច?

សារ៉ុន ៖ បាទ!

ដានី ៖ មកត្រើយខាងលិច មកនៅណាទៅ?

សារ៉ុន ៖ ដើរមករហូត ។

ដានី ៖ ២០០០នាក់ ដល់យើងឆ្លងមកដល់ត្រើយខាងលិចនេះយើងដើរបន្តមកទៀត?

សារ៉ុន ៖ ដើរមក២-៣ខែ បានដល់ដងរែកនឹង ។

ដានី ៖ ដើរមកយើងស្នាក់នៅតាមផ្លូវបណ្ដើរៗទៅ?

សារ៉ុន ៖ បាទ! ២-៣ថ្ងៃទៅ មានការមនុស្សយើងក្មេងឈឺគ្រុនច្រើនទៅក៏សម្រាក២-៣ថ្ងៃទៅចាក់ថ្នាក់ចាក់សង្កូវអីធូរធារហើយក៏ដើរទៅទៀត ។

ដានី ៖ ដើរកាត់តាមណា?

សារ៉ុន ៖ កាត់តាមនេះ ។

ដានី ៖ ពីកោះរង៉ាវឆ្លងមកខាងលិច ហើយកាត់មកត្រង់ណា?

សារ៉ុន ៖ ត្រង់ណាទេ អត់ចាំភូមិគេណា បែបកំពង់ធំនឹងឯង ចាក់មកចូលភូមិគេក៏នៅដេកនៅនឹងទិញអង្ករទិញម្ហូប អាហារអីសម្រាកនៅនឹង ហូបចុកអីបំប៉នបងប្អូនមានកម្លាំងទៅទៀតចូលភូមិណាសម្រាកភូមិនឹង ។ កាលមុននៅតាមភូមិនឹងសុទ្ធតែកម្លាំងកងទ័ពនេះនឹង ។

ដានី ៖ ខាងខ្មែរក្រហម?

សារ៉ុន ៖ បាទ!

ដានី ៖ ចឹងចេញមកពីខាងកោះរង៉ាវនឹង ចាក់មកដើរតាមភូមិក្នុងខេត្តកំពង់ធំ?

សារ៉ុន ៖ បាទ!

ដានី ៖ ចេញពីកំពង់ធំមកខេត្តណាទៀត?

សារ៉ុន ៖ ទេ! មានតែកាត់មកដល់ភ្នំនេះម៉ង ។

ដានី ៖ ដល់ភ្នំ?

សារ៉ុន ៖ ទល់អ្នកភូមិខ្ញុំអត់ស្គាល់ទេ ចូលភូមិណា ទិញអង្ករទិញអីនៅនឹងៗ ។

ដានី ៖ ចឹង៣ខែបានឡើងដល់ភ្នំ?

សារ៉ុន ៖ ៣ខែ ។

ដានី ៖ ខែប៉ុន្មានទៅឡើងដល់លើភ្នំ?

សារ៉ុន ៖ អឺ! ខែប៉ុន្មានទេហី អត់ចាំទេ ។

ដានី ៖ ពេលនឹងខែប្រាំង ខែវស្សា ដែលពេលឡើងដល់លើភ្នំនឹង?

សារ៉ុន ៖ ខែវស្សា ។

ដានី ៖ ខែវស្សា?

សារ៉ុន ៖ បាទ! ដឹងខែណាទេ អត់ចាំទេ ។

ដានី ៖ ខែវស្សាជិតឆ្នាំ៨៦នឹង?

សារ៉ុន ៖ បាទ!

ដានី ៖ ឡើងលើភ្នំនឹង ឡើងមកនៅណាទៅ?

សារ៉ុន ៖ ឡើងមកលើក្នុងដីថៃ ជំរំគេនៅក្នុងដីថៃ គេធ្វើជំរំស្រេច ។

ដានី ៖ ហោះនៅដីថៃនឹង?

សារ៉ុន ៖ បាទ!

ដានី ៖ គេហៅអីគេ?

សារ៉ុន ៖ ដឹងហៅអីគេ ។

ដានី ៖ ហៅជំរំអីកាលនឹង?

សារ៉ុន ៖ គេអត់ហៅជំរំអីទេ មិនមែនដូចខាងក្រោមទេ គេហៅជំរំខាវអ៊ីដាង អានឹងគេអត់ មាន ហៅ ។

ដានី ៖ អត់មានអូរត្រាវ?

សារ៉ុន ៖ អឺ!

ដានី ៖ ស៊ីងច័ន្ទ អីមិនមែន?

សារ៉ុន ៖ ស៊ីងច័ន្ទ អឺ! ។

ដានី ៖ ហៅជំរំអីគេ ស៊ីងច័ន្ទ?

សារ៉ុន ៖ ស៊ីងច័ន្ទ ។

ដានី ៖ កាលនឹងអ៊ំឡើងដល់លើភ្នំ អ៊ំទទួលតួនាទីអីទៅ?

សារ៉ុន ៖ នៅដដែល ។

ដានី ៖ នៅតែ?

សារ៉ុន ៖ កងពលដដែល ។

ដានី ៖ ប្រធានកងពល១០៥ដដែល?

សារ៉ុន ៖ បាទ!

ដានី ៖ ប៉ុន្តែអ៊ំអត់ ដល់ពេលឡើងដល់ជំរំនឹង អ៊ំអត់មានចេញទៅមុខសញ្ញា ទៅវៃអី?

សារ៉ុន ៖ ចុះ គេដេញចុះទៅក្រោម ទៅមណ្ឌលគិរីដដែល ។

ដានី ៖ គេឲ្យទៅមណ្ឌលគិរីដដែល?

សារ៉ុន ៖ បាទ!

ដានី ៖ ឲ្យអ៊ំទៅខាងណាវិញ?

សារ៉ុន ៖ នឹងទៅនៅមណ្ឌលគិរីនឹង ទៅនៅកន្លែងចាស់នៅកែវសីម៉ា ។

ដានី ៖ ចុះទៅវិញទៀត មកដល់លើភ្នំហើយចុះទៅវិញទៀត?

សារ៉ុន ៖ អឺ! ចុះទៅវិញទៀត ។

ដានី ៖ ចុះទៅជាមួយពីណាខ្លះកាលនឹង?

សារ៉ុន ៖ អូ! ច្រើនណាស់កងទ័ព៥០-៦០នាក់ ។

ដានី ៖ ចុះអ៊ំប្រធានកងពលមួយទាំងមូលម៉េចក៏ទៅតែកងទ័ព៥០-៦០?

សារ៉ុន ៖ វា ពីព្រោះគេថាទុកវៃខាងនេះខ្លះ (ស្តាប់មិនបាន)ជាង១០០ ។

ដានី ៖ អ៊ំទៅជាមួយពីណាកាលនឹង?

សារ៉ុន ៖ ច្រើនណាស់ ។

ដានី ៖ និយាយថា គណៈកងពលដូចអ៊ំដែរ អ៊ំទៅពីណាខ្លះ?

សារ៉ុន ៖ អត់ទេ ទៅតែខ្ញុំម្នាក់ទេ ក្រៅពីនឹងមានតែវរសេនាតូចទេ ។

ដានី ៖ ចុះ តា អនស៊ុំ តា វៀង អីគាត់អត់ទៅជាមួយអ៊ំទេ?

សារ៉ុន ៖ អត់ទេ ម៉ាឆ្នាំដូរគ្នាម្តង ។

ដានី ៖ ម៉ាឆ្នាំដូរគ្នាម្តង?

សារ៉ុន ៖ បាទ! ម៉ាឆ្នាំដូរគ្នាម្ដង គេទៅដូចខ្ញុំទៅធ្វើការបានម៉ាឆ្នាំហើយ គេក៏ចុះទៅរៀបកម្លាំងចុះទៅដូរខ្ញុំៗក៏ឡើងមក ដូរគ្នាវិលទៅចឹង ។

ដានី ៖ ដូរវិលគ្នា ដូចថាគណៈកងពលមាន៣នាក់ចឹង?

សារ៉ុន ៖ បាទ!

ដានី ៖ ដល់អ៊ំទៅម៉ាឆ្នាំ អ៊ំឡើងមកវិញ តា អនស៊ី គាត់ទៅម្ដង?

សារ៉ុន ៖ អឺ! ដល់គេទៅដល់នោះទៀត បានវិលមក ។

ដានី ៖ ដល់ពេលគាត់ដល់ម៉ាឆ្នាំទៅ តា វៀង គាត់ទៅម្ដង?

សារ៉ុន ៖ បាទ!

ដានី ៖ ដូរគ្នា ផ្លាស់គ្នា ក្នុង៣នាក់ ឬប៉ុន្មាននាក់?

សារ៉ុន ៖ ៣នាក់ ។

ដានី ៖ ផ្លាស់គ្នារហូត ចឹងទៅខាងមណ្ឌលគិរីរហូតកងពល១០៥?

សារ៉ុន ៖ បាទ!

ដានី ៖ ចុះអ៊ំពេលដែលឡើងមកដល់លើនេះហើយ ដូចថាខាងកងទ័ពខ្មែរក្រហម យើងមិនវៃផង យើងមិនដាក់មីនផង យើងធ្វើចំរូងផង អាចំរូងជ័រឆក់នោះ?

សារ៉ុន ៖ ដឹងគេខាងក្រោយ ដឹងគេដាក់អីទេ ឃើញតែដាក់មីន ឃើញដូចអត់បានដាក់ទេ យកសាក់ដាក់ម៉េចបាន ត្រូវភ្លៀងរលាយអស់ហើយនឹង ។

ដានី ៖ ប៉ុន្តែរបៀបគេធ្វើជ័រឆក់គេធ្វើយ៉ាងម៉េច?

សារ៉ុន ៖ អឺ! អត់ដឹងទេ មិនដឹងគេធ្វើយ៉ាងម៉េច ខ្ញុំអត់ចេះដែរ អត់ចេះទេ គេថាដោតជ័រឆក់ៗនោះណា ។

ដានី ៖ ប៉ុន្តែក្រែងជ័រឆក់នឹងក្រែងបងប្អូនជនជាតិយើងអ្នកធ្វើតើ?

សារ៉ុន ៖ អឺ! ប៉ុន្តែយើងជនជាតិដែរ តែយើងអត់ដឹងៗគេធ្វើរបៀបម៉េច មិនបានឃើញគេធ្វើ ។

ដានី ៖ ខាងកងទ័ពខ្មែរក្រហម ប៉ុន្តែគាត់ខាងខ្មែរគាត់អត់ធ្វើទេ ខាងបងប្អូនជនជាតិទេ គាត់អ្នកធ្វើ?

សារ៉ុន ៖ បាទ! អត់ទេ ខាងខ្មែរអ្នកធ្វើដែរ ជ័រឆក់នឹង គេរៀនពីគ្នាទៅវិញទៅមក ។

ដានី ៖ ប៉ុន្តែរៀនពីបងប្អូនជនជាតិ?

សារ៉ុន ៈ ប៉ុន្តែមិនឃើញបានដាក់ទេ ជ័រឆក់នឹង ។ ដាក់យ៉ាងម៉េច បើយើងដាក់ថ្ងៃ ត្រូវថ្ងៃរលាយអស់ហើយ ត្រូវភ្លៀងកាន់តែរលាយអត់មានសល់អីទេ ជ័រឆក់ តែដឹងគេស្ងោរយ៉ាងម៉េចៗទេ ខ្ញុំអត់ដឹង ។

ដានី ៈ ចុះអ៊ំ យើងទៅខាងមណ្ឌលគិរី ទៅដល់ឆ្នាំណាទៅបានឈប់ទៅ?

សារ៉ុន ៈ រហូតដល់មានអ៊ុនតាក់ទៅ គេប្រកាសថាឈប់បាញ់ ហើយម្តងនេះគេថាឲ្យពួកខ្ញុំនេះទៅរៀបចំកន្លែងនឹងណា ដែលគេឈប់បាញ់ហើយ តែគេមិនទាន់ដកអាវុធ គេថាចាំគណៈកម្មការគេដកអាវុធៗនឹងក៏យើងគេក៏ជូនឲ្យពួកខ្ញុំនឹងទៅរៀបចំកន្លែងប្រជាជន ព្រោះខ្ញុំទៅទាក់ទងនៅមូលដ្ឋាននឹង យកអាកន្លែងឥឡូវ បងប្អូនយើងចុះពីជំរំនៅស្រែជ្រៃនឹងណា កន្លែងចាស់កណ្តាល ព្រោះពួកខ្ញុំវាស្រែច្រើន ៤០០០-៥០០០ហិចតា ។ ហើយវាលនៅសល់ច្រើនទៀត ។

ដានី ៈ ស្រុកពេជ្រចិន្តា?

សារ៉ុន ៈ អឺ! ទៅទាក់ទងមូលដ្ឋានគេៗឯកភាពថាឲ្យទៅនៅនឹង មានអីដល់២-៣ខែថា វិត្នាវិញទៀត ។ គេឲ្យដឹកទៅទាំងអស់ម៉ង ថាឲ្យទៅរៀបចំមុន រៀបចំកន្លែងនៅនឹង ។

ដានី ៈ ដឹក យើងមកពី១០៥ ឲ្យដឹក១០៥ទៅវិញទាំងអស់ កាលជំនាន់អ៊ុនតាក់នឹង?

សារ៉ុន ៈ បាទ! ព្រោះខ្ញុំតាមនឹង ប្រហែលជាង១០០០០នាក់ គេឲ្យកាន់ដែរ កាំភ្លើងកំប៉េចកំប៉ុងគ្រាន់តែបាញ់ស៊ីនឹង គ្រាន់បាញ់សត្វហូប ។

ដានី ៈ ទៅបានរយៈពេលប៉ុន្មាន បានត្រឡប់មកវិញ?

សារ៉ុន ៈ មានអីទើបរួចនឹង គេប្រកាសថាវិត្នាវិញទៀត ម្តងនេះគេទៅយកពួកខ្ញុំមកវិញ ។

ដានី ៈ ពីណាទៅយកមកវិញ?

សារ៉ុន ៈ ខាងនេះខាងកងទ័ពដូចនៅខាងក្រោយនេះគេទៅយកមកវិញ ។

ដានី ៈ កងទ័ពនៅខាង?

សារ៉ុន ៈ ១០៥នឹងដែរ ។

ដានី ៈ កងទ័ពខាង១០៥ទៅយកមកវិញ?

សារ៉ុន ៈ បាទ! យកមកវិញ អ្នកខ្លះក៏ទៅនៅស្រុកនៅភូមិ អ្នកខ្លះក៏បានមក អ្នកខ្លះក៏នៅ ។

ដានី ៈ អ៊ំអីគេទៅយកមកវិញដែរ?

សារ៉ុន ៈ បាទ! យកមកវិញក៏មកទៀត ទាំងយាយទាំងអីនឹង ពីព្រោះគេថាចប់ឈប់បាញ់ហើយណា ក៏ទៅនៅមុនដំបូងនៅកន្លែងគេជីកមាស ដើម្បីឲ្យបងប្អូនជីកមាសបានលុយបានកាក់

ទៅ ទាក់ទងជាមួយមូលដ្ឋានគេ ថាកន្លែងស្រុកពេជ្រចិន្តាវាស្រែល្អ រួចដីធ្លីក៏វានៅសល់ច្រើនៗ ដល់មកវិញ ថាវៃគ្នាទៀត អ្នកខ្លះក៏មក អ្នកខ្លះក៏អត់ទៅៗ

ដានី : ចុះដល់ពេលអ៊ំមកវិញ មកឆ្នាំ៩០ប៉ុន្មាន ដែលអ៊ំត្រឡប់ពីពេជ្រចិន្តាមកនៅនេះវិញ?

សារ៉ុន : អឺ! ៩៧ នេះធ្វើផ្ទះនេះ៩៧ៗ

ដានី : ធ្វើផ្ទះនេះ៩៧?

សារ៉ុន : បាទ! មកដល់នេះ៩៧ៗ

ដានី : ចុះអ៊ំ អ្នកស្រុកអ្នកភូមិដែលចុះមករស់នៅភូមិយើងហៅភូមិ១០៥នឹង មកនៅតាំងពីឆ្នាំណា?

សារ៉ុន : តាំងពីប៉ុន្មាន ៩១ ៩៨យើងទៅនៅកន្លែងជិតអូរជីកទឹកលិចនឹងៗ

ដានី : ចឹងយើងចុះមកដំបូងឆ្នាំ៩១ មកនៅនេះ?

សារ៉ុន : បាទ!

ដានី : ចុះមកនឹង កាលនឹងតែពួកក្រុមកង១០៥របស់អ៊ំទេ មកនៅភូមិនឹងទាំងអស់?

សារ៉ុន : នៅទាំងអស់ដូចរៀប ទាំង១០៥អីៗ រៀបភូមិរហូតទាល់តែនឹងអានោះប្រាសាទព្រះវិហាររៀបៗ

ដានី : ប្រាសាទព្រះវិហារ?

សារ៉ុន : អឺ! រៀបទៅរហូតសុទ្ធតែភូមិទៅហែលៗទៅចឹងៗ

ដានី : ប៉ុន្តែភូមិ១០៥ ដែលកងទ័ពខាងតំបន់១០៥ទាំងអស់នឹង មកនៅនឹងភូមិ១០៥ទាំងអស់ប៉ុក៏មានពួកអ្នកណាផ្សេងចូលមកនៅក្នុងភូមិនឹងចំរុះជាមួយដែរ?

សារ៉ុន : មានៗ

ដានី : ឆ្នាំ៩១មកដំបូង?

សារ៉ុន : បាទ! មានតែបងប្អូនយើងខាងគេមកយកប្រពន្ធនៅកងពលផ្សេងៗទៅជិតគ្នាទៅគេយកប្រពន្ធក៏មកនៅនឹងរហូតៗ

ដានី : អ្នកដែលគេយកប្រពន្ធយកអីបងប្អូនជនជាតិក៏មកនៅនឹងដែរ?

សារ៉ុន : អឺ!

ដានី : ប៉ុន្តែដំបូងតែបងប្អូនជនជាតិទេនៅ១០៥នឹង?

សារ៉ុន : អត់ទេ មានក្មេង លាយឡំៗ

ដានី : ចុះម៉េចបានគេហៅឈ្មោះ១០៥ចឹង?

សារ៉ុន ៖ ដឹង គេតែតាំងពីដើមមក តាំងពីយើងនៅមណ្ឌលគិរីនឹង គេចេះតែហៅ១០៥៧ ហៅតាមគេទៅ ។

ដានី ៖ ចុះភូមិ១០៥ដំបូង ពីណាគេអ្នកដឹកនាំប្រធានគេ?

សារ៉ុន ៖ ខ្ញុំនឹងហើយ ។

ដានី ៖ អ្នកភូមិនឹង ដល់ពេលបង្កើតមក អ៊ំជាអ្នកប្រធាន?

សារ៉ុន ៖ អឺ! មករៀបចំភូមិនេះ នៅនេះ រៀបចំភូមិករណ៍អីនៅនេះ បានខ្ញុំ បានមានអ៊ុនគាត់ចុះមកដោះស្រាយថាឲ្យចុះមកវិញ ហើយពួកខ្ញុំក៏យកកម្លាំងគេថាចុះទៅ ឥឡូវទាហានឈប់បាញ់គ្នាហើយ យកមីន១ចុះទៅបណ្តើរ១ ។ ដើម្បីឲ្យខ្ញុំនេះចុះមុន ដើម្បីរៀបចំមូលដ្ឋានឲ្យប្រជាជនយើងចុះក្រោយណា ។ មានទៅទាន់ចុះក្រោយណា ថា១ខែ២ខែ ថាបាញ់គ្នាទៀត ។

ដានី ៖ ចុះកាលនឹងពេលដែលអ៊ំមកដល់លើភ្នំនឹង ដូចថាកាលនឹងយើងទាក់ទងយ៉ាងម៉េច ទាក់ទងជាមួយ តា ម៉ុក ដែរអត់ទេ?

សារ៉ុន ៖ គេ បើមិនទាក់ទងម៉េចយើងគ្មានបាយស៊ី គេហើអ្នកជូនបាយជូនទឹកឲ្យយើង ។

ដានី ៖ តា ម៉ុក?

សារ៉ុន ៖ តា ម៉ុក តាអីនឹង ។

ដានី ៖ អ៊ំស្គាល់ តា ម៉ុក ច្បាស់ទេ?

សារ៉ុន ៖ អត់ច្បាស់ទេ ។

ដានី ៖ អត់ស្គាល់ច្បាស់ទេ?

សារ៉ុន ៖ បាទ! មិនដឹង តា អត់ស្គាល់អត់ច្បាស់ទេ ។

ដានី ៖ អត់ដែលទៅជួប តា ម៉ុក ទៅពិភាក្សា ឬក៏ទៅនិយាយស្តីអីជាមួយ តា ម៉ុក?

សារ៉ុន ៖ អត់ទេ ។

ដានី ៖ ចុះ តា សុន សេន?

សារ៉ុន ៖ អត់ដែរ ។ សុន សេន គាត់នេះនោះពីលើមក តាមរយៈសំបុត្រស្នាម(ស្តាប់មិនច្បាស់)

ដានី ៖ អត់ដែលទៅប្រជុំ អត់ដែលទៅនិយាយអីជាមួយ តា ម៉ុក, តា សុន សេន អីទេ?

សារ៉ុន ៖ អត់ទេ ។

ដានី ៖ ចុះ តា ប៉ុល ពត?

សារ៉ុន ៖ អត់ទេ មកដល់នោះអត់ទេ អត់ដែលបានទៅជួប ។

ដានី ៖ តា នួន ដាអី?

សារ៉ុន ៖ អត់ដែរ ។

ដានី ៖ តា ខៀវ សំផន?

សារ៉ុន ៖ អត់ដែរ រិតតែឆ្ងាយ ។

ដានី ៖ ចុះអ៊ំដោយសារអ៊ំឆ្លងកាត់មកច្រើនរបបច្រើនជំនាន់តាំងពីក្មេងមក ហើយសម័យ៣ឆ្នាំអ៊ំមានតួនាទីជាកម្មាភិបាល ជាអ្នកដឹកនាំ ដូចថាអ៊ំឆ្លងកាត់ច្រើនចឹង ដូចច្បាប់ទម្លាប់អីយ៉ាងម៉េចដែរ ម៉ារបបៗវាមានខុសគ្នាម៉េចដែរពីជំនាន់តាំងពីសង្គមរាស្ត្រនិយមរបស់សម្តេចសីហនុ ជំនាន់៣ឆ្នាំ ហើយជំនាន់ក្រោយមកទៀត ក្រោយ៧៩ អ៊ំឆ្លងកាត់ចឹងអ៊ំឃើញថា ច្បាប់ទម្លាប់អីខុសគ្នាម៉េចទៅ?

សារ៉ុន ៖ ច្បាប់ដូចជាមិនសូវយល់ ច្បាប់យ៉ាងម៉េច នឹកឃើញយ៉ាងម៉េច អត់យល់ទេ យល់ច្បាប់នឹងតាំងពីបារាំងមក ។

ដានី ៖ អត់យល់ទេ?

សារ៉ុន ៖ អឺ! អត់យល់ទេ ប៉ុន្តែជំនាន់នឹងចេះដើររកស៊ីសេរី អត់មានអីសំបុត្រមានស្លាកអី ដូចរបៀបចឹង ។ មកដល់របប៣ឆ្នាំទៀត វាមានទៅធ្វើស្រែធ្វើចំការគេទៅនិយាយពីរឿងអីដូចថាខំធ្វើស្រែដោះស្រាយជីវភាពប្រជាជនយើងឲ្យមានស៊ីមានចុក មានផ្ទះមានសម្បែងតែប៉ុននឹង វាខុសតែប៉ុននឹងណា សង្គមរាស្ត្រនិយមនឹង យើងបានរកស៊ីទៅលក់ទៅដូរទៅរកស៊ី ។

ដានី ៖ ចុះអ៊ំកន្លែងនេះជាភូមិចាស់គេពីមុនមក ហើយក៏ទើបបង្កើតថ្មីពេលដែលអ៊ំចុះមកឆ្នាំ៩១បង្កើតភូមិថ្មីនឹង ហើយក៏មានភូមិចាស់គេពីមុន?

សារ៉ុន ៖ អត់ទេ អត់មានភូមិចាស់ទេ ។

ដានី ៖ នេះភូមិថ្មីទេ?

សារ៉ុន ៖ ភូមិថ្មី ។

ដានី ៖ ចុះនៅម្តុំនឹង មានភូមិចាស់ មានប្រជាជនអីពីដើម ពីស្រុកកំណើតគេ?

សារ៉ុន ៖ អត់មានទេ ។

ដានី ៖ អត់មានទេ នៅក្បែរៗនេះក៏អត់មានដែរ?

សារ៉ុន ៖ អត់ មានតែអន្លង់វែងទេ ទីតាំងធំគេ ។

ដានី ៖ មានតែអន្លង់វែងទីតាំងធំ?

សារ៉ុន ៖ បាទ!

ដានី ៖ តែយើងផ្លាច់ខ្លួនមកដំបូង កាលនឹងនៅក្រោមចំណុះរបស់អន្លង់វែងដែរ?

សារ៉ុន ៖ អត់ទេ ។ ចុះមកពីជំរំធ្វើសមាហរណកម្មនេះ?

ដានី ៖ បាទ!

សារ៉ុន ៖ នៅស្រុកត្រពាំងប្រាសាទ ។

ដានី ៖ នៅនេះមិនមែនជាស្រុកអន្លង់វែងទេ?

សារ៉ុន ៖ បាទ!

ដានី ៖ ហើយចុះអ៊ំដល់ ពេលយើងសមាហរណកម្មឆ្នាំ៩៨ហើយ ដូចថាយើងចូលជាមួយរាជរដ្ឋាភិបាលហើយ?

សារ៉ុន ៖ បាទ!

ដានី ៖ កាលនឹងអ៊ំមានតួនាទីអីដែរ?

សារ៉ុន ៖ ទេ! ក្រោយមកគេហៅទៅ តួនាទីទាហានដដែល ។

ដានី ៖ ប៉ុន្តែអ៊ំមានតួនាទីដូចថាទាហានមានឋានៈអីដែរ?

សារ៉ុន ៖ គេថាឲ្យអានេះសេនាធិការរងកងពល អឺ! រងសេនាធិការកងពល ។

ដានី ៖ អ៊ំបានសក្តិប៉ុន្មានមុនចូលនិវត្តន៍?

សារ៉ុន ៖ សក្តិ៤ ។

ដានី ៖ កងពលលេខប៉ុន្មាន?

សារ៉ុន ៖ កងពល៤៣ ។

ដានី ៖ កងពល៤៣?

សារ៉ុន ៖ បាទ! ចំណុះយុទ្ធភូមិ ។

ដានី ៖ ពីណាគេប្រធានកងពល?

សារ៉ុន ៖ តា ពឹម ។

ដានី ៖ ហើយចុះអ៊ំចូលនិវត្តន៍តាំងពីឆ្នាំណាមក?

សារ៉ុន ៖ មើល២០០០ប៉ុន្មានទេ ។

ដានី ៖ ប៉ុន្មានឆ្នាំហើយ?

សារ៉ុន ៖ ៣-៤ឆ្នាំហើយ តាំងពីចូលនិវត្តន៍ មើល២០០៨ ។

ដានី ៖ ទើបចូលថ្មីៗនេះដែរ?

សារ៉ុន ៖ បាទ!

ដានី ៖ ចុះអ៊ុំដូចថា អ៊ុំតាំងពីអ៊ុំចេញពីផ្ទះអ៊ុំមកដូចថា ទំនាក់ទំនងអ៊ុំជាមួយបងប្អូនអ៊ុំនៅស្រុកកំណើតអីយើងបានទាក់ទងគ្នា បានទំនាក់ទំនងជាប់លាប់អត់ តាំងពីអ៊ុំចេញមកតស៊ូ?

សារ៉ុន ៖ បានជួបគ្នាហើយតើ នៅសមាហរណកម្មរួចហើយខ្ញុំបានទៅលេងបងប្អូននឹង

ដានី ៖ បានទៅលេងបងប្អូននៅនោះដែរ?

សារ៉ុន ៖ បាទ!

ដានី ៖ មិនសួរដាច់ទេនោះ?

សារ៉ុន ៖ អត់សួរដាច់ទេ ។

ដានី ៖ ចុះអ៊ុំម៉េចបានជាអ៊ុំសម្រេចចិត្តរស់នៅនេះអត់ត្រឡប់ទៅស្រុកកំណើតវិញ ឆ្នាំ៩៨ពេលដែលយើងសមាហរណកម្ម?

សារ៉ុន ៖ វាចេះ ណា៎!រដ្ឋាភិបាលគេថា សមាហរណកម្មរួចនេះណា គេថាដីធ្លីផ្ទះសម្បែងគេផ្តល់ជូនបងប្អូនទាំងអស់ យើងវាមានដីមានធ្លីផ្ទះសម្បែងហើយ ក៏ខ្ជិលទៅ ។

ដានី ៖ ខ្ជិលទៅ?

សារ៉ុន ៖ បាទ! គេហៅយើងចូលក្នុងស្ថាប័នអីក៏បានគ្រប់បែបយ៉ាង គេរក្សាសិទ្ធិយើងៗមានសេរីភាពដើរហើររកស៊ីប្រកបធ្វើស្រែធ្វើចំការបាន ស្រែចំការអីគេអត់មានឲ្យប៉ះពាល់របស់យើងនេះ នេះដូចផ្ទះសម្បែងខ្ញុំនេះ មកក៏នៅតាំងពីផ្ទះចាស់នេះ ។

ដានី ៖ ចឹងអ៊ុំក៏នៅនឹងទៅ ក៏អត់សម្រេចចិត្តទៅស្រុកវិញទេ?

សារ៉ុន ៖ បាទ! អត់ទៅ ក៏ខ្ជិលទៅ ។

ដានី ៖ ចុះអ៊ុំក្នុងទំនាក់ទំនងក្នុងក្រុមគ្រួសារអ៊ុំដូចថារាល់ថ្ងៃនេះដូចថាយ៉ាងម៉េចដែរ រអ្នករអឹនជាមួយគ្នាដែរ ឬក៏?

សារ៉ុន ៖ មានអី ដូចលោកក្មួយឃើញនៅជាមួយគ្នាចឹង ។

ដានី ៖ ចុះកាលពីមុន កាលពីសម័យតស៊ូ អ៊ុំមានគ្រួសារមានកូនដែរ កាលនឹងយ៉ាងម៉េចដែរ ជីវភាពអ៊ុំអីយ៉ាងម៉េចដែរ កាលពីមុនអ៊ុំតស៊ូ កាលពីមុនឆ្នាំ៧០?

សារ៉ុន ៖ មុនឆ្នាំ៧០ កាលនៅភូមិ?

ដានី ៖ កាលនៅភូមិ ។

សារ៉ុន ៖ ធ្វើស្រែធ្វើចំការ ។

ដានី ៖ ប៉ុន្តែយ៉ាងម៉េចដែរ រអ្នករអឹនជាមួយគ្នាដែរ?

សារ៉ុន ៖ រអ្កករអឺន មានស៊ីមានចុកល្មម យើងមិនខ្វះ ។

ដានី ៖ មានហូបមានចុកល្មម?

សារ៉ុន ៖ បាទ! យើងខ្វះក៏មិនខ្វះ មានក៏មិនមានល្មមរស់នៅសមរម្យ ។

ដានី ៖ ចុះអ៊ំមកដល់សព្វថ្ងៃនេះ អ៊ំមានដែលដូចថាពេលដែលកូនក្មួយកូនចៅអ៊ំមានដែរខសង្រាហ៍និយាយរឿងរ៉ាវប្រវត្តិអ៊ំតស៊ូ ប្រវត្តិដែលអ៊ំធ្លាប់មករស់នៅក្នុងស្រុកភូមិនេះ អ៊ំមានដែលនិយាយប្រាប់កូនក្មួយ កូនចៅអីដែរ?

សារ៉ុន ៖ និយាយដូចគេនិយាយខ្លះៗ យើងតស៊ូនៅក្នុងព្រៃ យើងវាលំបាកស៊ីក្តួចស៊ីដំឡូង លំបាកក្នុងសង្គ្រាមវាមានគ្រាលំបាកច្រើន នឹងកូនចៅក៏គេដឹង ពីព្រោះទាំងអស់គ្នាយើងដឹង ។ មានអីដែលនៅព្រៃកាលយើងនៅមិនទាន់បានធ្វើស្រែធ្វើចំការនឹង ស៊ីតែក្តួច និងដំឡូងអង្ករទិញមកបានតិចតួចទៅក៏ចែកគ្នាទៅ ដើម្បីយកទៅលាយជាមួយដំឡូងនឹង តែម្ហូបវាអត់ខ្វះ ។

ដានី ៖ ចឹងអ៊ំក្នុងចិត្តអ៊ំមានរឿងអីដែលពិបាកនឹងនិយាយ ឬក៏មិនចង់និយាយចេញមកប្រាប់យើងអ្នកជិតខាង ឬកូនក្មួយអី មានរឿងអីដែលមិនចង់និយាយចេញមកទេ?

សារ៉ុន ៖ មានអី មានតែចេះតែប្រាប់ថា យើងនៅព្រៃវាមានការលំបាកចេះមួយចុះមួយ ស៊ីក្តួចស៊ីដំឡូង លំបាករត់លូនៗ បាននៅសុខមួយកន្លែងធម្មតា បើគេម៉ោងបាយហើយយើងរត់លូនទៅភៀសខ្លួនដើម្បីរស់ ។

ដានី ៖ បាទ! អ៊ំចំពោះដូចថាញាតិមិត្តជិតខាងវិញ កាលពីអ៊ំជំនាន់អ៊ំតស៊ូ អ៊ំនៅក្នុងព្រៃ អ៊ំនៅលើភ្នំ នៅតស៊ូអី ការរាប់អានញាតិមិត្តជិតខាងបើប្រៀបធៀបមកឥឡូវយើងរស់នៅជាក្រុមគ្រួសាររកស៊ីរៀងៗខ្លួន ការរាប់អាន ការទាក់ទងគ្នាអីយ៉ាងម៉េច មានការខុសប្លែកពីមុនដែរ ហើយក៏ដូចកាលមុនដែរ?

សារ៉ុន ៖ ការរាប់អាននេះ ពីមុនក៏យើងរាប់អាន ឥឡូវនេះបើយើងឃើញអ្នកណាយើងធ្លាប់រាប់អានក៏រាប់អានធម្មតា អ្នកណាស្គាល់គ្នាណា៎ៗ អ្នកមិនស្គាល់ក៏យើងដូចថាធម្មតាទៅ បើយើងជា គេនិយាយជាមួយយើងៗនិយាយជាមួយគេទៅ ។

ដានី ៖ បាទ! ចឹងអ៊ំខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំអ៊ំទៀតហើយ ចឹងអ៊ំមានអីចង់បញ្ជាក់បន្ថែមនូវអ៊ីដែលខ្ញុំអត់បានសួរនាំអ៊ំទេ?

សារ៉ុន ៖ អត់ អស់ប៉ុននឹងហើយ ។ ខ្ញុំដែលខ្ញុំជម្រាបលោកក្មួយឯង ខ្ញុំរាយការណ៍នេះវាដូចជាថា កន្លែងខ្វះវា ពីព្រោះខ្ញុំវង្វេងវង្វាន់ វាភ្លេចការចងចាំ ខ្ញុំឈឺរយៈ២ឆ្នាំនេះ ឈឺមែនទែន និយាយទៅ(ស្តាប់មិនបាន) មានការលើសខ្វះ ក៏សុំអភ័យទោសចុះ ។

ដានី ៖ បាទ! អត់អីទេ អ៊ំ ។ ខ្ញុំអរគុណអ៊ំច្រើនដែលអ៊ំបានផ្តល់ព័ត៌មាន ដែលពីបទពិសោធន៍ពីជីវិតអ៊ំមានតម្លៃ វាមានប្រយោជន៍ច្រើនសម្រាប់ការខ្ញុំយកទៅសរសេរ យកទៅចងក្រងនេះ វាមានប្រយោជន៍ច្រើនមែនទែន ដែលអ៊ំបានឆ្លងកាត់ពីដំណាក់កាលនឹងអ៊ំ ។ បាទ! ខ្ញុំអរគុណច្រើន ផ្តល់បទសម្ភាសន៍ជាមួយខ្ញុំជាង២ម៉ោងនេះ ខ្ញុំអរគុណអ៊ំច្រើន ។

សារ៉ុន ៖ បាទ!

«ចប់»